**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Universitè Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សន្តតិកម្មតាមមតកសាសន៍

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ភ ធឿន ស្រីនិច**

**ភ រេត រតនា**

ណែនាំដោយសាស្ត្រាចារ្យ

លោកស្រី **ឃឹម ម៉ាណែត**


បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០១៩

ជំនាន់ទី ២៣

ឆ្នាំសរសេរសារណា ២០២៣

# អារម្ភកថា

នៅក្នុងអំឡុងពេល ៤ ឆ្នាំ នៃការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៅសាលកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នាងខ្ញុំទាំងពីរអ្នកទទួលបាននូវទ្រឹស្តី បទពិសោធន៍ និងការអនុវត្តផ្ទាល់ជាច្រើនពីមុខវិជ្ជាដែលមាននៅក្នុងកម្មវិធីសិក្សា។ នៅក្នុងមុខវិជ្ជាដែលពួកយើងខ្ញុំបានសិក្សាកន្លងមកនោះ ពួកយើងខ្ញុំក៏មានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើផ្នែករដ្ឋប្បវេណី ទើបពួកយើងខ្ញុំ សម្រេចចិត្តយក ប្រធានបទស្តីពី **សន្តតិកម្មតាមមតកសាសន៍** ដែលមានចែងនៅក្នុងគន្ថីទី៨ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មកធ្វើជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវក្នុងសារណាបញ្ចប់ឆ្នាំសិក្សានេះ។

ដោយសារស្ថានភាពនៃការបែងចែកទ្រព្យសម្បត្តិនៅកម្ពុជាយើងមានភាពស្មុកស្មាញ និងមានការឈ្លោះទាស់ទែងគ្នាចំពោះបញ្ហានេះ ពួកយើងខ្ញុំក៏សម្រេចចិត្ត និងចាប់យកឱកាសសរសេរសារណាដែលទាក់ទងនឹងប្រធានបទមួយនេះ។ នៅក្នុងការចងក្រងសារណានេះឡើង ពួកយើងខ្ញុំបានពឹងផ្អែកទៅលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ជាចម្បង និងសៀវភៅនានា ដែលមានការពន្យល់ឲ្យកាន់តែច្បាស់លាស់នៅលើផ្នែកសន្តតិកម្មតាមមតកសាសន៍នេះ។ ហើយទោះបីជាការស្រាវជ្រាវទាក់ទង និងប្រធានបទសន្តតិកម្មតាមមតកសាសន៍ ខាងលើនេះ មិនចាត់ទុកជាស្នាដៃល្អឥតខ្ចោះក៏ដោយ ក៏ប៉ុន្តែស្នាដៃនេះជាការខិតខំប្រឹងប្រែងយ៉ាងខ្លាំងពីក្រុមរបស់យើងខ្ញុំដើម្បីបានលេចចេញរូបរាងជា ប្រធានបទមួយនេះមកបាន ហើយក៏ជាការវាយតម្លៃនូវចំណេះដឹងរបស់ពួកយើងខ្ញុំដែលបានចំណាយពេលសិក្សាអស់រយៈពេល ៤ឆ្នាំកន្លងមកនេះ។

ជាចុងក្រោយក្រុមរបស់យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការសិក្សាស្រាវជ្រាវមួយនេះអាចចូលរួមចំណែកនៅក្នុងការពង្រឹងចំណេះដឹងដល់អ្នកដែលមានបំណងក្នុងការសិក្សាស្វែងយល់អំពី ប្រធានបទមួយនេះ។ ទោះបីជាយ៉ាងណាក៏ដោយ សារណាបញ្ចប់ឆ្នាំសិក្សានេះប្រាកដជាមានកំហុសខុសឆ្គងដែលមិនអាចជៀសវាងបាន ហើយចាំបាច់មានការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្សច្បង និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ ដើម្បីឲ្យស្នាដៃនេះកាន់តែល្អប្រសើរ។ ក្រុមយើងខ្ញុំនឹងទទួលរាល់ការរិះគន់ក្នុងន័យស្ថាបនាទាំងឡាយដោយក្តីរីករាយ

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ឡើន ស្រីនិច** និង **រេត រតនា** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី ២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យើងខ្ញុំទាំងពីរនាក់សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

លោកឪពុក **ពិន ម៉ៅ** អ្នកម្ដាយ **មេង ទូច** លោកឪពុក **ស៊ន សារីន** អ្នកម្ដាយ **ទឹម សុជាតា** ដែលលោកទាំងបួនបានផ្ដល់កំណើត ព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សា ថ្នាក់ថ្នមយ៉ាងយកចិត្តទុកដាក់ដល់រូបយើងខ្ញុំទាំងពីរនាក់តាំងពីពេលចាប់កំណើត រហូតមកដល់បច្ចុប្បន្ននេះ ដោយក្ដីស្រឡាញ់ និងមានការអធ្យាស្រ័យប្រោសប្រណីដោយព្រហ្មវិហារធម៌ ផ្ដល់ការអប់រំ ទូន្មានប្រៀនប្រដៅចំណុចល្អៗជាច្រើនបំផុតនៅក្នុងជីវិតរបស់យើងខ្ញុំទាំងពីរនាក់។ លើសពីនេះទៅទៀត លោកទាំងបួនតែងតែជួយលើកទឹកចិត្ត ជ្រោមជ្រែងគ្រប់សព្វបែបយ៉ាង ទាំងគំនិត ប្រាជ្ញាស្មារតី និងសម្ភារៈប្រើប្រាស់ក្នុងការផ្គត់ផ្គង់ដល់ការសិក្សារៀនសូត្ររបស់យើងខ្ញុំទាំងពីរនាក់ចាប់តាំងពីបឋមសិក្សារហូតដល់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនាពេលនេះ ដោយពុំមានការប្រើប្រាស់ពាក្យពេចន៍មិន សមរម្យ ឬមានការត្អូញត្អែរពីភាពនឿយហត់លំបាកបន្តិចសោះឡើយ។ ទាំងអស់នេះហើយគឺជាគុណដ៏ធំធេងដែលកូនមិនអាចតបស្នងសងគុណលោកទាំងបួនបាននោះទេ ហើយលោកទាំងបួនក៏មិនចង់បានការតបស្នងសងគុណណាក្រៅពីចង់ឃើញកូនក្លាយទៅជាកូនល្អ សិស្សល្អ ពលរដ្ឋល្អនៅក្នុងសង្គម និងទទួលបានភាពជោគជ័យក្នុងជីវិតនាពេលអនាគត។

**ឯកឧត្ដម សាកលវិទ្យាធិកា សាកលវិទ្យាធិការរង និងគណៈគ្រប់គ្រង ព្រមទាំង លោក លោកស្រី សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្តក្នុងកិច្ចការដឹកនាំ គ្រប់គ្រង ជាពិសេសគឺការបង្ហាត់បង្រៀន និងផ្ដល់ចំណេះដឹង ក៏ដូចជាបទពិសោធន៍ល្អៗជាច្រើនដែលជាទ្រព្យធនដ៏ល្អប្រសើរ និងមានតម្លៃឥតអាចគណនាបានសម្រាប់និស្សិតគ្រប់ៗរូប ដើម្បីជាស្ពានចម្លងទៅថ្ងៃអនាគតដ៏ភ្លឺស្វាងត្រចេះត្រចង់។

**លោកស្រី ឃឹម ម៉ាណែត** ដែលជាគ្រូដឹកនាំការស្រាវជ្រាវ និងរៀបចំរបាយការណ៍សារណានេះឱ្យចេញជារូបរាងឡើង ជាពិសេសទៀតនោះគឺការខិតខំប្រឹងប្រែង ជួយពន្យល់ណែនាំយ៉ាងយកចិត្តទុកដាក់ ព្រមទាំងបានជួយចង្អុលបង្ហាញនូវចំណុចខ្វះខាត ពិនិត្យមើលចំណុចខ្វះចន្លោះដើម្បីឱ្យមានការកែសម្រួលកាន់តែល្អប្រសើរដល់រូបយើងខ្ញុំ។

ជាទីបញ្ចប់សូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ អ្នកស្រីសាស្ត្រាចារ្យ គ្រូបង្រៀនគ្រប់មុខវិជ្ជា ដែលបានផ្តល់ការអប់រំ ដំបូន្មាន ចំណេះដឹងគំនិតល្អៗ ដល់រូបយើងខ្ញុំតាំងពីថ្នាក់បឋមសិក្សារហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ព្រមទាំងមិត្តភក្តិទាំងអស់គ្នាដែលបានផ្តល់មតិល្អៗជួយចែករំលែកចំណេះដឹងបទពិសោធន៍ថ្មីៗ និងលើកទឹកចិត្តដល់រូបយើងខ្ញុំទាំងពីរនាក់កន្លងមកនេះ។

# មាតិកា

**អារម្ភកថា**

**សេចក្តីថ្លែងអំណរគុណ**

**សេចក្តីផ្តើម**..........................................................................................................១

## ជំពូកទី១

## សញ្ញាណទូទៅនៃសន្តតិកម្ម

**១.១ អត្ថន័យ និងលក្ខណៈនៃមតកសាសន៍**..........................................................................២

១.១.១. និយមន័យ..........................................................................................................២

១.១.២. លក្ខណៈនៃមតកសាសន៍..........................................................................................២

**១.២. ការចាប់ផ្តើមធ្វើមតកសាសន៍**..........................................................................................៣

**១.៣. សមត្ថភាពក្នុងការធ្វើមតកសាសន៍**..........................................................................................៤

១.៣.១. ម្ចាស់បណ្តាំត្រូវមានសមត្ថភាពធ្វើមតកសាសន៍..........................................................................................៤

១.៣.២.ជាគោលការណ៍ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើមតកសាសន៍បាន..........................................................................................៤

១.៣.៣. បន្ទុកភស្តុតាង..........................................................................................................៤

**១.៤. វិធីក្នុងការធ្វើមតកសាសន៍**..........................................................................................៥

១.៤.១. គោលគំនិត..........................................................................................................៥

១.៤.២. ប្រភេទនៃទម្រង់មតកសាសន៍..........................................................................................៥

**១.៥. ចំណុចដែលត្រូវសរសេរនៅក្នុងមតកសាសន៍**..........................................................................................៩

**១.៦.ការលុបចោលមតកសាសន៍**..........................................................................................៩

១.៦.១ការលុបចោលដោយមតកសាសន៍..........................................................................................១០

១.៦.២. ការលុបចោលដែលច្បាប់បានកំណត់..........................................................................................១០

១.៦.៣. ការលុបចោលកិច្ចសន្យានៃមតកសាសន៍ដោយផ្អែកលើវិការៈក្នុងការបង្ហាញឆន្ទៈ..........................................................................................១១

**១.៧. អច្ច័យទាន**..........................................................................................................១២

១.៧.១. លក្ខណៈទូទៅ..........................................................................................................១២

១.៧.២. ប្រភេទនៃអច្ច័យទាន..........................................................................................................១២

១.៧.៣. អច្ច័យលាភី..........................................................................................................១២

១.៧.៤. ការបោះបង់ ឬការទទួលស្គាល់នូវអច្ច័យទាន ............ ១៤
១.៧.៥. អច្ច័យទានដែលភ្ជាប់បន្ទុក............ ១៤
**១.៨. ការអនុវត្តមតកសាសន៍** ............ ១៤
១.៨.១. អត្ថន័យនៃការអនុវត្តមតកសាន៍ ............ ១៤
១.៨.២. ការពិនិត្យបញ្ជាក់ និងការបើកលិខិតមតកសាន៍ ............ ១៥
១.៨.៣. គោលបំណងនៃការពិនិត្យបញ្ជាក់មតកសាសន៍ ............ ១៥
១.៨.៤. នីតិវិធីសំខាន់ដែលត្រូវគោរពនៅពេលឡើងតុលាការ ............ ១៥
១.៨.៥. នីតិវិធីពិនិត្យបញ្ជាក់នៅតុលាការ ............១៦
១.៨.៦. ការកោះហៅសន្តតិជន ............ ១៦
១.៨.៧. អ្នកប្រតិបត្តិមតកសាសន៍ ............ ១៦
១.៨.៨.ការដាក់កម្រិតលើការទទួលស្គាល់ជនប្រតិបត្តិមតកសាសន៍ ............១៨
១.៨.៩. មុខងារអ្នកប្រតិបត្តិមតកសាសន៍ ............១៨

## ជំពូកទី២

## ការបែងចែងមត៌ក

**២.១. ការកំណត់ចំណែកមត៌ក** ............ ២០
**២.២.ករណីមានភាពចាំបាច់ក្នុងការបែងចែងមត៌ក** ............ ២០
**២.៣. ការគ្រប់គ្រងមត៌កមុននឹងធ្វើការបែងចែក** ............ ២១
**២.៤. របៀបនៃការបែងចែកមត៌ក** ............ ២១
២.៤.១. ការបញ្ជាក់អំពីសន្តតិជន ............ ២២
២.៤.២. កម្មវត្ថុនៃសន្តតិកម្ម ............ ២៣
២.៤.៣. កាតព្វកិច្ចនៃសន្តតិកម្ម ............ ២៤
**២.៥. ការអនុវត្តជាក់ស្តែងនៃការបែងចែងមត៌ក** ............ ២៤
២.៥.១. លំហូនៃការទទួលរឿងក្តីសន្តតិកម្ម ............ ២៤
២.៥.២. របៀបសរសេរពាក្យសុំបែងចែងមត៌ក ............ ២៦
២.៥.៣. ឯកសារភ្ជាប់ ............ ២៦
**២.៦. អវត្តមាននៃសន្តតិជន** ............ ២៧
២.៦.១ មរណភាពនៃមតកជន ............ ២៧

២.៦.២ ការតែងតាំងអ្នកគ្រប់គ្រង ..... ២៨
២.៦.៣. ការជូនដំណឹងលើកទី១ ដោយតុលាការ ..... ២៨
២.៦.៤ ការជូនដំណឹងលើកទី ២ ដោយអ្នកគ្រប់គ្រង ..... ២៨
២.៦.៥ ការដកចេញពីការជម្រះ ..... ២៨
២.៦.៦ ការជម្រះ ..... ២៩
២.៦.៧ ការជូនដំណឹងលើកទី៣ ដោយតុលាការ ..... ២៩
២.៦.៨ ការរំលត់សិទ្ធិ ..... ២៩
២.៦.៩ ការបែងចែងមត៌កទៅឲ្យជនដែលមាននិស្ស័យពិសេស ..... ៣០
**២.៧. ភាគបម្រុង** ..... ៣០
២.៧.១ គោលបំណង ..... ៣០
២.៧.២ អ្នកដែលមានសិទ្ធិលើភាគបម្រុង និងចំណែកនៃភាគបម្រុង ..... ៣១
២.៧.៣ ការគណនាចំណែកនៃភាគបម្រុង ..... ៣២
២.៧.៤ ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ..... ៣២
២.៧.៥ ការរំលត់សិទ្ធិទាមទារដើម្បីឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ..... ៣៤

## ជំពូកទី៣

## ការយល់ព្រម ការបោះបង់ និងការយល់ព្រមដោយមានកម្រិត

**៣.១. លក្ខណៈទូទៅ** ..... ៣៥
**៣.២. ការយល់ព្រមទទួលសន្តតិកម្មទាំងស្រុង** ..... ៣៥
**៣.៣. ការបោះបង់សន្តតិកម្ម** ..... ៣៦
៣.៣.១ គោលបំណង ..... ៣៦
៣.៣.២ របៀបនៃការបោះបង់សន្តតិកម្ម ..... ៣៦
៣.៣.៣ រយៈពេលដាក់ពាក្យសុំ ..... ៣៧
៣.៣.៤ អានុភាព ..... ៣៩
៣.៣.៥ ការបោះបង់ និងការគ្រប់គ្រងមត៌ក ..... ៤០
**៣.៤. ការយល់ព្រមទទួលសន្តតិកម្មដោយមានកម្រិត** ..... ៤១
៣.៤.១. គោលបំណង ..... ៤១
៣.៤.២. វិធីក្នុងការយល់ព្រមដោយមានកម្រិត ..... ៤១

**៣.៥.អានុភាព** ....................................................................................................................៤១
៣.៥.១. ដីការសម្រេច ....................................................................................................................៤១
៣.៥.២. អានុភាពនៃការយល់ព្រមដោយមានលកម្រិត ..................................................................................៤២
**សេចក្តីសន្និដ្ឋាន** ....................................................................................................................៤៣
**អនុសាសន៍** .................................................................................................................... ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ក្នុងជីវិតរស់នៅប្រចាំថ្ងៃ តែងតែមាននូវចំណោទបញ្ហាកើតឡើង។ នីតិរដ្ឋប្បវេណី ជានីតិដែលទាក់ទងនឹងសិទ្ធិឯកជន បង្កើតឡើងដើម្បីដោះស្រាយបញ្ហាមួយចំនួនដែលបានកើតឡើងក្នុងជីវភាពប្រចាំថ្ងៃ។ ការលើកឡើងពីបញ្ហាស្តីពីមរតក គឺជាផ្នែកមួយនៃក្រមរដ្ឋប្បវេណី ដែលជាទូទៅគឺជាបញ្ហាមួយផ្នែកនៃនីតិគ្រួសារ។ បញ្ហាទាក់ទងនឹងមរតកគឺជិតស្និទ្ធណាស់ទាក់ទងនឹងវិសាលភាពនៃជីវិតមនុស្ស ព្រោះមនុស្សគ្រប់រូបនឹងប្រាកដជាជួបប្រទះនឹងការស្លាប់។ ហើយការមានទ្រព្យសម្បត្តិគឺជាគុណប្រយោជន៍ដ៏មានតម្លៃក្នុងជីវិត ប៉ុន្តែមនុស្សយើងម្នាក់ៗមិនមានជីវិតអមតៈអាចគ្រប់គ្រងទ្រព្យសម្បត្តិទាំងនោះបានទេ។ ព្រោះជីវិតមនុស្សមានដែនកំណត់ដែលអាចរស់នៅបាន។

ហេតុនេះ ក្នុងស្ថានភាពមួយចំនួន ការរៀបចំអ្នកទទួលមត៌ក និងការរៀបចំបណ្តាំ គួរតែចាប់ផ្តើមពិចារណា ដូចជា ការឈានដល់ភាពចាស់ជរា ឬសហព័ទ្ធ(ប្តីឬប្រពន្ធ) នៅសល់តែម្នាក់ឯង។ លើសពីនេះការរៀបចំលិខិតបណ្តាំ នឹងធ្វើឲ្យមតកជននៅតែជាម្ចាស់កម្មសិទ្ធិលើទ្រព្យរបស់ខ្លួន ដែលអាចជៀសវាងបាននូវហានិភ័យទាំងឡាយកើតឡើងពេលកំពុងមានជីវិតរស់នៅ ហើយវាក៏អាចជួយការពារវិវាទ ឬជម្លោះពីក្នុងចំណោមសន្តតិជនដោយប្រការណាមួយពីបញ្ហាទទួលបានទ្រព្យសម្បត្តិតិចឬច្រើននោះដែរ ។ យ៉ាងណាមិញនៅក្នុងប្រទេសកម្ពុជាយើងទទួលយកការធ្វើ សន្តតិកម្មដោយឈរលើគោលការទទួលបន្តដោយស្វ័យប្រវត្តិវិញមូលហេតុដោយសារតែ ប្រជាជនជម្មតាភាគច្រើនគ្មានទ្រព្យសម្បត្តិសន្តតិកម្មច្រើនសម្រាប់ធ្វើការជម្រះបញ្ជីនោះទេ។

នៅក្នុងក្រមរដ្ឋប្បវេណី ២០០៧ ក៏បានចែកសន្តតិកម្មជាពីរប្រភេទ គឺ សន្តតិកម្មតាមច្បាប់ និង សន្តតិកម្មតាមបណ្តាំ។ **សន្តតិកម្មតាមច្បាប់** គឺធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ២០០៧ ចំណែកឯសន្តតិកម្មដែលផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា **សន្តតិកម្មតាមមតកសាសន៍** ។ប្រធានបទនេះមានគោលបំណង ចូលរួមចំណែកក្នុងការសិក្សាស្វែងយល់របស់និស្សិតច្បាប់អំពីការធ្វើសន្តតិកម្មតាមមតកសាសន៍ ឱ្យយល់កាន់តែច្បាស់ និងស៊ីជម្រៅមួយកម្រិតទៀត។ ហេតុនេះហើយទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទ **សន្តតិកម្មជាមតកសាសន៍** ជាប្រធានបទសម្រាប់ការស្រាវជ្រាវបញ្ចប់បរិញ្ញាបត្រនីតិសាស្ត្រ។ ទើបនាំឲ្យមានសំណួរមួយចំនួនលើកឡើងមកថា តើសន្តតិកម្មតាមមតកសាសន៍គឺជាអ្វី? ហើយសន្តតិកម្មតាមមតកសាសន៍បានបែងចែកជាប៉ុន្មានទម្រង់? ដើម្បីឆ្លើយតមទៅនឹងសំណួរទាំងអម្បាលម៉ានខាងលើ ជាដំបូងនឹងធ្វើការសិក្សាពី សញ្ញាណទូទៅនៃសន្តតិកម្ម (**ជំពូកទី១**) និងសិក្សាទៅលើ ការបែងចែកមត៌ក(**ជំពូកទី២**)និងការយល់ព្រមទាំងស្រុងការបោះបង់និងការយល់ព្រមដោយមានកម្រិត(**ជំពូកទី៣**)។

# ជំពូកទី១

# សញ្ញាណទូទៅនៃសន្តតិកម្ម

## ១.១. អត្ថន័យ និងលក្ខណៈនៃមតកសាសន៍

### ១.១.១ និយមន័យ

សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនឱ្យសន្តតិជនម្នាក់ ឬច្រើននាក់ តាមឆន្ទៈ ឬតាមច្បាប់។[1]

មតកសាសន៍ គឺជាការបង្ហាញឆន្ទៈជាឯកតោភាគីមួយរបស់ម្ចាស់បណ្តាំដែលខ្លួនមានការព្រួយបារម្ភពីបញ្ហាពិសេសដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់ខ្លួន ឬ ឋានៈរបស់បុគ្គលណាម្នាក់ដើម្បីបង្កើតនៅអានុភាពមួយនៅពេលដែលខ្លួនទទួលមរណភាព ហើយមតកសាសន៍នេះត្រូវបានបង្កើតឡើងដោយផ្អែកលើទម្រង់ជាក់លាក់ណាមួយ។[2]

### ១.១.២. លក្ខណៈនៃមតកសាសន៍

#### ក. សកម្មភាពឯកតោភាគីតាមច្បាប់

មតកសាសន៍ គឺជាសកម្មភាពឯកតោភាគីដោយមិនចាំបាច់មានការទទួល ឬ យល់ព្រមពីភាគីម្ខាងទៀតទេ។

#### ខ. អានុភាពនៃមតកសាសន៍កើតមាននៅពេលម្ចាស់បណ្តាំទទួលមរណភាព

នៅពេលដែលម្ចាស់បណ្តាំនៅរស់មតកសាសន៍ពុំមានអានុភាពនោះទេ ដូច្នេះហើយម្ចាស់បណ្តាំមានសិទ្ធិសេរីភាពក្នុងការលុបចោលក្នុងការបង្ហាញឆន្ទៈតាមរយៈមតកសាសន៍នៅពេលណាក៏បានដែរ។

#### គ. មតកសាសន៍គឺជាសកម្មភាពមួយដែលត្រូវធ្វើឡើងតាមរយៈទម្រង់

ដើម្បីធ្វើឲ្យម្ចាស់បណ្តាំបង្ហាញឆន្ទៈដោយមានការពិចារណាហ្មត់ចត់ ហើយដើម្បីការពារកុំឲ្យមានក្លែងបន្លំ ឬកែប្រែមតកសាសន៍ វាចាំបាច់ណាស់ក្នុងការធ្វើមតកសាសន៍ទៅតាមទម្រង់ដែលបានកំណត់ជាក់លាក់ ។ ប្រសិនបើមតកសាសន៍មិនអនុឡោមទៅតាមទ្រង់នៃក្រមរដ្ឋប្បវេណីនោះត្រូវចាត់ទុកជាមោឃៈ។[3]

#### ឃ. ចំណុចផ្សេងៗដែលអាចធ្វើមតកសាសន៍ ត្រូវបានកំណត់ដោយច្បាប់

វាមានសារៈសំខាន់ណាស់ ក្នុងការកំណត់ចំណុចដែលអាចធ្វើមតកសាសន៍ ដោយសារតែមតកសាសន៍ត្រូវបានបង្កើតឡើងដោយមិនមានការព្រមព្រៀងពីភាគីពាក់ព័ន្ធឡើយ។ ដូច្នេះហើយចំណុចដែលត្រូវ

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី លេខរៀង ១៤៣ ។

[2] ដដែល, មាត្រា ១១៩៤, ១១៨៨ ។

[3] ដដែល, មាត្រា ១១៧០ ។

កំណត់ក្នុងមតកសាសន៍ត្រូវបានដាក់កម្រិតដោយច្បាប់។ ក្នុងករណីមួយចំនួន ម្ចាស់បណ្តាំបានសរសេររៀបរាប់ចំណុចខ្លះដែលមិនមានកំណត់នៅក្នុងច្បាប់នោះទេមានដូចជា "**សន្តតិជនត្រូវមានការពិភាក្សាគ្នាដោយស្មោះត្រង់**" ឬ "**សន្តតិជនត្រូវរក្សាទំនាក់ទំនងជាមួយគ្នាជារៀងរហូត**" ជាអាទិ៍ ។ ចំណុចទាំងអស់នោះគ្មានអានុភាពតាមផ្លូវច្បាប់ទេបើទោះបីជាសន្តតិជនត្រូវគោរពតាមក៏ដោយ។[4]

**ខ. ការបង្កើតមតកសាសន៍មានភាពផ្តាច់មុខ និងជាសកម្មភាពផ្ទាល់ខ្លួនរបស់ម្ចាស់បណ្តាំ**

មតកសាសន៍ ត្រូវបានទទួលស្គាល់អានុភាពផ្លូវច្បាប់ដោយមានការគោរពនូវឆន្ទៈពិតនិងចុងក្រោយរបស់ម្ចាស់បណ្តាំ។ ដូច្នេះហើយ ការបង្កើតមតកសាសន៍មិនអាចធ្វើបានដោយភ្នាក់ងាបានឡើយ។ ទោះបីជាជននៅក្រោមអាណាព្យាបាលទូទៅ ដោយមិនចាំបាច់មានការព្រមព្រៀងពីនរណាម្នាក់។ ក្រៅពីនេះអ្នកតំណាងដែលច្បាប់បានកំណត់ដូចជាអាណាព្យាបាល ឬ ឪពុកម្តាយមិនអាចធ្វើមតកសាសន៍ជំនួសឲ្យជននៅក្រោមអាណាព្យាបាល ឬកូនជាអនីតិជនបានទេ។[5]

## ១.២. ការចាប់ផ្តើមធ្វើមតកសាសន៍

សន្តតិកម្មត្រូវបានចាប់ផ្តើមឡើងដោយមរណភាពរបស់មតកជន គឺមិនទទួលស្គាល់សន្តតិកម្មពេលនៅរស់ទេ។ ប៉ុន្តែក្នុងករណីដែលបុគ្គលណាម្នាក់ទទួលប្រកាសអំពីការបាត់ខ្លួនត្រូវចាត់ទុកថា អ្នកនោះទទួលមរណភាពដោយផ្អែកលើមាត្រា៤៣នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដូច្នេះ សន្តតិកម្មត្រូវបានចាប់ផ្តើម។ របបសន្តតិកម្មនៅក្នុងពិភពលោកនេះអាចបែងចែងជា ២ ប្រភេទបាន គឺជាគោលការណ៍បន្តដោយស្វ័យប្រវត្តិ និងគោលការណ៍ជម្រះបញ្ជី។

- ✓ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ គឺជាគោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិនិងករណីកិច្ចទាំងអស់របស់មតកជន។ ដូច្នេះសន្តតិជនបានទទួលបន្តនូវឋានៈរបស់មតកជនតែម្តង (ក្នុងករណីសហសន្តតិជន ត្រូវធ្វើការបែងចែក)។
- ✓ គោលការណ៍ជម្រះបញ្ជី គឺត្រូវជម្រះបញ្ជីទាំងអស់នូវសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់មតកជន ពេលដែលសន្តតិកម្មកើតមានឡើងហើយសន្តតិជននឹងស្នងទ្រព្យនោះ ក្នុងករណី ដែលមានទ្រព្យសកម្មតែប៉ុណ្ណោះហើយក្នុងករណីដែលមានកាតព្វកិច្ចធ្ងន់ធ្ងរហួសហេតុ ត្រូវប្រកាសក្ស័យធននៃមត៌កនោះ ដើម្បីកុំឲ្យសន្តតិជនទទួលបន្ទុកកាតព្វកិច្ចនោះ។

---

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៨៧។

[5] ដដែល, មាត្រា ១១៦៨, ១១៦៩។

## ១.៣.សមត្ថភាពក្នុងការធ្វើមតកសាសន៍

មតកសាសន៍ គឺជារបបមួយដែលបង្កើតឡើង ដើម្បីគោរពឆន្ទៈពិតរបស់ម្ចាស់បណ្តាំ។

### ១.៣.១. ម្ចាស់បណ្តាំត្រូវមានសមត្ថភាពធ្វើមតកសាសន៍

ម្ចាស់បណ្តាំ ត្រូវមានសមត្ថភាពធ្វើតកសាសន៍នៅពេលធ្វើមតកសាសន៍នោះ ដូច្នេះ នៅពេលធ្វើមតកសាសន៍ ប្រសិនម្ចាស់បណ្តាំខ្វះសមត្ថភាដោយសារការស្រវឹង ឬមានជំងឺខួរក្បាលជាដើមនោះមតកសាសន៍នោះត្រូវចាត់ទុកជាមោឃៈ។ ម្យ៉ាងវិញទៀត ម្ចាស់បណ្តាំត្រូវមានសមត្ថភាពនៅពេលធ្វើមតកសាសន៍តែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ ទោះបីជាម្ចាស់បណ្តាំបានបាត់បង់សមត្ថភាពនេះនៅពេលក្រោយធ្វើមតកសាសន៍ក៏ដោយក៏មតកសាសន៍មានសុពលភាពដែរ។[6]

### ១.៣.២. ជាគោលការណ៍ ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើមតកសាសន៍បាន

សូម្បីតែជននៅក្រោមអាណាព្យាបាលទូទៅ ក៏អាចធ្វើមតកសាសន៍ដោយខ្លួនឯងបានដែរដោយមិនចាំបាច់មានការយល់ព្រមពីអាណាព្យាបាល ហើយមតកសាសន៍ទាំងនោះមិនអាចលុបចោលបានទេ។ អ្វីដែលស្មុកស្មាញនោះគឺ ករណីរបស់ជននៅក្រោមអាណាព្យាបាលទូទៅ តែងតែខ្វះសមត្ថភាពក្នុងការធ្វើមតកសាសន៍ ប៉ុន្តែជននៅក្រោមអាណាព្យាបាលទូទៅក៏អាចមានសមត្ថភាពធ្វើមកតសាសន៍នៅពេលខ្លះដែរ ដោយសារតែស្ថានភាពខួរក្បាលរបស់ជននោះ អាចនឹងប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ។ ដូច្នេះ ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើ មតកសាសន៍បាននៅពេលដែលជននោះជាសះស្បើយមួយរយៈឡើងវិញជាបណ្តោះអាសន្ននូវសមត្ថភាពតែប៉ុណ្ណោះ។ ក្រោយការធ្វើមរតកសាសន៍ ជននោះអាចបាត់បង់សមត្ថភាពនៅពេលឆាប់ៗម្តងទៀត ប៉ុន្តែវាមិនមានផលប៉ះពាល់ដល់សុពលភាពមតកសាសាន៍នោះទេ។ នៅក្នុងការបង្ហាញភស្តុតាងអំពីការជាសះស្បើយមួយរយៈនូវសមត្ថភាពបណ្តោះអាសន្ននោះ នៅពេលធ្វើមតកសាសន៍គួតែមានមានវត្តមានរបស់វេជ្ជបណ្ឌិត ២ ឬ ច្រើននាក់ ហើយវិជ្ជបណ្ឌិតត្រូវមានបញ្ជាក់បន្ថែមលើមតកសាសន៍នោះ។[7]

### ១.៣.៣. បន្ទុកភស្តុតាង

ក្រោយម្ចាស់បណ្តាំទទួលមរណភាព បុគ្គលដែលជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍អាចមានការឈ្លោះប្រកែកគ្នាលើបញ្ហាសុពលភាពលើមតកសាសន៍ ដោយផ្អែកលើហេតុផលថា ម្ចាស់បណ្តាំខ្វះសមត្ថភាពក្នុងការធ្វើមតកសាសន៍។ ក្នុងករណីដូចខាងលើនេះ ភាគីដែលអះអាងដូចនេះត្រូវបញ្ជាក់ភស្តុតាងទៅលើហេតុផលនៃកង្វះសមត្ថភាពនោះ។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើម្ចាស់បណ្តាំស្ថិតនៅក្រោមអាណាព្យាបាលទូទៅពេលធ្វើមតកសាសន៍ បុគ្គលដែលអាចអះអាងពីកង្វះសមត្ថភាពរបស់ម្ចាស់បណ្តាំត្រូវធ្វើការបញ្ជាក់ភស្តុតាង។

---

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៩។

[7] ដដែល, មាត្រា ១១៦៨។

## ១.៤. វិធីក្នុងការធ្វើមតកសាសន៍

### ១.៤.១. គោលគំនិត

មតកសាសន៍ដែលពុំបានធ្វើតាមទម្រង់ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីត្រូវចាត់ទុកជាមោឃៈ។ ពេលដែលម្ចាស់បណ្តាំបានទទួលមរណភាពមតកសាសន៍នឹងមានអានុភាព ដូច្នេះមិនមានឱកាសសម្រាប់សួរពីឆន្ទៈពិត ឬប្រឆាំងចំពោះម្ចាស់បណ្តាំបាននោះទេ។ មានករណីខ្លះតតិយជនអាចបង្កើតមតកសាសន៍ក្លែងក្លាយបានផងដែរ ឬខ្លឹមសារពិតរបស់មតកសាសន៍ត្រូវបានតតិយជននោះកែប្រែផងដែរ។[8]

ដូច្នេះហើយ ដើម្បីធ្វើឲ្យឆន្ទៈម្ចាស់បណ្តាំមានភាពច្បាស់លាស់ និងការពារមិនឲ្យមានការក្លែងបន្លំ ឬកែប្រែមតកសាសន៍ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងយ៉ាងលំអិតអំពីទម្រង់មតកសាសន៍ ហើយប្រសិនបើមិនអនុវត្តតាមទម្រង់នោះទេនឹងត្រូវចាត់ទុកជាមោឃៈ។

### ១.៤.២. ប្រភេទនៃទម្រង់មតសាសន៍

#### ១.៤.២.១ ទម្រង់ធម្មតា

**ក. មតកសាសាន៍ដោយលិខិតយថាភូត**

ម្ចាស់បណ្តាំត្រូវពន្យល់ផ្ទាល់មាត់អំពីឆន្ទៈ នៃមតកសាសន៍ចំពោះសារការីហើយត្រូវមានវត្តមានសាក្សីយ៉ាងតិចពីរនាក់ ហើយសារការីត្រូវសរសេរអំពីខ្លឹមសារនៃមតកសាសន៍នោះជាលាយលណ៍អក្សរ និងត្រូវអានឲ្យម្ចាស់បណ្តាំស្តាប់បន្ទាប់មកម្ចាស់បណ្តាំ សារការី និងសាក្សីត្រូវចុះហត្ថលេខាទៅលើលិខិតនោះ។[9]

ប្រសិនបើម្ចាស់បណ្តាំមិនអាចនិយាយបាន គាត់ត្រូវប្រើភាសាសញ្ញា (ប្រើដៃជាសញ្ញា) ដោយមានអ្នកបកប្រែ ឬត្រូវសរសេរទៅកាន់សារការី (មាត្រា ១១៧៩ កថាខណ្ឌទី ១ នៃក្រម រដ្ឋប្បវេណី)។ ប្រសិនបើម្ចាស់បណ្តាំមិនអាចស្តាប់បានគេត្រូវ ប្រើភាសាសញ្ញាដោយមានអ្នកបកប្រែជំនួស ប្រាប់សារការីនូវចំណុចដែលសរសេរនោះ (មាត្រា ១១៧៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលអនុលោមទៅតាមមាត្រា ១១៧៩ សារការីត្រូវសរសេរការពិតនៅក្នុងលិខិតយថាភូត (មាត្រា ១១៧៩ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី)។

**គុណប្រយោជន៍**

- ✓ ខ្លឹមសារនៃមតកសាសន៍មានភាពច្បាស់លាស់ ព្រោះតែសារការីសរសេរនៅលើមតកសាសន៍នោះ
- ✓ មតកសាសន៍មានភាពជាផ្លូវការ ដោយសារសារការីជួយបង្កើតមតកសាសន៍នោះ
- ✓ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍មានភាពជឿជាក់ និងទុកចិត្តលើមតកសាសន៍ព្រោះសារការីចូលរួមនៅក្នុងនីតិវិធីនៃការធ្វើមតកសាសន៍ ហើយជាអ្នករក្សាទុកមតកសាសន៍នោះ

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧០។

[9] ដដែល, មាត្រា ១១៧៣។

- ✓ អ្នកមិនចេះអក្សរក៏អាចធ្វើមតកសាសន៍បានដែរ ពីព្រោះសារការីជាអ្នកសរសេរខ្លឹមសារនៃមតកសាសន៍នោះ
- ✓ មតកសាសន៍មិនត្រូវបានក្លែងបន្លំ ឬផ្លាស់ប្តូរ ឬបាត់បង់ ពីព្រោះសារការីជាអ្នករក្សាទុកមតកសាសន៍
- ✓ មុនពេលអនុវត្តន៍មតកសាសន៍មិនចាំបាច់មាននីតិវិធីពិនិត្យបញ្ជាក់ទេ។

**គុណវិបត្ត**

- ✓ ម្ចាស់បណ្តាំត្រូវស្នើសុំឲ្យសារការីជួយ
- ✓ សារការី និងសាក្សីដឹងខ្លឹមសារក្នុងមតកសាសន៍។

**ខ. មតកសាសន៍ដោយលិខិតឯកជន**

នេះគឺជាវិធីធ្វើមតកសាសន៍ ដែលម្ចាស់បណ្តាំត្រូវសរសេរអំពីខ្លឹមសារទាំងមូលនៃមតកសាសន៍ ហើយមានចុះថ្ងៃខែឆ្នាំ ព្រមទាំងចុះហត្ថលេខាដោយខ្លួនឯង។ ករណីមានការបន្ថែម ឬការលុបចោល ឬកែប្រែផ្សេងទៀតម្ចាស់បណ្តាំត្រូវសរសេរបន្ថែមនូវហេតុនេះព្រមទាំងចុះហត្ថលេខាផង។[10]

**គុណប្រយោជន៍**

- ✓ ម្ចាស់បណ្តាំអាចធ្វើតែឯងបានដោយមិនចាំបាច់មានការអន្តរាគមន៍ពីសារការីឬវត្តមានរបស់សាក្សី
- ✓ មិនអស់សោហ៊ុយ
- ✓ អាចរក្សាការសម្ងាត់នៃខ្លឹមសាររបស់មតកសាសន៍

**គុណវិបត្តិ**

- ✓ មតកសាសន៍អាចត្រូវមោឃៈភាពដោយសារកំហុសនៃទម្រង់ ដោយសារតែមានការទាមទារឲ្យគោរពទម្រង់តឹងរឹងហើយសារការីមិនបានចូលរួមជួយ
- ✓ ប្រសិនបើ ម្ចាស់បណ្តាំមិនចេះអក្សរទេ គាត់មិនអាចធ្វើមតកសាសន៍បានទេព្រោះខ្លឹមសារនៃមតកសាសន៍មិនអាចសរសេរដោយអ្នកផ្សេងបាននោះទេ ហើយម្ចាស់បណ្តាំក៏មិនត្រូវបានអនុញ្ញាតឲ្យប្រើ
- ✓ អាចបាត់ ឬអាចមានការធ្វើក្លែងក្លាយ ឬក្លែងបន្លំ ព្រោះម្ចាស់បណ្តាំជាអ្នករក្សាមតកសាសន៍
- ✓ ចាំបាច់ត្រូវមានការពិនិត្យបញ្ជាក់ដើម្បីអនុវត្តមតកសាសន៍។

**គ. មតកសាសន៍ដោយលិខិតសម្ងាត់**

មតកសាសន៍ដោយលិខិតសម្ងាត់ ជាវិធីដែលសារការីបញ្ជាក់ថាមានមតកសាសន៍ ប៉ុន្តែអ្វីៗក្នុងមតកសាសន៍នោះត្រូវរក្សាការសម្ងាត់។ ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាក្នុងលិខិតដោយខ្លួនឯងផ្ទាល់ ប៉ុន្តែម្ចាស់

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៤។

បណ្ដាំត្រូវសុំឲ្យនណាម្នាក់សរសេរខ្លឹមសារលើមតកសាសន៍ ឬអាចប្រើកុំព្យូទ័របាន។ ម្ចាស់បណ្ដាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ព្រមទាំងសរសេរសញ្ញាលើមាត់ស្រោមនោះ ឲ្យដឹងនៅពេលគេបើកស្រោមហើយត្រូវដាក់នៅចំពោះមុខសារការីម្នាក់ និងសាក្សីពីរនាក់ដោយថ្លែងការថានេះជាមតកសាសន៍ ជាអាទិ៍។ ប្រសិនម្ចាស់បណ្ដាំមិនអាចនិយាយបានគាត់ត្រូវប្រើភាសាសញ្ញា ឬត្រូវសរសេរ។ សារការី ម្ចាស់បណ្ដាំ និងសាក្សី ត្រូវចុះហត្ថលេខាលើលិខិតបិទជិតនោះ។ ម្យ៉ាងទៀតទោះបីមិនស្របនិងលក្ខខ័ណ្ឌនៃមតកសាសន៍ដោយលិខិតសម្ងាត់ក៏ដោយក៏អាចមានសុពលភាពជាលិខិតមតកសាសន៍ជាលិខិតឯកជនដែរ ។[11]

**១.៤.២.២ ទម្រង់ពិសេស**

**ក. មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត**

ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត អាចធ្វើមតកសាសន៍បានតាមវិធីធម្មតា ប៉ុន្តែជននោះគ្មានសមត្ថភាពអាចសរសេរខ្លឹមសារបានដោយខ្លួនឯងទេ ឬគ្មានពេលស្នើសុំឲ្យសារការីជួយបានក្នុងការការពារជនបែបនេះ ក្រមរដ្ឋប្បវេណីកំណត់វិធីពិសេសនៃមតកសាសន៍។[12]

សរុបមកជនដែលកំពុងជួនគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត អាចធ្វើមតកសាសន៍តាមធម្មតាបាន ឬតាមវិធីពិសេសក៏បាន។ ប្រសិនបើគាត់ចង់ប្រើវិធីនេះ គាត់ត្រូវប្រកាសឆន្ទៈមតកសាសន៍យ៉ាងហោចណាស់ប្រកាសឲ្យសាក្សីម្នាក់បានដឹងក្នុងចំណោមបីនាក់។ ប្រសិនម្ចាស់បណ្ដាំមិនអាចនិយាយបាន គាត់ត្រូវប្រើភាសាសញ្ញា ឬត្រូវសរសេរហើយសាក្សីដឹងឮត្រូវសរសេរខ្លឹមសារនៃមតកសាសន៍ បន្ទាប់ពីបានបញ្ជាក់ខ្លឹមសារនៃមតកសាសន៍នោះហើយ សាក្សីម្នាក់ៗត្រូវចុះហត្ថលេខាលើលិខិតនោះ។ ក្នុងអំឡុងពេល ១ ខែដោយគិតចាប់ពីថ្ងៃបានធ្វើមតកសាសន៍នោះត្រូវបញ្ជាក់ពីតុលាការ ហើយក្នុងករណីតុលាការទទួលស្គាល់ថាខ្លឹមសារនោះគឺជាឆន្ទៈពិតរបស់ម្ចាស់បណ្ដាំ ពេលនោះមតកសាសន៍នឹងមានសុពលភាព។

**ខ. មតកសាសន៍របស់ជនត្រូវជាប់ឃុំឃាំង**

តាមច្បាប់ជនដែលត្រូវជាប់ឃុំឃាំងដោយ សាលក្រមតុលាការ ឬដោយបញ្ជារដ្ឋបាលអាចធ្វើមតកសាសន៍តាមវិធីធម្មតាបាន។ ទោះជាយ៉ាងនេះក៏ដោយ ពួកគេមិនអាចធ្វើមតកសាសន៍តាមលិខិតយថាភូត ឬលិខិតសម្ងាត់បានទេ ព្រោះពួកគេមិនអាចរកជំនួយពីសារការីបានឡើយ លើសពីនេះទៀតប្រសិនបើពួកគេមិនចេះអក្សរ ឬមានជម្ងឺមិនអាចសរសេរលិខិតបានពួកគេមិនអាចធ្វើមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនបាននោះទេ។[13] ក្នុងករណីនេះពួកគេគ្មានផ្លូវធ្វើមតកសាសន៍បានឡើយ ដូច្នេះក្រមរដ្ឋប្បវេណីបានផ្ដល់វិធី

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៥។

[12] ដដែល, មាត្រា ១១៧៧។

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៨។

ពិសេសនៃមតកសាសន៍។ នីតិវិធីនេះគឺប្រហាក់ប្រហែលនឹងមតកសាសន៍ដោយលិខិតយថាភូតដែរគឺនគរបាល ឬនាវិកម្ចាស់យន្តហោះជាដើមនឹងដើរតួនាទីជាសារការីដែរ។

**គ. មតកសាសន៍ដែលគ្មានចុះថ្ងៃខែឆ្នាំ**

ជាគោលការណ៍ មតកសាសន៍ដែលធ្វើមិនត្រូវទម្រង់ណាមួយក្នុងក្រមរដ្ឋប្បវេណី ត្រូវចាត់ទុកជាមោឃៈ ប៉ុន្តែ មតកសាសន៍ដែលគ្មានចុះថ្ងៃខែឆ្នាំណាមួយដែលមានខ្លឹមសារផ្ទុយគ្នានឹងត្រូវចាត់ទុកជាមោឃៈទៅតាមកម្រិតដែលមានភាពផ្ទុយគ្នានោះ។ ប្រសិនបើមានមតកសាសន៍ដែលគ្មានចុះថ្ងៃខែឆ្នាំមួយទេ មតកសាសន៍នោះមានសុពលភាពពេញលេញ។ ប្រសិនបើមានមតកសាសន៍ចុះថ្ងៃខែឆ្នាំពីរអានុភាពនឹងត្រូវបានបកស្រាយខាងលើ។[14]

ឧទហរណ៍៖ មានមតកសាសន៍ ២ មតកសាសន៍ A ថាឲ្យដីទៅប្រពន្ធ X និងឲ្យឡានទៅកូន Y ។ ដោយឡែកមតកសាសន៍ B ថា ឲ្យឡានទៅកូន និងដីទៅប្រពន្ធ X។

**ឃ. មតកសាសន៍ទាំងពីរគ្មានចុះថ្ងៃទីខែឆ្នាំ**

ដីត្រូវប្រគល់ទៅឲ្យ X ពីព្រោះដីគ្មានភាពផ្ទុយរវាងមតកសាសន៍ទេនៅចំណុចនេះ។ មួយវិញទៀតមតកសាសន៍ទាំងពីរគ្មានអានុភាពលើចំណុចថាឲ្យឡានទៅ X ឬ Y ពីព្រោះមតកសាសន៍ទាំងពីរមានភាពផ្ទុយគ្នា។ មតកសសន៍ A មានចុះថ្ងៃទីខែឆ្នាំ ប៉ុន្តែមតកសាសន៍ B គ្មានចុះថ្ងៃទីខែឆ្នាំ ដីដែលត្រូវប្រគល់ឲ្យទៅ X ហើយឡានប្រគល់ឲ្យទៅ Y ពីព្រោះមតកសាសន៍ A មានសុពលភាពពេញលេញ។ មតកសាសន៍ទាំងពីរមានចុះថ្ងៃទីខែឆ្នាំ ហើយមតកសាសន៍ A បានធ្វើតាមក្រោយដីត្រូវប្រគល់ឲ្យ X ហើយឡានត្រូវប្រគល់ឲ្យទៅឲ្យ Y ពីព្រោះមតកសាសន៍ A មានសុពលភាព មានចុះថ្ងៃទីខែឆ្នាំ។

**ង. មតកសាសន៍ជនជាតិខ្មែររស់នៅបរទេស**

ជនជាតិខ្មែររស់នៅបរទេសត្រូវធ្វើ មតកសាសន៍ដោយលិខិតផ្ទាល់ខ្លួន។ ប្រសិនបើគាត់ចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬលិខិតសម្ងាត់ គាត់ត្រូវស្នើទៅកុងស៊ុលកម្ពុជានៃប្រទេសដែលគាត់រស់នៅដើរតួនាទីជាសារការី។

## ១.៥. ចំណុចដែលត្រូវសរសេរនៅក្នុងមតកសាសន៍

មានតែចំណុចដែលច្បាប់បានកំណត់ទេដែលអាចសរសេរនៅក្នុងមតកសាសន៍នោះបានម្ចាស់បណ្តាំចង់ធ្វើអ្វីៗក្រៅពីចំណុចដែលបានកំណត់នេះក៏បានដែរ ប៉ុន្តែពុំមានអានុភាពតាមផ្លូវច្បាប់ឡើយ។

[14] ដដែល, មាត្រា ១១៧០។

**ទាក់ទងនឹងសន្តតិកម្ម**[15]

ក.ការផ្ដាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននិងការលុបចោលនូវការផ្ដាច់មត៌កពីសន្តតិជន

ខ. ការកំណត់ចំណែកមត៌ក

គ. ការកំណត់នូវវិធីបែងចែកមត៌ក

ឃ. ការហាមឃាត់នូវការបែងចែងមត៌ក

ង. ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

**ទាក់ទងនឹងការចាត់ចែងទ្រព្យសម្បត្តិ**[16]

ក. អច្ច័យទានសកល អច្ច័យទានពិសេស

ខ. ការវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ

**ទំនាក់នងនឹងឋានៈបុគ្គល**[17]

ក.ការទទួលស្គាល់កូន

ខ. ការកំណត់អ្នកអាណាព្យាបាលរបស់អនីតិជន

## ១.៦. ការលុបចោលមតកសាសន៍

ម្ចាស់បណ្ដាំអាចលុបចោលមតកសាសន៍នៅពេលណាក៏បាន ប៉ុន្តែមតកសាសន៍នឹងមានអានុភាពនៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព។ នៅពេលមានវិវាទម្ចាស់បណ្ដាំបានទទួលមរណភាពបាត់ទៅហើយ ដូច្នេះមិនដឹងទេថាម្ចាស់បណ្ដាំនោះបានលុបចោលមតកសាសន៍នោះឬអត់ទេ។ ដូច្នេះដើម្បីដោះស្រាយវិវាទនេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិនូវវិធានទាក់ទិនទៅនឹងនីតិវិធីនៃការលុបចោលមតកសាសន៍។[18]

### ១.៦.១. ការលុបដោយដោយមតកសាសន៍

ក្នុងករណីដែលបានធ្វើមតកសាសន៍ជាថ្មី ដែលមានខ្លឹមសារថាលុបចោលមតកសាសន៍ដែលបានធ្វើនៅថ្ងៃទី០ ខែ ០ ឆ្នាំ ០ គឺជាការលុបចោលដោយមតកសាសន៍។

---

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥១,១១៥៤,១១៨២,១១៨៣,១១៨៦។

[16] ដដែល, មាត្រា ១១៨៤,១១៣។

[17] ដដែល, មាត្រា ៩៩៧,១០៦៨។

[18] ដដែល, មាត្រា ១១៨៨។

មតកសាសន៍ដែលលុបចោលមតកសាសន៍ មិនត្រូវមានទ្រង់ដូចនឹងមតកសាសន៍ដែលបានលុបចោលនោះទេ។ ឧទាហរណ៍ ម្ចាស់បណ្តាំធ្វើមតកសាសន៍ទី២ ដោយលិខិតផ្ទាល់ខ្លួនដើម្បីធ្វើការលុបចោលមតកសាសន៍ទី១ ដែលធ្វើឡើងដោយលិខិតយថាភូត។[19]

មតកសាសន៍ដែលលុបចោលមតកសាសន៍ទី១ ក៏ជាមតកសាសសន៍ដែរ ដូចច្នេះមកតសាសន៍ទី២ត្រូវអនុវត្តតាមទម្រង់ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។ លើសពីនេះទៅទៀតម្ចាស់បណ្តាំក៏អាចលុបចោលមតកសាសន៍ទី២បានផងដែរ ប្រសិនបើមតកសាសន៍ទី២ ត្រូវបានលុបចោលនឹងត្រូវចាត់ទុកថាគ្មានមតកសាសន៍ទី២តាំងពីដំបូង។ ដូច្នេះមានគំនិតមួយលើកឡើងថាដោយថាចាត់ទុកថាគ្មានមតកសាសន៍ទី២តាំងពីដំបូង យើងត្រូវគិតថាមតកសាសន៍ទី ១ ត្រូវមានអានុភាពតាំងពីដើមរហូតមកដល់ឥឡូវ មានន័យថាមតកសាសន៍ទី១ នឹងមានអានុភាពឡើងវិញ។ ទោះបីជាយ៉ាងណាក៏ដោយយើងត្រូវគិតពីឆន្ទៈពិតរបស់ម្ចាស់បណ្តាំ។ យើងមិនត្រឹមតែគិតពីខ្លឹមសារនៃមតកសាសន៍ទាំងពីរនោះទេ ក៏ប៉ុន្តែក៏ត្រូវគិតពីវិធីនៃការលុបចោលមតកសាសន៍ទី២ (ការលុបចោលដោយមតកសាសន៍ទី៣ ដោយលុបចោលដោយបំផ្លាញមតកសាសន៍ទី២ ការលុបចោលដោយបោះបង់កម្មវត្ថុនៃមតកសាសន៍) និងហេតុនៃការលុបចោលមតកសាសន៍ទី២ ដោយម្ចាស់បណ្តាំ។ ម្យ៉ាងវិញទៀតយើងត្រូវព្យាយាមបកស្រាយថា តើឆន្ទៈពិតរបស់ម្ចាស់បណ្តាំចង់ឲ្យមតកសាន៍ទី១ មានអានុភាពឡើងវិញ ឬយ៉ាងណា។

### ១.៦.២. ការលុបចោលដែលច្បាប់បានកំណត់

ក្នុងករណីដែលម្ចាស់បណ្តាំបានធ្វើសកម្មភាពផ្ទុយនឹងមតកសាសន៍មុន ករណីនេះត្រូវបានចាត់ទុកថាបានលុបចោលដោយស្វ័យប្រវត្តិដោយមតកសាសន៍មុន។ ក្នុងករណីដែលមតកសាសន៍មុន និងមតកសាសន៍ក្រោយមានភាពផ្ទុយគ្នា ទោះជាមិនមានការបង្ហាញឆន្ទៈលុបចោលមតកសាសន៍ក៏ដោយ ក៏ត្រូវចាត់ទុកថាបានលុបចោលនូវភាគផ្ទុយគ្នានោះ ក្នុងមតកសាសន៍ដែរ។

ឧទាហរណ៍៖ មតកសាសន៍មុន ឲ្យ ក ទទួលសន្តតិកម្មនូវទ្រព្យសម្បត្តិទាំងអស់ (ដី ប្រាក់បញ្ញើនៅធនាគារ និងទ្រព្យផ្សេងៗទៀត)។ មតកសាសន៍ក្រោយ ឲ្យ ក ទទួលនូវសន្តតិកម្មដីទាំងអស់ ឲ្យ ខ ទទួលសន្តតិកម្មនូវប្រាក់បញ្ញើនៅធនាគារទាំងអស់ និងឲ្យ គ ទទួលដោយសន្តតិកម្មនូវទ្រព្យសម្បត្តិក្រៅពីនេះ។

ក្នុងករណីនេះត្រូវចាត់ទុកថា "ឲ្យ ក ទទួលដោយសន្តតិកម្មនូវប្រាក់បញ្ញើនៅធនាគារ និងទ្រព្យផ្សេងទៀត" ក្នុងមតកសាសន៍មុនត្រូវបានលុបចោល។

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៩។

**១.៦.២.១. វត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍បើសិនជាម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬបានធ្វើសកម្មភាពផ្សេងទៀត**

វត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ បើសិនជាម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬបានធ្វើសកម្មភាពផ្សេងទៀតត្រូវចាត់ទុកថាស្តីពីភាគដែលផ្ទុយនឹងមតកសាសន៍ត្រូវបានលុបចោល។

ឧទាហរណ៍៖ ម្ចាស់បណ្តាំបានសរសេរនៅក្នុងមតកសាសន៍ "ឲ្យ ក ធ្វើសន្តតិកម្មដី ខ" ក៏ប៉ុន្តែបើសិនជាម្ចាស់បណ្តាំបានលក់ដីនោះបាត់នៅពេលដែលគាត់នៅរស់ ត្រូវបានចាត់ទុកថាគាត់បានលុបចោលមតកសាសន៍នោះ។

**១.៦.២.២. ការបំផ្លាញចោលនូវមតកសាសន៍**

ប្រសិនម្ចាស់បណ្តាំបានបំផ្លាញចោលច្បាប់ដើមនៃមតកសាសន៍ ឬកម្មវត្ថុនៃមតកសាសន៍នោះដោយចេតនាត្រូវចាត់ទុកថាម្ចាស់បណ្តាំ ត្រូវបានលុបចោលនូវផ្នែកដែលបានបំផ្លាញនោះ។ ម្យ៉ាងវិញទៀត ប្រសិនតតិយជនបានបំផ្លាញមតកសាសាន៍ នោះមតកសាសន៍នៅតែមានសុពលភាព។ លើសពីនេះទៅទៀត បើម្ចាស់បណ្តាំបានបំផ្លាញមតកសាសន៍នេះដោយកំហុស មតកសាសន៍នោះក៏នៅតែមានសុពលភាពដដែល។ ដូច្នេះប្រសិនជាតតិយជន ឬម្ចាស់បណ្តាំបានហែកចោល ឬដុតចោលមតកសាសន៍ដោយកំហុស មតកសាសន៍នោះនៅតែមានសុពលភាពដដែល។ ប៉ុន្តែប្រសិនគេមិនអាចអានមកតសាសន៍ដែលហែក ឬដុតចោលនោះបានទេ គឺគ្មានវិធីទេគឺត្រូវចាត់ទុកថាគ្មានសុពលភាពទេ។

ក្នុងករណីមតកសាសន៍ដែលធ្វើឡើងដោយលិខិតយថាភូត សារការីនឹងរក្សាទុកនូវច្បាប់ដើម ហើយម្ចាស់បណ្តាំរក្សាទុកមតកសាសន៍តែច្បាប់ចម្លងតែប៉ុណ្ណោះ ដូច្នេះការលុបចោលដោយការបំផ្លាញមកតសាសន៍មិនអាចកើតមានឡើងឡើយ ទោះបីម្ចាស់បណ្តាំបានបំផ្លាញមតកសាសន៍ដែលបានចម្លងក៏ដោយក៏មិនអាចចាត់ទុកថាបានលុបចោលមតកសាសន៍នោះបានឡើយ។[20]

**១.៦.៣. ការលុបចោលកិច្ចសន្យានៃមតកសាសន៍ដោយផ្អែកលើវិការៈក្នុងការបង្ហាញ ឆន្ទៈ**

ក្រមរដ្ឋប្បវេណីបានចែងអំពី ការលុបចោលកិច្ចសន្យានៃមតកសាសន៍ដោយផ្អែកលើការបង្ហាញឆន្ទៈពីព្រោះមតកសាសន៍ គឺជាសកម្មភាពឯកតោភាគីហើយមតកសាសន៍អាចលុបចោលដោយផ្អែកលើវិការៈក្នុងការបង្ហាញឆន្ទៈផងដែរ។ ការលុបចោលកិច្ចសន្យានៃមតកសាសន៍ផ្អែកលើវិការៈក្នុងការបង្ហាញឆន្ទៈតម្រូវឱ្យមានអង្គហេតុច្បាស់លាស់ដូចជា កំហុស ការឆបោក ឬការបង្ខិតបង្ខំ ជាដើម។

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៦,៣៥១។

## ១.៧. អច្ច័យទាន

### ១.៧.១ លក្ខណៈទូទៅ

អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្តាំបានធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។ អ្នកទទួលអច្ច័យទានគេហៅថា អច្ច័យលាភី។ [21]

អច្ច័យទាន គឺជារបបមួយប្រហាក់ប្រហែលនឹងប្រទានកម្មដែរតែប៉ុន្តែអច្ច័យទានគឺជាការផ្ទេរទ្រព្យសម្បត្តិតាមរយៈឯកតោភាគីរបស់ម្ចាស់បណ្តាំ ដូច្នេះ ខុសគ្នាត្រង់ប្រទានកម្មគឺជា ការផ្ទេរទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា។ ហើយអច្ច័យទានមានអានុភាពនៅពេលម្ចាស់បណ្តាំទទួលមរណភាព។

### ១.៧.២. ប្រភេទនៃអច្ច័យទាន

**អច្ច័យទានមានពីរប្រភេទគឺៈ**

- ✓ អច្ច័យទាន ដែលជាប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬមួយភាគដែលកំណត់ទៅតាមភាគ (អច្ច័យទានសកល)។ ឧទាហរណ៍ ៖ ឲ្យ ១ ភាគ ៣ នៃមត៌កទៅលោក X។
- ✓ អច្ច័យទាន ជាប្រទានកម្មនូវទ្រព្យសម្បត្តិពិសេស (អច្ច័យទានពិសេស)។ ឧទាហរណ៍ៈ ឲ្យឡានទៅលោក X។

### ១.៧.៣. អច្ច័យលាភី

ប្រសិនបើអច្ច័យលាភីបានទទួលមរណភាពនៅមុនពេលម្ចាស់បណ្តាំបានទទួលមរណភាពអច្ច័យទានពុំបង្កើតអានុភាពឡើយ ។ លើសពីនេះទៅទៀតអច្ច័ទានដែលភ្ជាប់ជាមួយលក្ខខណ្ឌបង្អង់ បើលក្ខខណ្ឌនោះបានបំពេញនៅក្រោយពេលអច្ច័យលាភីបានទទួលមរណភាព អច្ច័ទានពុំបង្កើតអានុភាពឡើយ។ ក្នុងករណីបែបនេះ កម្មវត្ថុនៃអច្ច័យទាននឹងក្លាយជាកម្មសិទ្ធិរបស់សន្តតិជន។ ប៉ុន្តែម្ចាស់បណ្តាំអាចធ្វើឲ្យអច្ច័យទានមានអានុភាពឡើងវិញទោះបីជាអច្ច័លាភីបានទទួលមរណភាពក៏ដោយ។ ឧទាហរណ៍ៈ ម្ចាស់បណ្តាំបានសរសេរនៅក្នុងមតកសាសន៍ថាខ្ញុំឲ្យឡានទៅលោក X ជាអច្ច័យទាន ហើយអច្ច័យទាននេះមិនបាត់បង់អានុភាពឡើយទោះបីជាលោក X ស្លាប់មុនខ្ញុំក៏ដោយ។ ក្នុងករណីនេះ លោក X បានស្លាប់មុនម្ចាស់បណ្តាំហើយសន្តតិជនរបស់លោក X នឹងទទួលបានឡានជាអច្ច័យទាន។

ចំពោះទារកនៅក្នុងគភ៌នៅពេលម្ចាស់បណ្តាំទទួលមរណភាព ទោះទារកនោះមានកំណើតនៅពេលក្រោយអាចទទួលអានុភាពនៃបណ្តាំនោះបាន។ ដូច្នេះនៅពេលដែលទារកនោះកើតមកមានសិទ្ធិទទួលបានអច្ច័យទាននោះបាន។

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ធានុក្រមផ្នែករដ្ឋប្បវេណី លេខរៀង ១៧៧។

### ១.៧.៤. ការបោះបង់ ឬការទទួលស្គាល់នូវអច្ច័យទាន

អច្ច័យទាន គឺជាការផ្ទេរទ្រព្យសម្បត្តិតាមរយៈសកម្មភាពឯកតោភាគីរបស់ម្ចាស់បណ្តាំ ដូច្នេះត្រូវបង្កើតអានុភាពចាប់ពីពេលដែលម្ចាស់បណ្តាំទទួលមរណភាព ដោយមិនពាក់ព័ន្ធនឹងឆន្ទៈរបស់អច្ច័យលាភីទេ។ ប៉ុន្តែមិនអាចបង្ខំអច្ច័យលាភីបានទេម្លោះហើយអច្ច័យលាភីអាចបោះបង់អច្ច័យទានបាន។[22]

ការបោះបង់អច្ច័យទានមានអានុភាពប្រតិសកម្ម ដូច្នេះប្រសិនអច្ច័យលាភីបោះបង់អច្ច័ទានកម្មវត្ថុនៃអច្ច័យទាននឹងត្រូវចាត់ទុកជាផ្នែកនៃមត៌កតាំងពីដំបូង។

#### ក. ការបោះបង់អច្ច័យទានពិសេស

មិនមានបទបញ្ញត្តិណានៅក្នុងក្រមរដ្ឋប្បវេណីចែងអំពី ការបោះបង់អច្ច័យទានពិសេសនោះទេ។ ដូច្នេះ អច្ច័យលាភីត្រូវបង្ហាញឆន្ទៈអំពីការបោះបង់អច្ច័ទានទៅឲ្យបុគ្គលដែលទទួលខុសត្រូវលើអច្ច័យទាន។

(ឧទាហរណ៍ សន្តតិជន អច្ច័យលាភីសកល នីតិបុគ្គលមត៌ក) ដោយវិធីណាមួយដូចជាការប្រាប់ដោយផ្ទាល់មាត់ ផ្ញើសំបុត្រ អ៊ីម៉ែល ជាអាទិ៍។ គ្មានពេលកំណត់សម្រាប់ការបោះបង់ទេ ប៉ុន្តែកាលណាអច្ច័យលាភីបានទទួលអច្ច័យទានហើយ ខ្លួនមិនអាចបោះបង់អច្ច័យទាននោះបានទេ។ ការទទួលអច្ច័យទាន អាចធ្វើទៅបានដោយការបង្ហាញឆន្ទៈដល់បុគ្គលទទួលខុសត្រូវលើអច្ច័យទានដោយអច្ច័លាភី ឬប្រសិនបើអច្ច័យលាភីបានទទួលកម្មវត្ថុនៃអច្ច័យទានដោយមិនមានការប្រកែកគឺអាចចាត់ទុកថាជាការទទួលអច្ច័យទាននោះ។

លើសពីនេះទៀតបុគ្គលដែលមានករណីកិច្ចពាក់ព័ន្ធនឹងអច្ច័យទាន ឬបុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ (ឧទាហរណ៍ ម្ចាស់បំណុលរបស់បុគ្គលដែលមានករណីកិច្ចពាក់ព័ន្ធអច្ច័យទាន) អាចធ្វើការដាស់តឿនពីការទទួលយក ឬ ការលុបចោលកិច្ចសន្យាក្នុងអំឡុងពេលសមរម្យមួយទៅកាន់អច្ច័យលាភី។ ប្រសិនបើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីកិច្ចពាក់ព័ន្ធនឹងអច្ច័យទាននៅក្នុងអំឡុងពេលកំណត់នោះទេ ត្រូវចាត់ទុកថាអច្ច័យលាភីបានទទួលអច្ច័យទាននោះ។

#### ខ. ការបោះបង់អច្ច័យទានសកល

ចំពោះការបោះបង់អច្ច័យទានសកល គឺត្រូវធ្វើឲ្យមានអានុភាពដោយអានុឡោមតាមបទបញ្ញត្តិស្តីពីការបោះបង់សន្តតិកម្ម។ ដូច្នេះការបោះបង់ត្រូវធ្វើឡើងនៅក្នុងរយៈពេល ៣ ខែ ក្រោយពីអច្ច័យលាភីបានដឹងពីការធ្វើអច្ច័យទានសកល។ លើសពីនេះទៀត ការបោះបង់ត្រូវឡើងដោយដាក់ពាក្យបណ្តឹងទៅតុលាការ។

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២០១។

### ១.៧.៥. អច្ច័យទានដែលភ្ជាប់បន្ទុក

#### ក. ការទទួលខុសត្រូវរបស់អច្ច័យលាភី

អច្ច័យទានដែលភ្ជាប់បន្ទុកគឺជា អច្ច័យទានដែលតម្រូវឲ្យអច្ច័យលាភីទទួលខុសត្រូវនូវ ករណីកិច្ចមួយចំនួន។ [23]

ឧទាហរណ៍ ម្ចាស់បណ្តាំ A បានទុកមតកសាសន៍មួយដែលមានខ្លឹមសារថាធ្វើអច្ច័យទានដីទៅឲ្យ B ក៏ប៉ុន្តែ B ត្រូវបង់ ១000ដុល្លារ ទៅឲ្យ C។

អច្ច័យលាភី ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីកិច្ចត្រឹមកម្រិតដែលមិនលើសពីតម្លៃនៃវត្ថុដែលជាវត្ថុនៃអច្ច័យទាន។

ឧទាហរណ៍ ក្នុងករណីខាងលើប្រសិនជាដីនោះមានតម្លៃ ៨00ដុល្លារ B អាចបង់ ៨00ដុល្លារ ទៅ C ហើយគាត់អាចធ្វើលទ្ធកម្មលើដីនោះបាន។

#### ខ. ករណីតម្លៃនៃកម្មវត្ថុត្រូវបានកាត់បន្ថយ

កាលណាតម្លៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុកត្រូវបានកាត់បន្ថយ ដោយអាងលើការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬការទាមទារអោយកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីនឹងត្រូវរួចផុតពីករណីកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគថយចុះនោះ បើសិមជាម្ចាស់បណ្តាំបានបង្ហាញឆន្ទៈខុសគ្នា នៅក្នុងមតកសាសន៍ត្រូវអនុឡោមតាមឆន្ទៈនោះ។

## ១.៨. ការអនុវត្តមតកសាន៍

### ១.៨.១. អត្ថន័យនៃការអនុវត្តមតកសាន៍

ការអនុវត្តមតកសាសន៍ គឺជាការចាត់ចែងដែលចាំបាច់ដើម្បីសម្រេចខ្លឹមសារនៃមកតសាសន៍នោះក្រោយពេលដែលអានុភាពនៃមតកសាសន៍នោះបានកើតឡើង។ អានុភាពនៃមតកសាសន៍កើតឡើងដោយគ្មាននីតិវិធីច្បាប់ច្បាស់លាល់ទេ។ ឧទាហរណ៍ នៅពេលដែលមតកសាសន៍បានកំណត់មត៌កសម្រាប់សន្តតិជននីមួយៗមត៌កនោះខ្លាចជាកម្មសិទ្ធិរបស់សន្តតិជនដោយស្វ័យប្រវត្តិតាមការកំណត់ចំណែកដែលត្រូវបានកំណត់នោះ ឬក៏អច្ច័យលាភីមានសិទ្ធិទទួលបាននូវកម្មវត្ថុនៃអច្ច័ទាននោះ។ ក៏ប៉ុន្តែដើម្បីបំពេញអានុភាពនោះចាំបាច់មាននីតិវិធីច្បាស់លាស់។

ឧទាហរណ៍៖ ត្រូវផ្ទេរការកាន់កាប់ទ្រព្យជាកម្មវត្ថុនៃសន្តតិកម្មត្រូវដកលុយពីធនាគារ ត្រូវផ្ទេរការចុះកម្មសិទ្ធិអចលនវត្ថុជាដើម ដូច្នេះក្រមរដ្ឋប្បវេណីមានបញ្ញត្តិដែលចែងអំពីនីតិវិធីនៃការអនុវត្តមតកសាន៍។

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១១។

### ១.៨.២. ការពិនិត្យបញ្ជាក់ និងការបើកលិខិតមតកសាសន៍

ក្រៅពីមតកសាសន៍ដោយ លិខិតយថាភូត មតកសាសន៍ទាំងអស់ត្រូវពិនិត្យបញ្ជាក់រួមទាំងមតកសាសន៍ដោយវិធីពិសេស។ ជាពិសេសត្រូវកត់សម្គាល់ថាមតកសាសន៍ចំពោះជនដែលកំពុងជួបគ្រោះថ្នាក់ជាបន្ទាន់ដល់ជីវិតត្រូវបានបញ្ជាក់ដោយតុលាការរួចហើយប៉ុន្តែនៅតែតម្រូវឲ្យមានការពិនិត្យបញ្ជាក់។[24]

### ១.៨.៣. គោលបំណងនៃការពិនិត្យបញ្ជាក់មតកសាសន៍

គោលបំណងនៃការពិនិត្យបញ្ជាក់មតកសាសន៍ គឺការជារក្សាទុកនូវភស្តុតាង។ តាមរយៈការពិនិត្យបញ្ជាក់តុលាការបានកត់ត្រាស្ថានភាពខាងក្រៅនៃមតកសាសន៍ជៀសវាង ការក្លែងបន្លំ ឬការផ្លាស់ប្តូ។ ដូច្នេះតុលាការនឹងកត់ត្រាទុកនូវមតកសាសន៍ដោយការថតចម្លង ការថតយករូបភាព និងពណ៌នាពីស្ថានភាពខាងក្រៅនៃមតកសាសន៍ដោយផ្ទាល់មាត់។ ម្យ៉ាងវិញទៀតតុលាការនិងមិនវិនិច្ឆ័យសុពលភាពនៃមតកសាសន៍ទេ។ ប្រសិនបើមានបុគ្គលណាម្នាក់ចង់លើកមតិប្រឆាំងលើសុពលភាពនៃមតកសាសន៍ មិនមែនជាគោលបំណងនៃការពិនិត្យបញ្ជាក់នោះទេ។

### ១.៨.៤. នីតិវិធីសំខាន់ដែលត្រូវគោរពមុនពេលឡើងតុលាការ

អ្នកថែរក្សាគ្រប់គ្រងមតកសាសន៍ ក្រោយពីបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម ត្រូវបង្ហាញឯកសារមតកសាសន៍ទៅកាន់តុលាការដោយគ្មានការយឺតយ៉ាវហើយតុលាការត្រូវពិនិត្យបញ្ជាក់។ ករណីគ្មានអ្នកគ្រប់គ្រងថែរក្សាលិខិតមតកសាសន៍គេត្រូវធ្វើដូចករណីខាងលើដែរក្រោយពេលសន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍បានរកឃើញ លិខិតមតកសាសន៍នោះ។ ប្រសិនបើសន្តតិជនបានរកឃើញលិខិតមតកសាសន៍ដែលរហែកហើយពួកគេគិតថា មតកសាសន៍នោះត្រូវបានលុបចោល ពួកគេនូវតែប្រគល់មតកសាសន៍នោះទៅតុលាការដើម្បីពិនិត្យបញ្ជាក់ ពីព្រោះតុលាការគឺជាអ្នកកំណត់ចុងក្រោយថាមតកសាសន៍នោះត្រូវបានលុបចោល ឬអត់។

ប្រសិនបើមតកសាសន៍ត្រូវបានបិទដោយប្រថាប់ត្រា គេមិនត្រូវបើកមតកសាសន៍នោះទេ។ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រាសន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ត្រូវប្រគល់លិខិតមតកសាសន៍នោះទៅតុលាការដោយមិនត្រូវបើកមើលឡើយ។ ជាធម្មតាមតកសាសន៍ដែលបិទដោយប្រថាប់ត្រា គឺជាមតកសាសន៍ដោយលិខិតសម្ងាត់។ ក៏ប៉ុន្តែម្ចាស់បណ្តាំក៏អាចបិទប្រថាប់ត្រានូវមតកសាសន៍ដោយលិខិតផ្ទាល់បានផងដែរ។ ក្នុងករណីនេះគេមិនអាចបើកមើលលិខិតមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនដែលបានបិទប្រថាប់ត្រានោះទេ។ ហើយជនដែលបានបើកមើលលិខិតមតកសាសន៍ដោយមិន

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣។

មានការត្រួតពិនិត្យបញ្ជាក់ ត្រូវពិន័យជាប្រាក់មិនលើសពី១លានរៀល ។ ប៉ុន្តែទោះបីជាមតកសាសន៍នោះត្រូវបានបើកមើលនៅក្រៅតុលាការក៏ដោយមតកសាសន៍នោះក៏នៅមានសុពលភាពដដែល។

### ១.៨.៥. នីតិវិធីពិនិត្យបញ្ជាក់នៅតុលាការ

#### ក. សមត្ថកិច្ច

សាលាដំបូងគឺជា កន្លែងមានសមត្ថកិច្ចចាប់ផ្តើមសន្តតិកម្មហើយកន្លែងចាប់ផ្តើមសន្តតិកម្មគឺជាអាសយដ្ឋានរបស់មតកជនដែលនៅពេលទទួលមរណភាព។[25]

### ១.៨.៦. ការកោះហៅសន្តតិជន

ជាទូទៅ សន្តតិជនគឺជាអ្នកដាក់ពាក្យស្នើសុំឲ្យមាន ការពិនិត្យបញ្ជាក់ ហើយយោងតាមក្នុងក្រមរដ្ឋប្បវេណីមិនតម្រូវឲ្យមានវត្តមានរបស់សន្តតិជន ឬអច្ច័យលាភីនៅក្នុងការពិនិត្យបញ្ជាក់នោះទេ។ ប៉ុន្តែតុលាការគួតែអនុញ្ញាតឲ្យសន្តតិជន ឬអច្ច័យលាភីមានឱកាសក្នុងការពិនិត្យបញ្ជាក់នោះ។ ដូច្នេះតុលាការត្រូវកំណត់ពេលវេលាក្នុងការពិនិត្យបញ្ជាក់ហើយកោះហៅសន្តតិជន ឬអច្ច័យលាភីដែលតុលាការបានស្គាល់នោះ។

ជាពិសេស ប្រសិនបើមតកសាសន៍ត្រូវបានបិទដោយក្រដាសប្រថាប់ត្រា មតកសាសន៍នោះនឹងត្រូវបើកនៅក្នុងតុលាការដោយមានវត្តមានរបស់សន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬអ្នកតំណាងរបស់ពួកគេ។ ដូច្នេះមតកសាសន៍ដែលបានបិទដោយប្រថាប់ត្រាតុលាការត្រូវកោះហៅសន្តតិជន ឬអច្ច័យលាភីដែលតុលាការបានស្គាល់ ប៉ុន្តែជាធម្មតាគេមិនស្គាល់អច្ច័យលាភីទេ ព្រោះមតកសាសន៍បានបិទដោយប្រថាប់ត្រាបាត់ទៅហើយ តែទោះបីជាយ៉ាងនេះក៏ដោយ មតកសាសន៍ដែលបានបិទដោយប្រថាប់ត្រាមិនមែនមានន័យថា ត្រូវតែមានវត្តមានរបស់សន្តតិជនទាំងអស់នោះទេ។ ការបើកមតកសាសន៍ អាចប្រព្រឹត្តិទៅបាននៅអំឡុងពេលពាក់កណ្តាលនៃនីតិធីពិនិត្យបញ្ជាក់បាន។

### ១.៨.៧. អ្នកប្រតិបត្តិមតកសាសន៍

#### ១.៨.៧.១. ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

មតកជនអាចជ្រើសតាំង ឬប្រគល់អាណត្តិទៅតតិយឲ្យជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬច្រើនអ្នកបានតាមរយៈមតកសាសន៍។[26] ដូច្នេះប្រសិនបើ នៅក្នុងមតកសាសន៍បានបញ្ញត្តិអំពីការជ្រើសតាំង ឬប្រគល់អាណត្តិទៅតតិយជនឲ្យ ជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍សន្តតិជនត្រូវផ្តល់ដំណឹងទៅដល់បុគ្គលដែលត្រូវបានជ្រើសតាំង ឬតតិយជននោះឲ្យបានឆាប់រហ័សបំផុត។ ប្រសិនបើមតកសាសន៍មិនបានបញ្ញត្តិដូចខាងលើទេសន្តតិជនត្រូវស្នើសុំទៅតុលាការដើម្បីជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ប៉ុន្តែគេមិនចាំបាច់ជ្រើស

[25] ច្បាប់ស្តីពីនីតិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧, មាត្រា ៤។

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨៦,១២១៨ ។

តាំងអ្នកប្រតិបត្តិមតកសាសន៍នោះគ្រប់ពេលនោះទេ។ ប្រសិនបើ សន្តតិជនទាំងអស់យល់ព្រមអនុវត្ត មតកសាសន៍នោះដោយខ្លួនឯងនោះពួកគេអាចធ្វើបាន។ ករណីនេះ ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ពុំមានភាពចាំបាច់នោះទេ។ ទោះបីជាយ៉ាងនេះក៏ដោយ ការទទួលស្គាល់កូនតាមរយៈមតកសាសន៍ ការផ្ដាច់មត៌កតាមរយៈមតកសាសន៍ និងការលុបចោលការផ្ដាច់មត៌កតាមមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍ត្រូវអនុវត្តតាមវិធីណាមួយ ដូច្នេះប្រសិនមតកសាសន៍មានរាប់បញ្ចូលបញ្ហាទាំងអស់នេះ សន្តតិជនត្រូវស្នើសុំទៅតុលាការដើម្បីជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍។

### ១.៨.៧.២. ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

#### ក. ករណីការតែងតាំងអ្នកប្រតិបត្តិមតកសាសន៍តាមរយៈមតកសាសន៍

ជនដែលត្រូវដែលត្រូវបានតែងតាំងមិនត្រូវបានបង្ខំឲ្យកាន់មុខងា ជាអ្នកប្រតិបត្តិមតកសាសន៍នោះទេ ប៉ុន្តែបើជននោះបានយល់ព្រមកាន់មុខងានោះហើយជននោះត្រូវបានអនុវត្តមុខងានោះភ្លាម។[27] គ្មានបទបញ្ញត្តិណាចែងអំពីនីតិវិធីក្នុងការទទួលយកការកាន់កាប់មុខងារនេះទេ ប៉ុន្តែជាធម្មតាអ្នកប្រតិបត្តិមតកសាសន៍ត្រូវទទួលយកមុខងារនេះតាមរយៈការបង្ហាញឆន្ទៈទៅកាន់សន្តតិជន។ ប្រសិនបើអ្នប្រតិបត្តិមតកសាសន៍មិនបានបង្ហាញឆន្ទៈឲ្យបានច្បាស់លាស់នោះទេសន្តតិជន ឬជនដែលពាក់ព័ន្ធផលប្រយោជន៍អាចកំណត់រយៈពេលសមរម្យណាមួយ ហើយធ្វើការដាស់តឿនទៅជនដែលបានតែងតាំងជាអ្នកប្រតិបត្តិមតកសាសន៍ដោយទាមទារឲ្យជននោះផ្តល់ចម្លើយជាក់លាក់មួយថាតើគាត់កាន់មុខងារនោះ ឬយ៉ាងណាហើយប្រសិនបើជននោះមិនបានផ្តល់ចម្លើយជាក់លាក់ក្នុងរយៈពេលកំណត់សមរម្យនោះទេគេត្រូវចាត់ទុកថាជននោះបានលាឈប់ពីមុខតំណែងនេះ។ ហើយប្រសិនបើជនដែលត្រូវបានតែងតាំងនោះមិនព្រមកាន់មុខងារសន្តតិជនត្រូវពិចារណាថា តើពួកគេត្រូវអនុវត្តមតកសាសន៍នោះដោយខ្លួនឯង ឬស្នើសុំឲ្យតុលាការតែងតាំងអ្នកប្រតិបត្តិមតកសាសាន៍។[28]

#### ខ. ករណីប្រគល់អាណត្តិឲ្យតតិយជនដើម្បីកំណត់មតកសាសន៍

ជនដែលទទួលអាណត្តិក្នុងមតកសាសន៍ដើម្បីកំណត់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវកំណត់អានុភាពនូវនៃការកំណត់នោះ និងជូនដំណឹងនោះទៅសន្តតិជនដោយគ្មានការយឺតយ៉ាវ។ បើជនដែលទទួលអាណត្តិមានបំណងលាឈប់ពីដំណែងនេះជននោះត្រូវជូនដំណឹងទៅសន្តតិជនដោយគ្មានការយឺតយ៉ាវ។

ប្រសិនបើជនដែលទទួលអាណត្តិដើម្បីកំណត់អ្នកប្រតិបត្តិមតកសាសន៍មិនបានបង្កើតអានុភាពនៃការកំណត់ភ្លាមៗនោះទេសន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចជូនដំណឹងក្នុងរយៈពេលកំណត់សមរម្យណាមួយទៅជនដែលទទួលអាណត្តិជាអ្នកប្រតិបត្តិមតកសាសន៍ ហើយទាមទារឲ្យមានការកំណត់

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៥ ។

[28] ដដែល, មាត្រា ១២១៦ ។

ជ្រើសតាំងនោះ។ ក្នុងករណីនេះប្រសិនបើតតិយជនមិនបានតែងតាំងអ្នកប្រតិបត្តិមតកសាសន៍ក្នុងរយៈពេលសមរម្យណាមួយនោះទេជននោះនឹងត្រូវបានចាត់ទុកថាបានលាឈប់ពីអាណត្តិ។

**គ. ករណីការកំណត់អ្នកប្រតិបត្តិមតកសាសន៍ដោយសេចក្តីសម្រេចរបស់តុលាការ**

តុលាការអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ទៅតាមការស្នើសុំរបស់សន្តតិជន ឬជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍។[29]

### ១.៨.៨. ការដាក់កម្រិតលើការទទួលស្គាល់ជនប្រតិបត្តិមតកសាសន៍

ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ជនស្ថិតក្រោមហិតូបត្ថម្ភ អនីតិជន និងជនក្ស័យធន មិនអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានទេលើសពីនេះក្នុងករណី ដែលអ្នកប្រតិបត្តិមតកសាសន៍ជានីតិបុគ្គលការរំលាយនីតិបុគ្គល ឬអ្នករួមបញ្ចូលនីតិបុគ្គលនឹងមិនទទួលស្គាល់ថា នីតិបុគ្គលនោះជាអ្នកប្រតិបត្តិមតកសាសន៍ឡើយ។ ម្យ៉ាងវិញទៀត ជាគោលការណ៍បុគ្គលណាក៏អាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានដែរដូចជាមិត្តភក្តិរបស់មតកជន សាច់ញាត្តិរបស់មតកជន ឬមេធាវីជាដើម។ លើសពីនេះនីតិបុគ្គលសន្តតិជនម្នាក់ក្នុងចំណោមសន្តតិជនទាំងអស់ ឬអច្ច័លាភីក៏អាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានដែរ។[30]

### ១.៨.៩. មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និងករណីកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍។[31] ប្រសិនបើការងារនោះ ត្រូវចំណាយអស់សោហ៊ុយណាមួយ អ្នកប្រតិបត្តិមតកសាសន៍ត្រូវប្រើប្រាស់មត៌ក ក្នុងការចំណាយនោះ ការចំណាយរួមមានការចំណាយឲ្យអ្នកប្រតិបត្តិមតកសាសន៍។[32]

#### ១.៨.៩.១. ការចាប់ផ្តើមបំពេញមុខងារ

អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិហើយត្រូវប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅសន្តតិជនដោយគ្មានការយឺតយ៉ាវ។ សន្តតិជនមានសិទ្ធិចូលរួម នៅពេលអ្នកប្រតិបត្តិមតកសាសន៍ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបានហើយប្រសិនបើមតកសាសន៍ ទាក់ទងនឹងទ្រព្យសម្បត្តិកំណត់ជាក់លាក់

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៨ និង ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧, មាត្រា ៣ ។

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៧ ។

[31] ដដែល, មាត្រា ១២២៨ ។

[32] ដដែលមាត្រា ១២២០ ។

ណាមួយនោះការរៀបចំបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ គឺមានភាពចាំបាច់សម្រាប់តែទ្រព្យសម្បត្តិដែលជាក់លាក់តែប៉ុណ្ណោះ។[33]

**១.៨.៩.២. ការអនុវត្តមតកសាសន៍**

អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និងកាតព្វកិច្ចធ្វើសកម្មភាពអ្វីៗទាំងអស់ ដែលចាំបាច់សម្រាប់អនុវត្តមតកសាសន៍។ មតកសាសន៍ អាចមានចែងអំពីការផ្ទេរទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់អំពីអច្ច័យទាន ឬកាកំណត់វិធីសាស្ត្របែងចែកទ្រព្យសម្បត្តិ។ អ្នកប្រតិបត្តិមតកសាសន៍អាចផ្ទេរទ្រព្យសម្បត្តិអាចចាត់នីតិវិធីនៃការផ្ទេរសិទ្ធចុះបញ្ជីអចលនវត្ថុ ឬអាចដកលុយពីគណនីធនាគារជាដើមដើម្បីអនុវត្តការផ្ទេរសិទ្ធិនេះ។[34] ហើយប្រសិនបើមតកសាសន៍មានចែងអំពីការទទួស្គាល់កូន អ្នកប្រតិបត្តិមតកសាសន៍ត្រូវដាក់ពាក្យបណ្តឹងទៅមន្ត្រីអត្រានុកូលដ្ឋាន។[35] មួយវិញទៀតមតកសាសន៍មានចែងអំពី ការផ្តាច់មត៌ក ឬការលុបចោលការផ្តាច់មត៌កអ្នកប្រតិបតត្តិមតកសាសន៍ត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ។

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៩ ។

[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧មាត្រា ៩៩៧ ។

[35] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥២,១១៥៤ និង ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧, មាត្រា ៣ ។

# ជំពូកទី២

# ការបែងចែកមត៌ក

## ២.១. ការកំណត់ចំណែកមត៌ក

ក្រមរដ្ឋប្បវេណីបានចែងអំពីវិធានក្នុងការគណនាចំនួននៃមត៌ក ដែលសន្តតិជនដែលសន្តតិជនគ្រប់រូបមានសិទ្ធិទទួលបាន។ ដូច្នេះហើយ ប្រសិនបើមត៌កនោះ មានតែសាច់ប្រាក់ការបែងចែកមត៌កឲ្យមានភាពស្មើគ្នាគឺមានភាពងាយស្រួល ប៉ុន្តែជាទូទៅ មត៌ករួមមានទ្រព្យសម្បត្តិផ្សេងៗដូចជា ចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើបំណុល។ នៅពេលចាប់ផ្តើមសន្តតិកម្មសន្តតិជនមិនត្រឹមតែត្រូវកំណត់ចំនួនចំណែកមត៌កដែលនឹងត្រូវបែងចែកសម្រាប់សន្តតិជនម្នាក់ៗប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ត្រូវកំណត់ថា សន្តតិជនមួយណាដែលត្រូវទទួលមត៌កមួយណាផងដែរ។ ដូច្នេះហើយសន្តតិជនត្រូវកំណត់នូវរបៀបនៃការបែងចែកមត៌ក។ ចំណុចនេះមានភាពស្រដៀងគ្នាទៅនឹងការបែងចែកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធក្នុងការលែងលះផងដែរ។[36] ការបែងចែកមត៌ក ជាទូទៅត្រូវធ្វើតាមរយៈការពិភាក្សារវាងសហសន្តតិជន។[37] ប្រសិនបើពួកគេមិនអាចឈានដល់កិច្ចព្រមព្រៀង ឬការពិភាក្សាមិនបានសម្រេច សន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការ ហើយតុលាការនិងធ្វើបែងចែកទ្រព្យសម្បត្តិតាមរយៈដីកាសម្រេច។

## ២.២. ករណីមានភាពចាំបាច់ក្នុងការបែងចែកមត៌ក

ចូរគិតអំពីករណីមួយចំនួនដែលមតកជនបានធ្វើមតកសាសន៍មួយ ហើយមតកសាសន៍នោះបានរៀបរាប់អំពី មត៌កគ្រប់ប្រភេទ និងបានរៀបរាប់ពីបុគ្គលដែលត្រូវទទួលបានមត៌កនីមួយៗយ៉ាងលំអិតផងដែរ។[38] ក្នុងករណីនេះមត៌កទាំងអស់ នឹងត្រូវបែងចែកទៅតាមខ្លឹមសារនៃ មតកសាសន៍នោះក្រោយការស្លាប់របស់មតកជន ដូច្នេះគេមិនចាំបាច់ធ្វើការបែងចែកមត៌កឡើយ។

ឧទាហរណ៍៖ មានសន្តិជន A B និង C ចំណែកឯមត៌ករួមមាន ដី ឡាន និងលុយ ហើយមតកសាសន៍បានកំណត់ថា A ត្រូវទទួលបាន ៣ ភាគ ៦ B ត្រូវទទួលបាន ២ ភាគ ៦ និង C ត្រូវទទួលបាន១ ភាគ ៦។ ក្នុងករណីនេះ A B និង C ត្រូវបែងចែកមត៌កតាមរយៈចំណែកមត៌កដែលត្រូវបានកំណត់នៅក្នុងមតកសាសន៍។ ប៉ុន្តែ មតកសាសន៍នោះមិនបានបញ្ជាក់ថា អ្នកណាត្រូវទទួលបានដី អ្នកណាត្រូវទទួលបានឡាន និងអ្នកណា

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៦៦ ។

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧០ និង ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧, មាត្រា ៣ ។

[38] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៩៤,១១៩៥ ។

ត្រូវទទួលបានលុយនោះទេ។ ដូច្នេះហើយ ពួកគេត្រូវធ្វើបំណែងចែកមត៌កតាមរយៈការពិភាក្សាគ្នា ឬតាមសេចក្តីចម្រេចរបស់តុលាការ។

## ២.៣. ការគ្រប់គ្រងមត៌កមុននឹងធ្វើការបែងចែក

មត៌ក ត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិកម្មរហូតដល់ការបែងចែកត្រូវបានប្រព្រឹត្ត។[39] ក្នុងអំឡុងពេលនេះ សន្តតិជនដែលត្រូវកាន់កាប់មត៌កនៅពេលដែលមតកជនទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះរហូតដល់ពេលធ្វើការបែងចែកមត៌ក ។[40] លើសពីនេះទៀត សន្តតិជនត្រូវគ្រប់គ្រងមត៌កនេះ ប្រកបដោយការប្រុងប្រយ័ត្នដូចគ្នានឹងទ្រព្យសម្បត្តិរបស់ខ្លួនផងដែរ ។[41] ក្នុងអំឡុងពេលនេះ សោហ៊ុយដែលត្រូវចំណាយដែលទាក់ទងមត៌កត្រូវជាបន្ទុកនៃមត៌កនោះប៉ុន្តែសោហ៊ុយដែលនឹងកើតចេញពីកំហុសរបស់សន្តតិជន ត្រូវជាបន្ទុករបស់សន្តតិជននោះ។

**ផលដែលកើតមកពីការបែងចែកមត៌ក** ដោយសារតែការបែងចែកមត៌កអាចនឹងត្រូវធ្វើឡើង យ៉ាងហោចណាស់រយៈពេល ១ ខែ ក្រោយការចាប់ផ្តើមសន្តតិកម្ម ដូច្នេះមត៌កនឹងស្ថិតក្រោមកម្មសិទ្ធិអវិភាគក្នុងរយៈពេលលើសពី ១ ខែ ។ ក្នុងអំឡុងពេលនោះ ផលធម្មជាតិ ឬផលស៊ីវិល អាចនឹងកើតចេញមកពីការបែងចែកមត៌ក ដូចជា ការប្រាក់ដែលបានពីការដាក់ប្រាក់នៅក្នុងធនាគារ ចំណូលបានមកពីការជួលផ្ទះ ឬផលស្រូវជាដើម។[42]

## ២.៤. របៀបនៃការបែងចែកមត៌ក

របៀបនៃការបែងចែកមត៌កត្រូវបានបែងចែកជាបីគឺៈ

### ក. ការបែងចែកវត្ថុជាក់ស្តែង

ការបែងចែកវត្ថុជាក់ស្តែង គឺជាការបែងចែកវត្ថុដោយផ្ទាល់តែម្តង។

ឧទាហរណ៍ៈ មានសន្តតិជន A B និង C ហើយមត៌ករួមមាន ដី ឡាន និងប្រាក់មួយចំនួន ១៣.០០០ ដុល្លារ ។ ក្នុងករណីនេះ ប្រសិនបើការបែងចែកមត៌កដោយឲ្យ A ទទួលបានដី B ទទួលបានឡាន និងប្រាក់ចំនួន ៣.០០០ដុល្លារ ហើយ C ទទួលបានប្រាក់ ១០.០០០ដុល្លារ នោះការបែងចែកនេះហៅថា ការបែងចែកវត្ថុជាក់លាក់។

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៨ ។

[40] ដដែល, មាត្រា ១២៦២ ។

[41] ដដែល, មាត្រា ១២៦៥ ។

[42] ដដែល, មាត្រា ១២៦៦ ,១២៦៧។

**ខ. ការបែងចែកក្រោមលក្ខខណ្ឌនៃការបង់ប្រាក់សម្រួល**

ការបែងចែកក្រោមលក្ខខណ្ឌនៃការបង់ប្រាក់សម្រួល គឺជាវិធីនៃការបែងចែកមត៌កដោយអនុញ្ញាតឲ្យសន្តតិជនណាមួយទទួលនូវ មត៌កទាំងមូល ដោយស្ថិតក្នុងក្រមល័ក្ខខ័ណ្ឌនៃការបង់ប្រាក់សម្រួលក្នុងចំនួនសមរម្យទៅឲ្យសន្តតិជនផ្សេងទៀត ឲ្យត្រូវនឹងចំណែកមត៌កដែលសន្តតិជននីមួយៗត្រូវទទួលបាន។ ឧទាហរណ៍៖ សន្តតិជនមាន A B និង ហើយដី គឺជាមត៌កតែមួយគត់ ។ ក្នុងករណីនេះ ប្រសិនបើការបែងចែកមត៌កដោយឲ្យ A ទទួលបាននូវដីទាំងមូល នោះ A ត្រូវបង់ប្រាក់ចំនួន ៥.០០០ដុល្លារ ទៅ B និង៥.០០០ដុល្លារ ដុល្លារទៀត ទៅឲ្យ C ។ ករណីនេះ គេហៅថា ការបែងចែកក្រោមល័ក្ខខ័ណ្ឌនៃការបង់ប្រាក់សម្រួល ។

**គ. ការបែងចែកប្រាក់ដែលបានមកពីការលក់**

ការបែងចែកប្រាក់ដែលបានមកពីការលក់ គឺជារបៀបនៃការបែងចែកមត៌កតាមរយៈការលៃទុកប្រាក់ដែលបានមកពីការលក់ដោយការដេញថ្លៃជាសាធារណៈសម្រាប់ផ្តល់ឲ្យសន្តតិជន ។[43]

ឧទាហរណ៍៖ សន្តតិជនមាន A B និង C ហើយដីជាមត៌កតែមួយគត់ ។ ក្នុងករណីនេះ កាលណាតុលាការបានចេញដីការសម្រេចដែលមានខ្លឹមសារថា ″ ត្រូវលក់អចលនទ្រព្យដោយការដេញថ្លៃជាសាធារណៈ ហើយប្រាក់ដែលនៅសល់ពីការលក់ក្រោយពីកាត់សោហ៊ុយចំណាយលើការដេញថ្លៃត្រូវចែកទៅឲ្យ A B និង C ស្មើៗគ្នា ‶ នេះគេហៅថាការបែងចែកប្រាក់ដែលបានមកពីការលក់។

**២.៤.១. ការបញ្ជាក់អំពីសន្តិជន**

នៅពេលសន្តតិកម្មចាប់ផ្តើម ទោះបីជាសន្តតិកម្មតាមច្បាប់ ឬតាមមតកសាសន៍ក៏ដោយ យើងត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់សន្តតិជនឲ្យបានច្បាស់លាស់ ដោយភ្ជាប់ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណដែលមានទំនាក់ទំនងញាត្តិជាមួយនឹងមតកជនដូចជា សំបុត្រកំណើត សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ សំបុត្រមរណភាព ឬឯកសារអគ្រានុកូលដ្ឋានផ្សេងទៀតដែលអាចបញ្ជាក់អំពីទំនាក់ទំនងញាត្តិ។[44] ការបែងចែងមត៌ក ដោយបូករួមទាំងជនដែលគ្មានលក្ខណៈសម្បត្តិក្នុងទំហំនៃសន្តតិជន ត្រូវចាត់ទុកជាមោឃៈ ដោយរាប់បញ្ចូលការបែងចែកមត៌កតាមការពិភាក្សាដោយអវត្តមានអ្នកមានលក្ខណៈសម្បត្តិមួយចំនួន ។ ក្នុងករណីការទទួលស្គាល់ក្រោយត្រូវអនុវត្តតាមមាត្រា ១២៧៤ មានន័យថា ការកំណត់សន្តតិជនផ្តោតសំខាន់នៅមុននីតិវិធីសន្តតិកម្ម។ ទោះបីដឹងច្បាស់ថាមានសន្តតិជនដែលត្រូវបានកំណត់ក៏ដោយ ក៏មិនអាចក្លាយជាសន្តតិជនបានដែរ បើសិនជាសន្តតិជននោះស្លាប់ ឬជាអភ័ព្វបុគ្គល ឬអត្ថិភាពនៃការផ្តាច់មត៌កពីសន្តតិជន។ ប្រសិនបើសន្តតិជនជាជនបរទេស ឬគ្មានសញ្ជាតិខ្មែរ ក៏មិនអាចទទួលមត៌កជាដីធ្លី ប៉ុន្តែអាចចាត់ចែងក្នុងអំឡុងពេល

[43] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧១ ។

[44] មេធាវី អ៊ីវ ប៉ូលី, សៀវភៅការបែងចែកមត៌ក,២០១១, នីតិរដ្ឋប្បវេណី,ភ្នំពេញ ។

០៣ ខែ ដើម្បីប្តូរជាប្រាក់ បើផុតអំឡុងពេលនឹងធ្វើសន្តតិកម្មបន្ទាប់ទៅសន្តតិជនដែលមានសញ្ជាតិខ្មែរ បើគ្មានត្រូវធ្លាក់ជាទ្រព្យសម្បត្តិរដ្ឋ ។

### ២.៤.២. កម្មវត្ថុនៃសន្តតិកម្ម

កម្មវត្ថុនៃសន្តតិកម្ម គឺជាទ្រព្យផ្ទាល់របស់មតកជន ដែលអាចជាទ្រព្យដោយឡែក និង ១/២នៃទ្រព្យរួមរបស់មតកជន បើមតកជនមានសហព័ទ្ធជាអាទិ៍ ។ ហើយទ្រព្យសម្បត្តិរបស់មតកជនអាចជា ចលនវត្ថុ និង អចលនវត្ថុ ប្រាក់នៅក្នុងគណនីធនាគារ ឬសិទ្ធិលើបំណុលផ្សេងៗទៀត ដូចជាបំណុលដែលមតកជនមានចំពោះកូនបំណុល ។ ដើម្បីឲ្យមានភាពច្បាស់លាស់លើអត្តសញ្ញាណនៃទ្រព្យទាំងនោះ ត្រូវមានឯកសារបញ្ជាក់អត្តសញ្ញាណទ្រព្យទាំងនោះដូចជា ចំពោះរថយន្ត (ប័ណ្ណសម្គាល់យានយន្ត) ដី (វិញ្ញាណបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) ប្រាក់ក្នុងធនាគារ (សៀវភៅធនាគារ ឬ ATM Card ) ប្រាក់បំណុល (កិច្ចសន្យាខ្ចីប្រាក់) ឬភាគហ៊ុន ( លក្ខន្តិកៈក្រុមហ៊ុន) ឬប័ណ្ណភាគហ៊ុន ។ នៅក្នុងករណីបែងចែកមត៌កដោយរួមបញ្ចូលទាំងទ្រព្យដែលមិនមែនជាទ្រព្យសន្តតិកម្ម នោះការពិភាក្សាបែងចែកទាំងមូលអាចក្លាយជាមោឃភាពដោយសារការភាន់ច្រឡំ ហើយបើមានទ្រព្យសន្តតិកម្មមួយផ្នែកមិនបានបញ្ចូល នោះការបែងចែកមត៌កត្រូវធ្វើសារជាថ្មីក៏មាន ។ ករណីខ្លះមានវិវាទទៅតុលាការ ដោយសារសន្តតិជនបានអះអាងទ្រព្យសម្បត្តិសន្តតិកម្មជាទ្រព្យសម្បត្តិឯកជនតែម្នាក់ ជាអាទិ៍ ។ ក្នុងករណីដែលមើលឃើញថាទ្រព្យអសកម្មមានច្រើនជាងទ្រព្យសកម្ម យើងត្រូវធ្វើនីតិវិធីបោះបង់សន្តតិកម្មភ្លាមៗ ។[45] ប្រសិនបើទ្រព្យអកម្មមានច្រើនជាងទ្រព្យសកម្ម គប្បីផ្តើតតារាងទំនាក់ទំនងញាត្តិ ដើម្បីបង្ហាញឆន្ទៈបោះបង់ ឬយល់ព្រម និងការយល់ព្រមដោយមានកម្រិត ។ ជាគោលការណ៍មានអំឡុងពេល ០៣ ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ។ ហើយតម្លៃនៃកម្មវត្ថុមត៌ក ជាទូទៅត្រូវបានបំលែងជាប្រាក់តាមការសន្មត ដើម្បីងាយស្រួលក្នុងការបែងចែកមត៌ក ហេតុនេះ ជាទូទៅតុលាការកំណត់ថាតម្លៃកម្មវត្ថុមត៌កត្រូវសន្មត នៅពេលសន្តតិកម្មចាប់ផ្តើម ។

ឧទាហរណ៍៖ មតកជន បានបន្សល់ទុក ដី រថយន្ត លុយនៅធនាគារ គ្រឿងអលង្ការ ។ បើម្ចាស់ទ្រព្យបានស្លាប់នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ដីមានតម្លៃ ២០០.០០០ រថន្តយន្តតម្លៃ ៦០.០០០ គ្រឿងអលង្ការតម្លៃ ៤០.០០០ ហេតុនេះមត៌កសរុបមានតម្លៃ ៣០០.០០០ ។

ចំពោះការវាយតម្លៃនៃទ្រព្យនីមួយៗ ត្រូវអនុវត្តតាមការព្រមព្រៀងរបស់សន្តតិជន ប្រសិនបើគ្មានការឯកភាពគ្នានោះទេ ភាគីអាចដាក់ពាក្យសុំទៅតុលាការ តុលាការនឹងជ្រើសតាំងអ្នកជំនាញក្នុងការវាយតម្លៃ ដោយសួរយោបល់របស់ភាគីអំពីបុគ្គលដែលតុលការមានបំណងជ្រើសតាំង ប្រសិនបើមានយោបល់ផ្សេងគ្នា តុលាការ

[45] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា,១២៤៨, ១២៥៦, ១២៦០ ។

នឹងសម្រេចដោយសន្ធានុសិទ្ធិ ។ ការពិចារណារបស់តុលាការក្នុងការជ្រើសតាំងអ្នកវាយតម្លៃ ឬអ្នកជំនាញ ជា អាទិ៍ គឺតាមរយៈការស្ទាបស្ទង់អំពីតម្លៃនៅលើទៅផ្សារ ដោយប្រមូលតម្លៃប៉ាន់ស្មាន ពីអ្នកដែលបំពេញកិច្ចការទាំងនោះ ដូចជាករណីវាយតម្លៃ គ្រឿងអលង្ការ ឬរថយន្ត ជាអាទិ៍ គឺសុំតារាងប៉ាន់តម្លៃពីហាងលក់រថយន្តចំនួន ០៣ ទីតាំង ជាអាទិ៍ បន្ទាប់មកតម្លៃមធ្យមភាគ ក្នុងការកំណត់តម្លៃរួចមួយ សម្រាប់ជាមូលដ្ឋានមួយនៃតម្លៃសរុបរបស់សន្តតិកម្ម ។

### ២.៤.៣. ភាតព្វកិច្ចនៃសន្តតិកម្ម

នៅពេលសន្តតិកម្មចាប់ផ្តើម គម្បីស្រាវជ្រាវ ឬស្វែងយល់បំណុលរបស់មតកជនដើម្បីឲ្យមានភាពច្បាស់លាស់ថា តើបំណុលទាំងនោះមានកម្រិតណា ច្រើនជាង ឬតិចជាងទ្រព្យដែលបន្សល់ទុក សម្រាប់ជាមូលដ្ឋានក្នុងការបង្ហាញឆន្ទៈទទួលយកមត៌កដោយកម្រិត ឬការបោះបង់សន្តតិកម្ម ជាអាទិ៍ ។ ដើម្បីឲ្យមានភាពច្បាស់លាស់ចំពោះបំណុលរបស់មតកជន គម្បីមានឯកសារបញ្ជាក់បំណុល ដែលអាចជាកិច្ចសន្យាខ្ចីប្រាក់ ជាអាទិ៍ តាមរយៈការសាកសួរពីសន្តតិជន ឯកសារនានាដែលបានបន្សល់ទុក ឬបញ្ជីស្នាមផ្សេងៗ ឬតាមរយៈប្រកាសជាសាធារណៈ។ ប្រសិនបើទ្រព្យអកម្មច្រើនជាង ការបោះបង់ ឬការយល់ព្រមដោយមានកម្រិតគម្បីយកមកអនុវត្ត។ សិទ្ធិនេះត្រូវអនុវត្តក្នុងអំឡុងពេល ០៣ ខែ នៅពេលដឹងថាសន្តតិកម្មបានចាប់ផ្តើមចំពោះខ្លួនប៉ុន្តែរយៈពេល០៣ ខែ ករណីខ្លះគឺមានលក្ខណៈមិនសមរម្យ ដោយសារថាទ្រព្យសន្តតិកម្មច្រើនប្រភេទ និងមានទីតាំងផ្សេងៗគ្នាជាអាទិ៍ ។[46] ប្រសិនបើស្ថានភាពបែបនេះ ភាគីអាចស្នើសុំពន្យាពេល ដោយផ្អែកលើករណីដូចខាងក្រោមៈ

ក. ការពន្យាពេលដោយតុលាការ

ខ. ករណីពិសេសដែលសន្តតិជនទទួលមរណភាព

គ. ករណីពិសេសក្នុងករណីអនីតិជន

ឃ. ករណីពិសេសដែលមិនដឹងពីអត្ថិភាពនៃកាតព្វកិច្ច

## ២.៥. ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក

### ២.៥.១. លំហូនៃការទទួលរឿងក្តីសន្តតិកម្ម

#### ក. ចំនួនសន្តតិជន

សាកសួរភាគីលំអិតអំពីបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងមត៌ករបស់មតកជន ដើម្បីដឹងឲ្យច្បាស់លាស់អំពីចំនួនសន្តតិជន ។ ប្រសិនបើអាចកំណត់អត្តសញ្ញាណសន្តតិកម្មរួចហើយ ត្រូវកំណត់ប្រភេទ

[46] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៤៨,១២៤៩,១២៥០,១២៥១ ។

សន្តតិជនថែមទៀត ដូចជាសន្តតិជននោះជាកូន ឬបច្ឆាញាត្តិផ្ទាល់ ឬជាបុគ្គលទទួលតាមសន្តតិកម្មជំនួស ឬសហព័ទ្ធ ឬជាឪពុកម្តាយ ឬបងប្អូនបង្កើត ជាអាទិ៍ ។[47]

**ខ. ចំណែកសន្តតិកម្ម**

នៅពេលដែលអាចកំណត់ចំនួនសន្តតិជន និងអត្តសញ្ញាណរបស់សន្តតិជនរួចហើយ និងដឹងអំពីទំនាក់ទំនងញាត្តិរួចហើយ និងធ្វើការពិនិត្យបន្ត ថាតើមានលិខិតបណ្តាំ ឬយ៉ាងណា បើមានត្រូវអនុវត្តតាមសន្តតិកម្មតាមមតកសាសន៍ បើគ្មានត្រូវបែងចែងមត៌កតាមច្បាប់ ក្នុងចំណោមសន្តតិជនទាំងនោះ ។[48]

**គ. ទំហំមត៌ក**

ដើម្បីទទួលបានភាពច្បាស់លាស់ត្រូវធ្វើការស្រាវជ្រាវមត៌កដែលជាកម្មវត្ថុនៃការបែងចែក គឺជាទ្រព្យសកម្មដែលមិនទាន់បានបែងចែកនៅឡើយនៅពេលបែងចែកមត៌ក នៅក្នុងចំណោមសិទ្ធិនិងករណីកិច្ចនៃទ្រព្យសម្បត្តិរបស់មតកជននៅពេលចាប់ផ្តើមសន្តតិកម្ម ។ ក្នុងករណីដែលមានវិវាទពាក់ព័ន្ធនឹងការទទួលយកមត៌ក ត្រូវដោះស្រាយតាមនីតិវិធីរដ្ឋប្បវេណី ។ ចំណុចដែលត្រូវប្រុងប្រយ័ត្នពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ គឺមានតែចំណែកកម្មសិទ្ធិអវិភាគរបស់មតកជនតែប៉ុណ្ណោះដែលក្លាយជាមត៌ក ។ ប្រសិនបើកម្មវត្ថុនៃមត៌កជាសិទ្ធិលើបំណុលជាប្រាក់ ជាទូទៅសិទ្ធិលើបំណុលនេះនឹងបែងចែកទៅតាមចំណែកនៃសន្តតិកម្មតាមច្បាប់ ប៉ុន្តែប្រសិនជាមានការព្រមព្រៀងរវាងសន្តតិជន សិទ្ធិលើបំណុលនោះអាចជាកម្មវត្ថុនៃការបែងចែក ប៉ុន្តែកាតព្វកិច្ចមិនមែនជាកម្មវត្ថុនៃការបែងចែកមត៌កនោះទេ ។ មួយវិញទៀត ផលពីសិទ្ធិនៃសន្តតិកម្ម ដូចជាប្រាក់សំណងនៃការខូចខាត ជាអាទិ៍ ដែលបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬការបំពានកម្មវត្ថុនៃទ្រព្យសម្បត្តិសន្តតិកម្ម ប្រាក់លក់ដែលបានធ្វើលទ្ធកម្ម ជាអាទិ៍ ដោយកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ នឹងក្លាយជាកម្មវត្ថុនៃការបែងចែកមត៌កផងដែរ។

**ឃ. ការវាយតម្លៃមត៌ក**

ការវាយតម្លៃមត៌កអាចធ្វើឡើងបានតាមរយៈការព្រមព្រៀងអំពីចំនួន ឬការជ្រើសតាំងអ្នកវាយតម្លៃ ឬការសន្មត់នូវចំនួនជាក់លាក់ណាមួយ ។ ចំពោះ អចលនទ្រព្យនៅប្រទេសជប៉ុន តុលាការអាចបង្គាប់ឲ្យដាក់ឯកសារដូចជា លិខិតវាយតម្លៃទ្រព្យ លិខិតប្រកាសពន្ធសន្តតិកម្ម និងលិខិតវាយតម្លៃរបស់ក្រុមហ៊ុនអចលនវត្ថុ ដើម្បីសម្របសម្រួលយោបល់របស់ភាគី និងឈានទៅដល់ការព្រមព្រៀង។ ក្នុងករណីដែលមិនអាចព្រមព្រៀង

[47] មេធាវី អ៊ីវ ប៉ូលី ,សៀវភៅការបែងចែកមត៌ក,២០១១, នីតិរដ្ឋប្បវេណី,ភ្នំពេញ។

[48] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៤៨,១២៤៩,១២៥០,១២៥១ ។

តុលាការនឹងជ្រើសរើសអ្នកវាយតម្លៃដូចជាបុគ្គលដែលមានចំណេះដឹងដូចជា អ្នកជំនាញវាយតម្លៃអចលវត្ថុ ជា អាទិ៍ មកធ្វើការវាយតម្លៃ ។ [49]

**ខ. ការកំណត់ចំណែកមត៌កជាក់ស្តែង**

ចំណែកសន្តតិកម្មជាក់ស្តែងគឺ ជាអត្រាចំណែកមត៌កចុងក្រោយដែលបានសម្រួលរួចរាល់ដោយពិចារណាលើចំណែកសន្តតិកម្មតាមច្បាប់ជាមួយនឹងការទទួលបានផលប្រយោជន៍ពិសេស និង ភាគនៃវិភាគទាន។ ការសម្រួលចំណែកសន្តតិកម្ម ជាវិធីមួយកំណត់ឲ្យមានសមភាពជាក់ស្តែងនៃទ្រព្យសន្តតិកម្ម ។ ទ្រព្យសន្តតិកម្មនៅពេលចាប់ផ្តើមសន្តតិកម្មបូកនឹងផលប្រយោជន៍ពិសេស និងដកភាគនៃវិភាគទានចេញ ត្រូវចាត់ទុកជាមត៌ក ។ ចំណែកសន្តតិកម្មរបស់សន្តតិជនទាំងអស់ (ចំណែកសន្តតិកម្ម បណ្តោះអាសន្ន) ត្រូវគណនាឲ្យទៅតាមចំណែកសន្តតិកម្មតាមច្បាប់នៃទ្រព្យដែលត្រូវបានចាត់ទុកជាមត៌ក។ ចំពោះជនដែលត្រូវទទួលបានផលប្រយោជន៍ពិសេស ត្រូវទទួលបានចំណែកមត៌កជាក់ស្តែងស្មើនឹងចំណែកមត៌ក ដកផលប្រយោជន៍ពិសេសដែលទទួលបានចេញ ហើយសន្តតិជនដែលទទួលបានវិភាគទាន ត្រូវទទួលបានចំណែកមត៌កជាក់ស្តែងស្មើនឹងចំណែក មត៌កបូកនឹងភាគនៃវិភាគទាន ។

**ច. ដីការសម្រេចបែងចែកមត៌ក**

តុលាការត្រូវសម្រេចករណីបែងចែកមត៌ក ដោយពិចារណាទៅលើស្ថានភាពមួយចំនួន ដូចជា ទី១ ការបែងចែកវត្ថុដោយផ្ទាល់ ទី២ ការសម្រួលដោយបង់ជាប្រាក់ ទី៣ ការបែងចែកដោយប្តូរជាប្រាក់ ទី៤ ការបែងចែងជាវត្ថុអវិភាគដោយគិតគូរជាក់ស្តែងទៅលើស្ថានភាពរបស់សហសន្តតិជនដូចជា អាយុ មុខរបរ សុខភាព ជីវភាព វត្ថុ ឬប្រភេទនៃសិទ្ធិដែលមានចំពោះមត៌ក សិទ្ធិអាទិភាពរបស់សហព័ទ្ធ សំណងនៃកាតព្វកិច្ចរបស់មតកជន ទំនៀមទម្លាប់ និងមតិយោបល់របស់សហសន្តតិជន ជាអាទិ៍ ។

### ២.៥.២. របៀបសរសេរពាក្យសុំបែងចែកមត៌ក

ក. អត្តសញ្ញាណភាគី អាស័យដ្ឋាន និងឋានៈភាគី

ខ. ខ្លឹមសារនៃដីការសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឲ្យតុលាការចេញ

គ. អង្គហេតុដែលជាមូលហេតុនៃការទាមទារ។[50]

---

[49] មេធាវី អ៊ីវ ប៉ូលី, សៀវភៅការបែងចែកមត៌ក ,២០១១, នីតិរដ្ឋប្បវេណី,ភ្នំពេញ។

[50] ដដែល,២០១១, នីតិរដ្ឋប្បវេណី,ភ្នំពេញ ។

### ២.៥.៣. ឯកសារភ្ជាប់

ទី១ ឯកសារបញ្ជាក់អត្តសញ្ញាណសន្តតិជន ៖ អត្តសញ្ញាណប័ណ្ណ ។

ទី២ ឯកសារបញ្ជាក់អត្តសញ្ញាណរបស់សន្តតិជន និងមតកជន ៖ សំបុត្រកំណើត សៀវភៅគ្រួសារ និង សៀវភៅស្នាក់នៅ ជាអាទិ៍ ។

ទី៣ ឯកសារបញ្ជាក់អត្តសញ្ញាណទ្រព្យដែលជាកម្មវត្ថុនៃមត៌ក ៖ លិខិតបញ្ជាក់ទ្រព្យទាំងឡាយដែល ជាកម្មសិទ្ធិរបស់មតកជន ។

ទី៤ សំបុត្រមរណភាព ៖ លិខិតដែលបញ្ជាក់អំពីមតកជនស្លាប់ ។

ទី៥ ឯកសារបញ្ជាក់អំពីសិទ្ធិលើបំណុល ឬកាតព្វកិច្ច ជាអាទិ៍ ៖ កិច្ចសន្យា ។

## ២.៦. អវត្តមាននៃសន្តតិជន

នៅពេលដែល មនុស្សម្នាក់ទទួលមរណភាព ទ្រព្យសម្បត្តិរបស់គាត់ត្រូវបានទទួលបន្តដោយ សន្តតិជន ។[51] ប្រសិនបើមានសន្តតិជន ប៉ុន្តែពួកគេបានបាត់ខ្លួន នោះការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់បុគ្គល ដែលអវត្តមាន និងការប្រកាសពីការបាត់ខ្លួនត្រូវយកមកប្រើប្រាស់។ មួយវិញទៀត ក៏អាចមានករណីដែលមិន មានភាពច្បាស់លាស់ ថាតើមានសន្តតិជន ឬអត់។ ក្នុងករណីដូចនេះ ចាំបាច់ត្រូវមាននីតិវិធីក្នុងការស្វែងរក សន្តតិជន។ ប្រសិនបើរកមិនឃើញសន្តតិជនទេនោះ ទ្រព្យសម្បត្តិដែលនៅសល់ត្រូវប្រគល់ឲ្យជនដែលមាន និស្ស័យពិសេសជាមួយនឹងមតកជន ឬធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋ ។

### ២.៦.១. មរណភាពនៃមតកជន

ប្រសិនបើគ្មានភាពច្បាស់លាស់ថាមានសន្តតិជនទេ មត៌កនឹងត្រូវក្លាយជានីតិបុគ្គលមត៌កដោយ ស្វ័យប្រវត្តិ ទោះបីជាមត៌កមានចំនួនតិចតួចក៏ដោយ ក៏នីតិបុគ្គលមត៌កត្រូវបង្កើតឡើងដោយស្វ័យប្រវត្តិ ។ ដើម្បី បង្កើតនីតិបុគ្គលមត៌ក មិនតម្រូវឲ្យមាននីតិវិធីឡើយ ដូច្នេះទោះបីគ្មាននណាម្នាក់ដាក់ពាក្យសុំតែងតាំងអ្នក គ្រប់គ្រងក៏ដោយ ក៏នីតិបុគ្គលមត៌កត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិដែរ ។ ប៉ុន្តែប្រសិនបើគ្មានអ្នកគ្រប់គ្រង នោះក៏គ្មានការចាប់ផ្តើមនៃនីតិវិធីដែរ ។[52]

ភាពមិនច្បាស់លាស់ថាមានសន្តតិជន រួមមាន៖

ក. ច្បាស់ថាមិនមានសន្តតិជន

ខ. មានសន្តតិជនដែរ ប៉ុន្តែពួកគេទាំងអស់បានបោះបង់សន្តតិកម្ម

---

[51] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៧, ៤១ ។

[52] ដដែល, មាត្រា ១២៩០ ។

គ. មានសន្តតិជនដែរ ប៉ុន្តែពួកគេជាអភ័ព្វបុគ្គល ឬជនដែលត្រូវបានផ្តាច់មត៌ក។[53]

### ២.៦.២. ការតែងតាំងអ្នកគ្រប់គ្រង

តុលាការត្រូវតែងតាំងអ្នកគ្រប់គ្រងទៅតាមពាក្យសុំ ប្រសិនបើគ្មាននណាម្នាក់បានដាក់ពាក្យសុំទេ នោះមិនត្រូវតែងតាំងអ្នកគ្រប់គ្រងឡើយ ក្នុងករណីនេះមាននីតិបុគ្គលមត៌ក តែគ្មាននីតិវិធីឡើយ។ ប្រសិនបើមត៌កមានច្រើនសន្ទឹកសន្ធាប់ ដូចជាអចលនវត្ថុ ជាដើមនោះ មេឃុំ ឬចៅសង្កាត់ ឬព្រះរាជអាជ្ញា ត្រូវធ្វើជាអ្នកដាក់ពាក្យសុំនោះ។ ហើយមានករណីជាច្រើនដែលម្ចាស់បំណុលរបស់មតកជន អច្ច័យលាភី ឬជនដែលមាននិស័យពិសេស ធ្វើការដាក់ពាក្យសុំក្នុងការតែងតាំងអ្នកគ្រប់គ្រង ព្រោះបុគ្គលទាំងនេះ គឺជាបុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយសារតែពួកគេត្រូវមានសិទ្ធិទទួលបានមត៌កមួយផ្នែក។[54]

### ២.៦.៣. ការជូនដំណឹងលើកកទី១ដោយតុលាការ

ការជូនដំណឹងជាសាធារណៈនៃការតែងតាំងអ្នកគ្រប់គ្រង ត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និងការចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ ។

### ២.៦.៤. ការជូនដំណឹងលើកទី២ ដោយអ្នកគ្រប់គ្រង

ការជូនដំណឹងជាសាធារណៈសម្រាប់ការបង្ហាញទាមទារ ត្រូវធ្វើឡើងដោយការបិទប្រកាសរបស់តុលាការ និងចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ ។ ការជូនដំណឹងជាសាធារណៈត្រូវ៖

ក. បញ្ជាក់នូវអំឡុងពេលជាក់លាក់ដែលមិនត្រូវតិចជាង ២ ខែ

ខ. បង្ហាញថាគ្រប់សន្តតិជន និងអច្ច័យលាភីទាំងអស់ត្រូវបង្ហាញពីការទាមទាររបស់ពួកគេ នៅក្នុងអំឡុងពេលកំណត់ខាងលើ ។

គ. សរសេរថា ម្ចាស់បំណុលរបស់សន្តតិជនដែលមិនបានបង្ហាញពីការទាមទាររបស់ខ្លួននៅក្នុងអំឡុងពេលខាងលើទេនោះ ការទាមទារនោះនឹងត្រូវដកចេញពីការជម្រះ ។[55]

### ២.៦.៥. ការដកចេញពីការជម្រះ

ម្ចាស់បំណុល និងអច្ច័យលាភី ដែលមិនបង្ហាញការទាមទាររបស់ខ្លួននៅក្នុងអំឡុងពេលខាងលើ នឹងត្រូវដកចេញពីការជម្រះ ។ ម្ចាស់បំណុល និងអច្ច័យលាភីទាំងនោះ អាចអនុវត្តសិទ្ធិរបស់ពួកគេ លុះត្រាតែមានសល់ទ្រព្យសម្បត្តិក្រោយពីការជម្រះ ។ ចំពោះបើតែម្ចាស់បំណុល និងអច្ច័យលាភីទាំងនោះ មិនបានបង្ហាញការទាមទាររបស់ខ្លួននៅក្នុងអំឡុងពេលដែលបានកំណត់ខាងលើក៏ដោយ ប្រសិនបើអ្នកគ្រប់គ្រងស្គាល់ពួកគេ

[53] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦១,១១៥០,១១៥១ ។

[54] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩១ និង ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧, មាត្រា ៣ ។

[55] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៦ ។

ពួកគេនឹងទទួលបានការសងតាមរយៈការជម្រះ។ ទោះបីម្ចាស់បំណុលមិនបានបង្ហាញការទាមទាររបស់ខ្លួននៅក្នុងអំឡុងពេលខាងលើក៏ដោយ ក៏ប្រាតិភោគរបស់ម្ចាស់បំណុលទាំងនោះ មិនត្រូវបានរលត់ឡើយ ដូច្នេះហើយម្ចាស់បំណុលទាំងនោះអាចអនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួនតាមរយៈការជម្រះបាន ។[56]

### ២.៦.៦. ការជម្រះ

ការជម្រះ មានន័យថា អ្នកគ្រប់គ្រងធ្វើការសងបំណុល និងអច្ច័យទានដោយយកចេញពីមត៌ក។ ជាធម្មតា កាជម្រះចាប់ផ្តើមនៅពេលដែលអំឡុងពេលជាក់លាក់ យ៉ាងហោចណាស់ពីខែ បានកន្លងផុត ក្រោយពីការជូនដំណឹងជាសារធាណៈលើកទី២ ។[57] នៅមុនអំឡុងពេលជាក់លាក់នោះ អ្នកគ្រប់គ្រងអាចបដិសេធការសងចំពោះម្ចាស់បំណុល និងអច្ច័យលាភីក៏បាន ។ សូម្បីតែ ក្នុងអំឡុងពេលជាក់លាក់នោះក៏ដោយ ក៏អ្នកគ្រប់គ្រងអាចសងទៅម្ចាស់បំណុល និងអច្ច័លាភីបានដែរ ក្នុងករណីនេះ ប្រសិនបើមិនអាចសងទៅម្ចាស់បំណុល និងអច្ច័យលាភីដ៏ទៃទៀតបានទេនោះ អ្នកគ្រប់គ្រងមានករណីកិច្ចសងសំណងការខូចខាត ។

### ២.៦.៧. ការជូនដំណឹងលើកទី ៣ ដោយតុលាការ

ប្រសិនបើ ក្រោយពីពេលដែលអំឡុងពេលដែលបានកំណត់ជាក់លាក់នៃការជូនដំណឹងលើកទី២ នោះហួសកំណត់ ហើយនៅតែមិនអាចរកឃើញអត្ថិភាពនៃសន្តតិជនទៀតនោះទេ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈលើកទី៣ តាមពាក្យស្នើសុំតាមសំណាក់អ្នកគ្រប់គ្រង ឬព្រះរាជអាជ្ញា។ ប៉ុន្តែ ដោយសារតែគោលបំណងនៃការជូនដំណឹងនេះ គឺដើម្បីផ្តល់ឲ្យនូវទ្រព្យសម្បត្តិដែលនៅសល់ ទៅឲ្យសន្តិជន ដូច្នេះប្រសិនបើប៉ាន់ប្រមាណឃើញថា គ្មានសេសសល់មត៌កទេ មិនទាមទារឲ្យអ្នកគ្រប់គ្រង និងតំណាងអយ្យការធ្វើពាក្យ សុំឡើយ។[58] ការជូនដំណឹងជាសាធារណៈនេះ ត្រូវធ្វើឡើងដោយការបិទប្រកាសរបស់តុលាការ និងចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ ។ ការជូនដំណឹងនេះ ត្រូវបញ្ជាក់ឲ្យច្បាស់ពីអំឡុងពេលជាក់លាក់មួយដែលមិនឲ្យតិចជាង ៦ ខែ ហើយត្រូវសរសេរថា ប្រសិនបើមានសន្តតិជន ពួកគេត្រូវប្រកាសខ្លួន ដោយខ្លួនឯងថាជាសន្តតិជននៅក្នុងអំឡុងពេលខាងលើ ។

### ២.៦.៨. ការរំលត់សិទ្ធិ

ប្រសិនបើគ្មានសន្តតិជនណាបង្ហាញខ្លួនក្នុងអំឡុងពេលខាងលើទេ សន្តតិជនទាំងអស់នឹងបាត់បង់សិទ្ធិរបស់ខ្លួន ។ លើសពីនេះទៀត ម្ចាស់បំណុល និងអច្ច័យទានទាំងអស់ដែលអ្នកគ្រប់គ្រងស្គាល់និងបាត់បង់

[56] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៦,១២៥៨ ។

[57] ដដែល, មាត្រា ១២៨២ ,១២៩៧ ។

[58] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១,មាត្រា ១២ ។

សិទ្ធដូចគ្នា។ ពួកគេ មិនអាចអនុវត្តសិទ្ធិរបស់ពួកគេបានឡើយ ទោះបីជានៅសល់នូវមត៌កក្រោយពីការជម្រះក៏ដោយ ។[59]

### ២.៦.៩. ការចែកមត៌កទៅឲ្យជនដែលមាននិស្ស័យពិសេស

នៅក្នុងករណីខ្លះ ក៏អាចមានមត៌កដែលនៅសល់ក្រោយពីការរលត់សិទ្ធិផងដែរ នៅក្នុងករណីដូច្នេះ ជនដែលមាននិស្ស័យពិសេសអាចដាក់ពាក្យសុំបែងចែកមត៌កទៅឲ្យជនដែលមាននិស័យពិសេសបាន ។ ប្រសិនបើតុលាការពិចារណាឃើញថា សមហេតុផល នោះតុលាការអាចចេញដីកាសម្រេចប្រគល់ឲ្យនូវផ្នែកនៃមត៌កដែលនៅសល់ទៅជនដែលមាននិស្ស័យពិសេស ។ ថ្វីត្បិតតែជនដែលមាននិស្ស័យពិសេស គឺជាសាច់ញាតិរបស់មតកជនក៏ដោយ ក៏ទំនាក់ទំនងញាត្តិ ឬញាត្តិពន្ធមិនមានភាពចាំបាច់អ្វីដែរ ។ នៅក្នុងករណីខ្លះ មិត្តភក្តិរបស់មតកជន ឬមណ្ឌលមើលថែចាស់ជរាដែលមើលថែមតកជនបានជិតដល់ ក៏អាចក្លាយជាជនដែលមាននិស្ស័យពិសេសបានដែរ ។[60]

## ២.៧. ភាគបម្រុង

របបភាគបម្រុង គឺជារបបមួយធានានៃភាគចំណែកមតកកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលកំណត់ដោយច្បាប់។ មតកជនមានសេរីភាពក្នុងការធ្វើមតកសាសន៍ ក៏ប៉ុន្តែរបបនេះទទួលស្គាល់ឲ្យសន្តតិជនដែលកំណត់ដោយច្បាប់មួយចំនួន ធ្វើការបដិសេធនេះមួយភាគ។ របបភាគបម្រុងនេះ មានតួនាទីសម្រួលសន្តិកម្មតាមច្បាប់។ របបភាគបម្រុងនេះ មានវិធីធានានូវភាគបម្រុងដោយបដិសេធមតកសាសន៍ ជាអាទិ៍ដោយសន្តិជនដែលត្រូវបានគេបំពានមានសិទ្ធិលើភាគបម្រុងរបស់ខ្លួន និងវិធីហាមមិនឲ្យមតកជនយកមតកមួយចំនួនទៅធ្វើជាកម្មវត្ថុនៃ មតកសាសន៍។ [61]

### ២.៧.១. គោលបំណង

ច្បាប់បានទទួលស្គាល់ឱ្យមានសន្តតិកម្មតាមបណ្ដាំ (មតកសាសន៍) ដែលមតកជនអាចបង្ហាញឆន្ទៈរបស់ខ្លួនក្នុងការបែងចែកចំណែកមត៌ក បន្ទាប់ពីខ្លួនបានស្លាប់ទៅ។ ប៉ុន្តែការទទួលស្គាល់របបសន្តតិកម្មបែបនេះ ក៏អាចធ្វើឱ្យប៉ះពាល់ដល់ចំណែកដែលសន្តតិជនត្រូវទទួលបានផងដែរ ប្រសិនបើមតកជន បង្ហាញឆន្ទៈចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនដោយមិនត្រឹមត្រូវ ហេតុនេះហើយទើបក្រមរដ្ឋប្បវេណីបានបង្កើតនូវរបបភាគបម្រុងឡើង។ បទបញ្ញត្តិ ស្ដីពីភាគបម្រុងត្រូវបានបង្កើតឡើង ក្នុងគោលបំណងការពារការចាត់ចែងទ្រព្យសម្បត្តិ

---

[59] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៨ ។

[60] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៩ និង ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧, មាត្រា ៣ ។

[61] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី លេខរៀង ១១៤ ។

ដោយមិនត្រឹមត្រូវ ដែលធ្វើឡើងដោយមតកជន ដូចជាធានាបាននូវចំណែកមត៌កជាក់លាក់ និងត្រឹមត្រូវមួយសម្រាប់ជនដែលនឹងត្រូវមានសិទ្ធិទទួលបាន។ មតកជន មានសិទ្ធិធ្វើការបែងចែកមត៌ករបស់គាត់បានគ្រប់រូបភាព ក៏ប៉ុន្តែត្រូវគោរពលក្ខខណ្ឌតាមគោលការណ៍ភាគបម្រុង។ តាមច្បាប់ ភាគបម្រុង គឺជាចំណែកមួយដែលត្រូវបម្រុងទុកឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង តាមច្បាប់កំណត់។ ភាគបម្រុង គឺជាចំណែកបម្រុងទុក ដែលត្រូវរាប់បញ្ចូលទាំងមត៌ក និងទ្រព្យសម្បត្តិមួយចំនួន ដែលមានមុនពេលមរណភាពរបស់មតកជន ដូចជាប្រទានកម្ម និងតម្លៃនៃផលប្រយោជន៍ពិសេស ដោយហេតុថា ប្រសិនបើទ្រព្យសម្បត្តិដែលជាមូលដ្ឋានសម្រាប់គណនាភាគបម្រុងនេះត្រូវបានកំណត់ត្រឹមមត៌ក នោះអាចមានករណីមួយចំនួន ដែលមតកជនគាត់អាចចាត់ចែងទ្រព្យសម្បត្តិបានតាមរយៈប្រទានកម្មជាដើម ដែលអាចធ្វើឱ្យប៉ះពាល់ដល់ចំណែករបស់សន្តតិជន។

### ២.៧.២. អ្នកដែលមានសិទ្ធិលើភាគបម្រុង និងចំណែកនៃភាគបម្រុង

ក្នុងចំណោមសន្តតិជនដែលកំណត់ដោយច្បាប់ មានបច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជន ដែលជាអ្នកមានសិទ្ធិលើភាគបម្រុង ។ មានន័យថា សន្តតិជន ក្រៅពីបងប្អូនបង្កើតរបស់មតកជន និង ជនទទួលសន្តតិកម្មជំនួសបងប្អូនបង្កើតនោះ ជាអ្នកមានសិទ្ធិលើភាគបម្រុង ។ ម្យ៉ាងទៀត ក្នុងករណីដែលបច្ឆាញាតិផ្ទាល់របស់មតកជន បានទទួលមរណភាព មុនពេលមតកជនទទួលមរណភាព ជនដែលទទួល សន្តិកម្មជំនួស ក៏ត្រូវមានភាគបម្រុង ។[62] ជាគោលការណ៍ ភាគបម្រុង គឺ ១ ភាគ ២ នៃមតករបស់មតកជន ហើយចំពោះករណីដែលមានតែឪពុកម្តាយ ឬ មានតែជីដូនជីតាសន្តតិជន ភាគបម្រុង គឺ ១ ភាគ ៣ នៃមតិករបស់មតកជន។ ឧទាហរណ៍ ក្នុងករណីដែលមានតែកូនម្នាក់ នឹង សហព័ទ្ធរបស់មតកជន ជាសន្តតិជន ភាគបម្រុងសម្រាប់អ្នកទាំងនោះ គឺ ១ ភាគ ២ នៃមតិករបស់មតកជន ។

ក្នុងករណីដែលអ្នកមានសិទ្ធិលើភាគបម្រុងមានច្រើននាក់ ត្រូវធ្វើការបែងចែកទ្រព្យដែលត្រូវបានចាត់ទុកជាភាគបម្រុងនោះ ទៅតាមសមាមាត្រនៃចំណែកមត៌ក ។ ចំពោះឧទាហរណ៍ខាងលើនេះ ចំណែកមត៌ក មានស្មើភាពគ្នា ហេតុនេះហើយ ភាគបម្រុងរបស់កូនព្រមទាំងសហព័ទ្ធនោះ គឺ ១ភាគ៤នៃមត៌កសម្រាប់ម្នាក់ៗ ក្នុងករណីដែលឪពុកម្តាយ និង សហព័ទ្ធ រួមទាំងអស់ ៣ នាក់ជាសន្តតិជន ចំណែកមត៌កសន្តតិកម្មរបស់សហព័ទ្ធ គឺ ១ ភាគ ៣ ហើយមត៌កដែលសល់ត្រូវចែកស្មើភាពគ្នាទៅឱ្យឪពុកម្តាយ ដូច្នេះម្នាក់ទទួលបាន ១ ភាគ ៣ ។ ហេតុនេះហើយ ភាគបម្រុងគឺ ១ ភាគ ៦ សម្រាប់ម្នាក់ៗ។ ម្យ៉ាងទៀត ក្នុងករណីដែលបងប្អូនបង្កើតបានមតកជន និង សហព័ទ្ធ ជាសន្តតិជន ភាគបម្រុង មាន ១ ភាគ ២ នៃមត៌ក ក្នុងករណីដែលមានបងប្អូនបង្កើត

[62] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៨,៩ មាត្រា ១២៣០ ។

ចំណែកមត៌ករបស់សហព័ទ្ធគឺ ១ ភាគ២ ដូច្នេះសហព័ទ្ធត្រូវទទួលភាគបម្រុងស្មើនឹង ១ភាគ ៤ នៃមត៌កទាំងអស់។

### ២.៧.៣. ការគណនាចំណែកនៃភាគបម្រុង

ទ្រព្យសកម្មដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង មានទ្រព្យដែលមានពេលចាប់ផ្តើមសន្តតិកម្ម ផលប្រយោជន៍ពិសេស ព្រមទាំងប្រទានកម្មដែលយកមកធ្វើជាមូលដ្ឋាននៃការគណនាភាគបម្រុង។ តម្លៃសរុបនៃទ្រព្យសម្បត្តិនៅពេលចាប់ផ្តើមសន្តិកម្ម និងតម្លៃនៃផលប្រយោជន៍ពិសេស ស្មើនឹងទ្រព្យដែលត្រូវចាត់ទុកថាជាមតក។ នេះគឺដើម្បីអោយមានកម្មភាពជាក់ស្តែងរវាងសហសន្តិជន។ លើសពីនេះក៏មានបូកបន្ថែមទាំងតម្លៃនៃទ្រព្យប្រទានកម្មដែលបានកំណត់ ព្រោះថាទ្រព្យដែលធ្វើប្រទានកម្មចំពោះតតិយជនក្រៅពីសន្តតិកម្ម ក៏អាចក្លាយទៅជាកម្មវត្ថុនៃការទាមទារអោយកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ បន្ទាប់ត្រូវដកត្រូវដកតម្លៃសរុបកាតព្វកិច្ចរបស់មតកជន ពីតម្លៃសរុបនៃទ្រព្យសកម្មទាំងអស់ ព្រោះថាត្រូវយកទ្រព្យសុទ្ធមកធ្វើជាមូលដ្ឋានក្នុងការគណនាភាគបម្រុង។[63]

ឧទាហរណ៍៖ ក្នុងករណីដែលសហព័ទ្ធ A របស់មតកជន ព្រមទាំងកូន B និង C ត្រូវទទួលសន្តិកម្មស្មើគ្នា។ នៅពេលចាប់ផ្តើមសន្តតិកម្ម មត៌ករបស់មតកជនមានទ្រព្យ ១០០០ដុល្លារ B បានទទួលនូវផលប្រយោជន៍ពិសេស ៥០០ដុល្លារ ហើយកាតព្វកិច្ចដែលត្រូវធ្វើសន្តិកម្មមាន ៣០០ដុល្លារ ក្រៅពីនេះ មតកជនមាននារី D ហើយបានធ្វើប្រទានកម្មទ្រព្យ ១០០០ដុល្លារ ទៅអោយនារីនោះនៅ ៦ខែ មុនពេលមរណភាព។ ក្នុងករណីនេះ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនា គឺ ១០០០+៥០០+១០០០-៣០០=២២០០ដុល្លារ។

ក្នុងចំណោមកាតួកិច្ចដែលត្រូវបានទទួលដោយសន្តិកម្ម ត្រូវរាប់បញ្ចូលផងដែរនូវសោហ៊ុយបុណ្យសពតាមឋានៈរបស់មតកជន។តាមធម្មតាកាតព្វកិច្ចដែលត្រូវបានទទួលបន្តដោយ សន្តតិកម្ម សំដៅទៅលើកាតព្វកិច្ចដែលមតកជនមានមុនពេលទទួលមរណភាពប៉ុន្តែ ក៏រាប់បញ្ចូលទាំងសោហុយបុណ្យសពតាមឋានៈរបស់មតកជននោះដោយឡែកមិនត្រូវរាប់បញ្ចូលនូវកាតួកិច្ចដែលសន្តតិជនត្រូវទទួលបន្ទុកដោយអាច្ច័យទាន ទេ។

### ២.៧.៤. ការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ក្នុងចំណោមទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មទ្រព្យ ដែលត្រូវយកមកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺមានទ្រព្យដែលបានធ្វើប្រទានកម្ម និងទ្រព្យដែលបានកំណត់ជាចំណែកមត៌កតាមមតកសាសន៍ ព្រមទាំងផលប្រយោជន៍ពិសេស ។ ដោយឡែកចំពោះទ្រព្យសម្បត្តិដែល

[63] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៨,៩ មាត្រា ១២៣១ ។

នៅសល់ពីទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម តាមធម្មតា ត្រូវធ្វើការបែងចែកទៅអោយជនដែលមានសិទ្ធិលើភាគបម្រុង។

ឧទាហរណ៍៖ ក្នុងករណីដែលសន្តតិជនមានបីអ្នក A, B និង C ហើយមតកមាន១000ដុល្លារ ហើយ A ទទួលបានផលប្រយោជន៍ពិសេស ៥000ដុល្លារ ដូច្នេះចំណែកមត៌ករបស់គឺ 0ដុល្លារ B និង C ទទួលបាន ៥00ដុល្លារម្នាក់។ ក៏ប៉ុន្តែ ភាគបម្រុងដែលអាចទាមទារបានគឺ (១000+៥00)៖២៖៣ =១000ដុល្លារ ដូចន្នេះ B និង C ត្រូវ Aបំពានភាគបម្រុងរបស់ខ្លួន ៥00ដុល្លាម្នាក់។

ក្នុងករណីដែលសន្តតិជនមានបីនាក់ A, B និង C ហើយមតកមាន ១000ដុល្លារ និងបំណុលមាន ៣00ដុល្លារ A ទទួលបានផលប្រយោជន៍ពិសេសចំនួន ៥00ដុល្លារ ចំណែកមត៌កដែលមតកជនបានកំណត់ទៅអោយ B មាន ៨00ដុល្លារ នោះ A នឹងទទួលបាន 0ដុល្លារ (ក្រៅពីនេះទទួលបានផលប្រយោជន៍ពិសេសចំនួន ៥00ដុល្លាររួចហើយ) B នឹងទទួលបាន ៨00ដុល្លារ ហើយ C នឹងទទួលបាន ២00ដុល្លារ (ក្រៅពីនេះសន្តតិជនទាំងនោះត្រូវទទួលបន្ទុកនូវកាតព្វកិច្ច ១00ដុល្លារ ម្នាក់)។ ក្នុងករណីនេះភាគបម្រុងដែលអាចទាមទារបានគឺ (១000+៥00-៣00)៖២៖៣៖៣00៖៣ =៣00ដុល្លារ ។ ដូចន្នេះមានតែ C ដែលត្រូវបានគេបំពានចំនួន ១00ដុល្លារ ក្នុងករណីនេះ ទាមទាអោយកាត់បន្ថយបង្គ្រប់ភាគបម្រុងពី B បាន។

ក្នុងករណីមួយទៀត គឺសន្តតិជនមានបីនាក់ A, B និង C មតកមានចំនួន ១000ដុល្លារ និងបំណុល ៩00ដុល្លារ ។ ៥ឆ្នាំមុន A ទទួលបានផលប្រយោជន៍ពិសេសចំនួន ៥00ដុល្លារ ក្នុងករណីនេះចំណែកមតក A គឺ 0ដុល្លារ B និង C ម្នាក់ ៥00ដុល្លារ (ប្រសិនបើគិតពីកាតព្វកិច្ចថែមទៀត A បាន ៣00ដុល្លារ ហើយ B និង C ទទួលបានម្នាក់ ២00ដុល្លារ) ហេតុនេះហើយ មិនមានអ្នកណាម្នាក់ត្រូវបានគេបំពានភាគបម្រុងរបស់ខ្លួនឡើយ។ ប៉ុន្តែ ប្រសិនបើ A បានបោះបង់សន្តតិកម្មរបស់ខ្លួន ហើយផលប្រយោជន៍ពិសេសត្រូវបានផ្តល់ ដោយបានដឹងថាមានការបំពានភាគបម្រុង នោះភាគបម្រុងរបស់ B និង C គឺ (១00+៥00-៩00) ៖២៖៣+៩00 ៖២=៥៥0ដុល្លារ ។ ក៏ប៉ុន្តែម្នាក់ៗទទួលបានត្រឹមតែ ៥00ដុល្លារ ប៉ុណ្ណោះ ដូច្នេះ ម្នាក់ៗត្រូវ A បំពាន ៥0ដុល្លារ។ ប្រសិនបើ A មិនបានបំពានដោយទុច្ចរិតទេ ភាគបម្រុងរបស់ B និង C គឺ (១000-៩00) ៖២៖៣+៩00 ៖២=៤៦៧ដុល្លារ ដូច្នេះនៅក្នុងករណីនេះមិនមានការបំពានភាគបម្រុងទេ។

ចំពោះអច្ច័យទាន ចំពោះសន្តតិជន ជាកម្មវត្ថុដើម្បីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងប្រសិនបើសន្តតិជនដែលត្រូវគេទាមទារអោយកាត់បន្ថយនោះ ត្រូវបានគេបំពានភាគបម្រុងរបស់ខ្លួនទៅវិញ ដោយសារការកាត់បន្ថយនោះនឹងមានបញ្ហា។[64]

[64] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៨,៩ មាត្រា ១២៣៣ ។

### ២.៧.៥. ការរំលត់សិទ្ធិទាមទារដើម្បីឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិ អំឡុងពេលខ្លី គឺត្រូវបានចងតម្រូវទៅនឹងអំឡុងពេលនៃអាជ្ញាយុកាលនៃការអនុវត្តសិទ្ធិលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ រីឯអំឡុងពេលវែងវិញត្រូវបានចែងតម្រូវទៅនឹង៥ឆ្នាំ ដែលជាអំឡុងពេលទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ការលុបចោលនូវអំពើដែលនាំឱ្យខូចខាតផលប្រយោជន៍ ចាំបាច់ត្រូវអនុវត្តតាមផ្លូវតុលាការ រីឯការទាមទារឱ្យកាត់បន្ថយដើម្បី បង្គ្រប់ភាគបម្រុងមិនចាំបាច់អនុវត្តតាមផ្លូវតុលាការទេ។ ដូច្នេះអាចអនុវត្តសិទ្ធិនេះក្នុងអំឡុងពេលដែលបានកំណត់នេះចំពោះអ្នកមានកាតព្វកិច្ចដោយមិនចាំបាច់ដាក់ពាក្យបណ្ដឹងទេ ។ តាមរយៈការអនុវត្តសិទ្ធិទាមទារនេះ កម្មសិទ្ធិទាំងមូល ឬមួយភាគនៃកម្មវត្ថុត្រូវផ្ទេរទៅអ្នកមានសិទ្ធិដោយស្វ័យប្រវត្តិ ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកមានកាតព្វកិច្ចមិនបានប្រគល់ ឬសហប្រតិបត្តិការធ្វើនីតិវិធីចុះបញ្ជីទេចាំបាច់ត្រូវដាក់ពាក្យបណ្ដឹងចំណុចនេះ គឺដូចគ្នានឹងករណីដែលបានបង្កើតកិច្ចសន្យាលក់ទិញ ក៏ប៉ុន្តែអ្នកលក់មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែរ ។[65]

[65] សេចក្ដីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៨,៩ មាត្រា ១២៤៥ ។

# ជំពូកទី៣

# ការយល់ព្រមទាំងស្រុង ការបោះបង់ និងការយល់ព្រមដោយមានកម្រិត

## ៣.១. លក្ខណៈទូទៅ

នៅពេលដែលមតកជនទទួលមរណភាព សន្តតិជនជាអ្នកស្នងនូវសិទ្ធិ និង បំណុលទាំងអស់ដែលជាកម្មសិទ្ធិមតកជន។ ប៉ុន្តែ ប្រសិនបើមានបំណុលច្រើនលើសលុបនោះ ប្រហែលជាអយុត្តិធម៌ណាស់ក្នុងការបង្ខំឲ្យសន្តតិជនទទួលបន្ទុកទាំងនោះ។[66] ជាធម្មតា សន្តតិជនចង់ទទួលសន្តតិកម្មបើសិទ្ធិមានច្រើនជាងបំណុល ហើយសន្តតិជនចង់ទទួលដោយមានកម្រិត ករណីដែលមិនច្បាស់ថាមានបំណុលមានចំនួនប៉ុន្មាន និង ចង់បោះបង់សន្តតិកម្ម ប្រសិនបើបំណុលមានច្រើនជាងសិទ្ធិ។ ដូច្នេះហើយ ក្រមរដ្ឋប្បវេណីបានផ្ដល់នូវជម្រើស ៣ យ៉ាងដល់សន្តតិជន៖ ការយល់ព្រមទាំងស្រុង ការបោះបង់ ការយល់ព្រមដោយមានកម្រិត។

## ៣.២. ការយល់ព្រមទទួលសន្តតិកម្មទាំងស្រុង

ប្រសិនបើសន្តតិជនមិនបង្កើតអានុភាពបោះបង់ ឬ ការយល់ព្រមដោយមានកម្រិតនោះត្រូវចាត់ទុកថាសន្តតិជននោះបានបង្កើតអានុភាពនៃការយល់ព្រមទាំងស្រុង ក្រោយពេលមតកជនបានទទួលមរណភាព ចាប់តាំងពីពេលដែលបានដឹងថាសន្តតិជនរបស់ខ្លួនបានចាប់ផ្ដើម។ លើសពីនេះទៅទៀត នៅក្នុងអំឡុងពេល ៣ ខែ ប្រសិនបើសន្តតិជនបានចាត់ចែងភាគណាមួយនៃមត៌កនោះ ត្រូវចាត់ទុកថាបានបង្កើតអានុភាពនៃការយល់ព្រមទាំងស្រុង។ ម៉្យាងវិញទៀតទោះបីជា នៅក្រោយពេលសន្តតិជនបង្កើតអានុភាពនៃ ការបោះបង់សន្តតិកម្មក៏ដោយ ប្រសិនបើសន្តតិជននោះលក់ ឬ ប្រើប្រាស់មតកមួយភាគនោះ ត្រូវចាត់ទុកថាបានបង្កើតអានុភាពនៃការយល់ព្រមទាំងស្រុង។ ប្រសិនបើ សន្តតិជនបានយល់ព្រមទាំងស្រុង សន្តតិជននោះ ត្រូវទទួលបន្តដោយគ្មានកម្រិតនៃសិទ្ធិ និង កាតព្វកិច្ចរបស់មតកជន។ ដូច្នេះ បើសន្តតិជនបានបង្កើតអានុភាពលើការយល់ព្រមទាំងស្រុងមិនថាបំណុលមានចំនួនប៉ុន្មាននោះទេ ក៏សន្តតិជនត្រូវទទួលកាតព្វកិច្ចសងបំណុលទាំងនោះដែរ។[67]

### ប្រសិនបើសន្តតិជនសងបំណុលដោយប្រើប្រាស់មត៌ក

ប្រសិនបើសន្តតិជន មានបំណងចង់បោះបង់សន្តតិកម្ម គាត់មិនត្រូវសងបំណុលដោយប្រើប្រាស់មត៌កនោះទេ។ ប្រសិនបើគាត់ធ្វើបែបនេះ ត្រូវចាត់ទុកថាគាត់បានយល់ព្រមទាំងស្រុងលើសន្តតិកម្ម។

---

[66] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៧ (កថាខណ្ឌទី១ វាក្យខណ្ឌទី១) ។

[67] ដដែល, មាត្រា១២៥៤,១២៥៥ ។

**ទោះជាយ៉ាងណាក្តី អាចនឹងមានករណីដូចខាងក្រោមៈ**

សន្តតិជនម្នាក់អាចគិតថា នឹងយល់ព្រមទាំងស្រុងលើសន្តតិកម្មដូច្នេះហើយគាត់បានសងបំណុល ដោយប្រើប្រាស់មត៌ក។ ប៉ុន្តែក្រោយមកគាត់បានដឹងច្បាស់ថាចំនួនបំណុលមានច្រើនលើសពីការស្មាន ហើយគាត់បានប្តូរចិត្តចង់បោះបង់សន្តតិកម្មនោះវិញ។ នៅក្នុងករណីនេះទោះបីជាសន្តតិជនបានប្រើប្រាស់មត៌កដើម្បីសងបំណុលក៏ដោយគាត់មិនត្រូវចាត់ទុកថា បានយល់ព្រមទាំងស្រុងលើសន្តតិកម្មនោះ។

## ៣.៣. ការបោះបង់សន្តតិកម្ម

### ៣.៣.១. គោលបំណង

នៅពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និង ករណីកិច្ចទាំងអស់របស់មតកជន។ ទោះជាយ៉ាងនេះក៏ដោយ វាមិនត្រឹមត្រូវនោះទេនៅក្នុងការបង្ខំឲ្យសន្តតិជននោះមិនចង់បានអ្វីសោះពីមតកជន។ ជាពិសេសប្រសិនបើមតកជនមានកាតព្វកិច្ចច្រើនការបង្ខំឲ្យសន្តតិជនទទួលបន្ទុកបំណុលនោះជារឿងដែលមិនសមរម្យឡើយ។ ដូចនេះហើយ បានជាក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យសន្តតិជន អាចធ្វើការបោះបង់សន្តតិកម្មបាន។ ប្រសិនបើសន្តតិជនបោះបង់សន្តតិកម្ម គាត់និងមិនទទួលបានអ្វីទាំងអស់។[68] ជាធម្មតា សន្តតិជនបោះបង់សន្តតិកម្មក្នុងករណីនៅពេលដែលមានបំណុលច្រើនជាងសិទ្ធិ។ ប៉ុន្តែទោះបីជាគ្មានបំណុលក៏ដោយ ក៏សន្តតិជននៅតែអាចបោះបង់សន្តតិកម្មបានដែរ។[69]

ឧទាហរណ៍ៈសន្តតិជនម្នាក់ដែលចង់ឲ្យសន្តតិជនម្នាក់ទៀតបានទទួលមរតកទាំងអស់អាចធ្វើការបោះបង់សន្តតិកម្មបាន ដើម្បីគោរពដល់សិទ្ធិរបស់សន្តតិជនម្នាក់ទៀតនោះ ដូចជាបងប្រុសច្បង។

### ៣.៣.២. របៀបនៃការបោះបង់សន្តតិកម្ម

#### ក. ការដាក់ពាក្យសុំ

សន្តតិជនត្រូវដាក់ពាក្យសុំបោះបង់សន្តតិកម្មទៅកាន់តុលាការ ដើម្បីបង្កើនអានុភាពនៃការនៃការបោះបង់សន្តតិកម្ម។ តុលាការដែលមានសមត្ថកិច្ចគឺជា តុលាការនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងនិងឧបសម្ព័ន្ធផ្នែកទី៥ចំណុច១៤។[70]

ការដាក់ពាក្យសុំបោះបង់សន្តតិកម្ម ត្រូវធ្វើឡើងដោយសន្តតិជនម្នាក់ៗ។ ដូចនេះ អ្នកដាក់ពាក្យមិនចាំបាច់ដាក់ពាក្យសុំជាមួយសន្តតិជនដទៃ ឬ មិនចាំបាច់មានការយល់ព្រមពីសន្តតិជនដទៃឡើយ លើសពីនេះ

[68] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៧ កថាខណ្ឌទី១ ។

[69] ដដែល, មាត្រា ១២៦០ ។

[70] ច្បាប់ស្តីពីនីតិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧, ឧបសម្ព័ន្ធទី១៥ ចំណុចទី១៤ ។

ទៀត ថ្វីត្បិតតែសន្តតិជនម្នាក់បានធ្វើការយល់ព្រមទាំងស្រុងលើសន្តតិកម្មក៏ដោយ ក៏សន្តតិជនផ្សេងទៀតនៅតែអាចធ្វើការបោះបង់សន្តតិកម្មបានដែរ។

**ខ. ករណីដែលសន្តតិជនជាអនីតិជន ឬ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ**

ក្នុងករណីសន្តតិជនដែលជាអនីតិជន ឬប្រជាជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ សន្តតិជននោះមិនអាចដាក់ពាក្យសុំដោយខ្លួនឯងបាននោះទេ លើកលែងតែជាអនីតិជនដែលទទួលបានអត្តាធីនភាពតែប៉ុណ្ណោះ។ ថ្វីត្បិតតែសន្តតិជននោះ ទទួលបានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អាណាព្យាបាលរបស់អនីតិជន ឬ អាណាព្យាបាលទូទៅ) ក៏ដោយ ក៏សន្តតិជននោះមិនអាចដាក់ពាក្យសុំដោយខ្លួនឯងបានទេ។ ដើម្បីឲ្យសន្តតិជននោះអាចបោះបង់សន្តតិកម្មបាន អ្នកតំណាងដែលច្បាប់បានកំណត់ត្រូវដាក់ពាក្យសុំ។[71] ប្រសិនបើ បានតែងតាំង អ្នកត្រួតពិនិត្យសម្រាប់អាណាព្យាបាលទូទៅ ឬ អាណាព្យាបាលរបស់អនីតិជន នោះអាណាព្យាបាលទូទៅ ឬ អាណាព្យាបាលរបស់អនីតិជនត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យជាមុនសិន។[72]

**គ. ករណីដែលសន្តតិជនជាជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ**

សន្តតិជនដែលដាក់ពាក្យសុំដោយខ្លួនឯងបាន ប៉ុន្តែត្រូវមានកការយល់ព្រមពីហិតូបត្ថម្ភកៈ។ មួយវិញទៀតហិតូបត្ថម្ភកៈមិនអាចដាក់ពាក្យសុំក្នុងនាមជាជននៅក្រោមហិតូបត្ថម្ភនោះទេដោយសារតែហិតូបត្ថម្ភកៈមិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ។[73]

### ៣.៣.៣. រយៈពេលដាក់ពាក្យសុំ

**ក. វិធានការទូទៅ**

ប្រសិនបើសន្តតិជនចង់បោះបង់សន្តតិកម្ម គាត់ត្រូវដាក់ពាក្យទៅតុលាការក្នុងអំឡុងពេល ៣ ខែ ក្រោយពីបានដឹងថាសន្តតិកម្មរបស់ខ្លួនត្រូវបានចាប់ផ្តើម។ ក្នុងអំឡុងពេល ៣ ខែ នេះ ហៅថា **អំឡុងពេលគិតពិចារណា**។ ពីព្រោះតែសន្តតិជនម្នាក់ៗ បានដឹងអំពីការចាប់ផ្តើមសន្តតិជននៅពេលខុសៗគ្នាៗដូចនេះ អំឡុងពេលសម្រាប់គិតពិចារណា ក៏ត្រូវគណនាសម្រាប់គិតពិចារណារបស់សន្តតិជនខ្លះបានចប់ក៏ដោយ ក៏សន្តតិជនផ្សេងទៀត នៅតែអាចបោះបង់ចោលសន្តតិកម្មបានផងដែរ។ ហើយនៅអំឡុងពេលគិតពិចារណា សន្តតិជនត្រូវស្រាវជ្រាវពី សិទ្ធិ និងកាតព្វកិច្ចហើយត្រូវសម្រេច ថាតើ ត្រូវយល់ព្រមដោយមានកម្រិត ឬ ត្រូវយល់ព្រមទាំងស្រុង? ប្រសិនបើគាត់មិនបានដាក់ពាក្យសុំបោះបង់ ឬ យល់ព្រមដោយមានកម្រិតទេនោះ ត្រូវចាត់ទុក

[71] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧,មាត្រា,មាត្រា១៧ កថាខណ្ឌទី២ ។

[72] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៩០, ១១២៦ ។

[73] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧,មាត្រា,១៧ កថាខណ្ឌទី៦ និងកថាខណ្ឌទី៦ ។

ថាគាត់បានយល់ព្រមទាំងស្រុងលើសន្តតិកម្មនោះ(មាត្រា១២៥៥ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ស្តីពីការយល់ព្រមទាំងស្រុងតាមច្បាប់)។[74]

**ខ. ករណីសន្តតិជនទទួលមរណភាពដោយមិនបានយល់ព្រម ឬ បោះបង់**

ប្រសិនបើសន្តតិជនទទួលមរណភាព ដោយមិនបានធ្វើការយល់ព្រម ឬ បោះបង់អំឡុងពេលគិតពិចារណាត្រូវគណនាដោយមិនគិតចាប់ពីពេលដែលសន្តតិជន នៃសន្តតិជនទទួលមរណភាពនោះបានដឹងថាសន្តតិកម្មរបស់ខ្លួនបានចាប់ផ្តើម។

ឧទាហរណ៍៖ ក ជាមតកជន ខ ជាសន្តតិជននិង គ ជាកូនរបស់ខ ។ ក បានទទួលមរណភាពនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៦។ ខ បានទទួលមរណភាពនៅថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០១៦ ដោយមិនបានយល់ព្រម ឬ បោះបង់សន្តតិកម្មឡើយ។ គ បានដឹងពីការស្លាប់របស់ ខ នៅថ្ងៃ១៥ខែសីហា ឆ្នាំ២០១៦។ ក្នុងករណីនេះនៅអំឡុងពេលគិតពិចារណាសម្រាប់ការទទួលសន្តតិកម្មពី ក ត្រូវគណនាចាប់ពីថ្ងៃទី១៥ សីហា ឆ្នាំ២០១៦តទៅ(មាត្រា១២៤៩ នៃក្រមរដ្ឋប្បវេណី)។ អំឡុងពេលគិតពិចារណាសម្រាប់ការទទួលសន្តតិកម្មពី ខ ត្រូវគណនាចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ដូចគ្នា។ ដូចនេះ គ អាចគិតពិចារណាថា ត្រូវបោះបង់សន្តតិកម្ម ឬ ក៏អត់ រហូតដល់ថ្ងៃទិ១៥ ខែវិច្ឆិកា ឆ្នាំ២០១៦។[75] ប្រសិនបើ គ បោះបង់សន្តតិកម្មពីខ នោះ គ មិនចាំបាច់ពិចារណាលើសន្តតិកម្មពី ក ឡើយ។ ផ្ទុយទៅវិញ ប្រសិនបើ គ មិនយល់ព្រមសន្តតិកម្មពី ខ នោះ គ ត្រូវគិតពិចារណាបន្ថែមថាតើត្រូវបោះបង់ឬ យល់ព្រមទទួលសន្តតិកម្មពី ក។

**គ. ករណីដែលសន្តតិជនជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ**

ប្រសិនបើសន្តតិជនជាអនីតិជនឬ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលគិតពិចារណាត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់បានដឹង សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ បានចាប់ផ្តើម។ ប្រសិនបើសន្តតិជនដែលជាអនីតិជន គ្មានទាំងអំណាចមេបា ឬ អាណាព្យាបាលទេនោះ អំឡុងពេលគិតពិចារណា ត្រូវគណនាដោយគិតចាប់បីក្រោយពេលដែលលបានតែងតាំងអាណាព្យាបាលសម្រាប់អនីតិជន។[76]

**ឃ. ករណីដែលសន្តតិជនមិនបានដឹងពីអត្ថិភាពនៃកាតព្វកិច្ច**

ក្នុងករណី ដែលមតកជនមានកាតព្វកិច្ចច្រើនលើសលប់ដែលមិនអាចយកសិទ្ធិទៅសងឲ្យបានគ្រប់ទេនោះ បើសន្តតិជនមិនអាចដឹងពីអត្ថិភាពនៃកាតព្វកិច្ច តាមស្ថានភាពនៃជីវភាពរបស់មតកជន ឬ ស្ថានភាព

[74] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា, ៣០ ចំណុច គ និងចំណុច ង, ១២៥៥ (ចំណុចខ) ។

[75] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៤៨,១២៤៩ ។

[76] ដដែល, មាត្រា,១២៥០ ។

ទ្រព្យ សម្បត្តិរបស់មតកជន និង ស្ថានភាពផ្សេងទៀតទេនោះ អំឡុងពេលគិតពិចារណា ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជន បានដឹងពីអត្ថិភាពនៃកាតព្វកិច្ចនោះ។ ក្នុងករណីនេះ បើសន្តតិជនបានចាត់ចែងទ្រព្យសម្បត្តិដែលជាមត៌កណាមួយដើម្បីសងកាតព្វកិច្ចរបស់មតកជន នៅមុនពេលដែលខ្លួនបានដឹងពីអត្ថិភាពនៃកាតព្វកិច្ចដែលបានរៀបរាប់ខាងលើ មាត្រា១២៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តឡើយ មានន័យថាសន្តតិជននៅតែអាចបោះបង់សន្តតិកម្មបានជានិច្ច។[77]

**ខ. ការពន្យារពេលគិតពិចារណា**

នៅក្នុងករណីដែលមានសិទ្ធិ ឬ កាតព្វកិច្ចច្រើនអំឡុងពេល ៣ខែ ប្រហែលជាមិនគ្រប់គ្រាន់សម្រាប់កំណត់ថាត្រូវបោះបង់សន្តតិកម្ម ឬ អត់ទេនោះ។ ករណីនេះ សន្តតិជនអាចដាក់ពាក្យសុំពន្យារពេលបាន។ ពាក្យសុំពន្យារពេលអំឡុងពេលគិតពិចារណាត្រូវដាក់ទៅតុលាការ នៅអំឡុងពេលគិតពិចារណាលើ ចំណុចដូចជា ចំនួន និង ប្រភេទនៃមត៌ក និង កាតព្វកិច្ច ទីកន្លែងផ្ដើមសន្តតិកម្ម ទីកន្លែងដែលសហសន្តតិជនរស់នូវ ជាដើម។ ប្រសិនបើ តុលាការយល់ថាគួរផ្ដល់ឲ្យការពន្យា តុលាការត្រូវចេញដីការ សម្រេចពន្យាអំឡុងពេលគិតពិចារណា។[78]

បញ្ហាស្ថិតត្រង់ថា បើពន្យាពេលអំឡុងពេលនោះនៅតែមិនគ្រប់គ្រាន់ តើសន្តតិជនអាចដាក់ពាក្យសុំពន្យាលើកទី២ បានដែរឬទេ? សន្តតិជនអាចដាក់ពាក្យសុំជាលើកទី២បានពីព្រោះ ក្រមរដ្ឋប្បវេណីមិនបានកម្រិតពេលវេលានៃការពន្យាពេលនោះឡើយ។ ពាក្យសុំទី២ នោះ ត្រូវដាក់នៅក្នុងពេលដែលពន្យាពេលដោយដីការសម្រេចនៃពាក្យសុំទី១។[79]

**៣.៣.៤. អានុភាព**

**៣.៣.៤.១. ដីការសម្រេច**

បើតុលាការ គិតថាពាក្យសុំបោះបង់សន្តតិកម្មមានភាពត្រឹមត្រូវ តុលាការត្រូវចេញដីការសម្រេចដើម្បីទទួលពាក្យសុំបោះបង់សន្តតិកម្ម។ តុលាការត្រូវពិនិត្យថា អ្នកដែលបានដាក់ពាក្យសុំ គឺជាសន្តតិជនពិតប្រាកដដែរឬទេ តើបានដាក់ពាក្យស្នើរសុំក្នុងអំឡុងពេលគិតពិចារណាដែរឬទេ តើអ្នកដាក់ពាក្យសុំពិតជាមានបំណងចង់បោះបង់សន្តតិកម្មដែរឬទេ ថាតើមានមូលហេតុសម្រាប់ការយល់ព្រមទាំងស្រុងតាមច្បាប់ដែរទេ។ ម៉្យាងទៀត មូលហេតុត្រឹមត្រូវ ឬ ភាពចាំបាច់ក្នុងការបោះបង់ មិនមែនជាលក្ខខណ្ឌក្នុងការបោះបង់សន្តតិកម្មនោះទេ។ ដូចនេះ តុលាការមិនត្រូវលើកចោលពាក្យសុំនោះឡើយ ទោះបីជាគ្មានមូលហេតុចាំបាច់នៃការបោះបង់ក៏ដោយ។

[77] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,, មាត្រា១២៥១ កថាខណ្ឌទី១, ១២៥៥ កថាខណ្ឌទី១ ។

[78] ដដែលមាត្រា, ១២៥៥, ១២៤៨ កថាខណ្ឌទី១ ។

[79] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧,មាត្រា,៣។

ហើយក៏ច្បាប់មិនតម្រូវឲ្យតុលាការ ដឹងលឺពីគំនិតរបស់អ្នកដាក់ពាក្យសុំនោះទេ។ ប៉ុន្តែដើម្បីអនុវត្តក៏ល្អនោះ តុលាការគួរតែពិនិត្យលើអ្នកដាក់ពាក្យសុំដោយផ្ទាល់យ៉ាងហោចណាស់ពិនិត្យតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើការបញ្ជាក់ថាជាឆន្ទៈពិតប្រាកដរបស់អ្នកដាក់ពាក្យសុំ។

**៣.៣.៤.២. អានុភាពនៃការបោះបង់សន្តតិកម្ម**

**ក. អានុភាពចំពោះសន្តតិជនដែលបានបោះបង់សន្តតិកម្ម**

បុគ្គលដែលបានបោះបង់សន្តតិកម្មត្រូវបាន ចាត់ទុកថាបុគ្គលនោះមិនមែនជាសន្តតិជនតាំងពីតំបូងមក។ [80]

**ខ. អានុភាពចំពោះសហសន្តតិជនផ្សេងទៀត**

ចំនួនមត៌កដែលសហសន្តតិជនទទួលបានអាចនឹងកើនឡើង ពីព្រោះចំនួននៃសហសន្តតិជននឹងត្រូវកាត់បន្ថយដោយសារតែការបោះបង់ចោលសន្តតិជនណាម្នាក់។ បើសន្តតិជនទាំងអស់បោះបង់សន្តតិកម្ម សន្តតិជនដែលស្ថិតនៅលំដាប់បន្ទាប់ ត្រូវទទួលសិទ្ធិ និងបន្ទុកកាតព្វកិច្ច។

**គ. ការបោះបង់សន្តតិកម្ម និង សន្តតិកម្មជំនួស**

ទោះបីជាសន្តតិជនបានបោះបង់ សន្តតិកម្មក៏ដោយ សន្តតិកម្មជំនួសនឹងមិនកើនឡើងនោះទេ (មាត្រា១១៥៧នៃក្រមរដ្ឋប្បវេណី មិនបានចែងពីសន្តតិកម្មឡើយ)។ ដូចនេះហើយញាតិលោហិតខ្សែផ្ទាល់នៃសន្តតិជនដែលបានបោះបង់សន្តតិកម្មមិនអាចទទួលមត៌កតាមរយៈសន្តតិកម្មជំនួសបានឡើយ។

**៣.៣.៥. ការបោះបង់ និងការគ្រប់គ្រងមត៌ក**

ជាធម្មតា នៅពេលដែលចាប់ផ្តើមសន្តតិកម្មមត៌កគឺ ស្ថិតនៅក្រោមការកម្មសិទ្ធិរបស់សន្តតិជន។ សន្តតិជនទាំងនោះត្រូវរក្សាទុក និងគ្រប់គ្រងមត៌កដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ។ ការរក្សាទុក និងគ្រប់គ្រងមត៌កដោយប្រុងប្រយ័ត្នដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួននោះ ត្រូវបន្តដល់បុគ្គលដែលបានក្លាយទៅជាសន្តតិជនដោយសារការបោះបង់នោះ អាចចាប់ផ្តើមធ្វើការគ្រប់គ្រងមត៌កនោះបាន។ ប្រសិនបើសន្តតិជន ចំណាយសោហ៊ុយក្នុងការរក្សាការពារមត៌កសោហ៊ុយទាំងនោះត្រូវចំណាយចេញពីទ្រព្យសម្បត្តិ។[81]

## ៣.៤. ការយល់ព្រមទទួលសន្តតកម្មដោយមានកម្រិត

### ៣.៤.១. គោលបំណង

សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបានត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ។ បើមានភាពច្បាស់លាស់ថាមាន

---

[80] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា,១១៥៦,១១៥៧,១១៥៩,១១៦០,១១៦១ ។

[81] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា,១២៦២ កថាខណ្ឌទី១និងទី២ វាក្យខណ្ឌទី១, ១២៦៥ ។

កាតព្វកិច្ចច្រើនជាងទ្រព្យសម្បត្តិសន្តតិជនអាចធ្វើការសម្រេចចិត្តដើម្បីបោះបង់សន្តតិកម្មបាន។ ប៉ុន្តែ ក៏អាចមានករណីដែលមិនអាចដឹងច្បាស់ពីចំនួនកាតព្វកិច្ចផងដែរ។ ក្នុងករណីដូចនេះសន្តតិជនអាចនឹងចង់ដឹងថាតើចំនួនកាតព្វកិច្ចមានលើសសិទ្ធិដែរឬទេ? បើសន្តតិជនយល់ព្រមដោយមានកម្រិតនឹងត្រូវសងបំណុលនោះដោយប្រើប្រាស់មត៌ក។ ក្រោយពីការសង បើនៅសល់ទ្រព្យសម្បត្តិ សន្តតិជនអាចទទួលយកទ្រព្យសម្បត្តិនោះបាន។ ផ្ទុយទៅវិញបើមាននៅសល់បំណុលក្រោយពីការសងសន្តតិជនគ្មានកាតព្វកិច្ចសងបំណុលនោះឡើយ។

### ៣.៤.២. វិធីក្នុងការយល់ព្រមដោយមានកម្រិត

នៅក្នុងការបង្កើតអានុភាពនៃការយល់ព្រមដោយមានកម្រិត សន្តតិជនត្រូវដាក់ពាក្យស្នើសុំអំពីការយល់ព្រមដោយមានកម្រិតរួមជាមួយបញ្ជីសារពើភណ្ឌទៅកាន់តុលាការ។ តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម។

សហសន្តតិជនត្រូវដាក់ពាក្យស្នើសុំអំពីការយល់ព្រមដោយមានកម្រិតដោយរួមគ្នាទាំងអស់ ដូចនេះហើយ បើសន្តតិជនម្នាក់សុខចិត្តយល់ព្រមទាំងស្រុងហើយមិនយល់ព្រមសហការដាក់ពាក្យសុំអំពីការយល់ព្រមដោយមានកម្រិតទេនោះសន្តតិជនដទៃទៀតមិនអាចយល់ព្រមដោយមានកម្រិតលើសន្តតិកម្មបានឡើយ។ ម្យ៉ាងទៀតទោះបីជា សន្តតិជនម្នាក់អាចបោះបង់សន្តតិកម្មក៏ដោយក៏សន្តតិជនដទៃនៅតែអាចយល់ព្រមដោយមានកម្រិតបានដែរ ដោយសារបុគ្គលដែលបានបោះបង់នោះ ត្រូវចាត់ទុកថាមិនមែនជាសន្តតិជនតាំងពីដំបូងមក។[82]

## ៣.៥.អានុភាព

### ៣.៥.១. ដីការសម្រេច

ប្រសិនបើ តុលាការគិតថាពាក្យសុំអំពីការយល់ព្រមដោយមានកម្រិត មានភាពត្រឹមត្រូវតុលារការត្រូវចេញដីការសម្រេចដើម្បីទទួលយកពាក្យសុំអំពីការយល់ព្រមដោយមានកម្រិតនោះ។ ប្រសិនបើ មានសន្តតិជន ២ ឬ ច្រើននាក់ តុលាការត្រូវតែងតាំងអ្នកគ្រប់គ្រងរក្សាមត៌ក។

### ៣.៥.២. អានុភាពនៃការយល់ព្រមដោយមានកម្រិត

#### ៣.៥.២.១. ការជម្រះបញ្ជីមត៌ក

ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយមានកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចទាមទារឲ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ។[83] ជារួមមត៌កត្រូវបែងចែកឲ្យដាច់ពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន។ កាតព្វកិច្ច និង អច្ច័យទាននឹងត្រូវដកចេញពីមត៌កតែ

[82] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា,១២៥៧,១២៥៦ កថាខណ្ឌទី១ ។

[83] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា,១២៨០,១២៨៩ ។

ប៉ុណ្ណោះដោយផ្អែកតាមមាត្រា១២៨០ ដល់ មាត្រា១២៨៩នៃក្រមរដ្ឋប្បវេណី។ ក្រោយពីបានសងបំណុលនិងធ្វើអច្ច័យទានគ្រប់អស់ហើយ ប្រសិនបើ ទ្រព្យសម្បត្តិនៅសល់ សន្តតិជនអាចទទួលបានទ្រព្យសម្បត្តិនោះ។ ផ្ទុយទៅវិញ ប្រសិនបើមិនមានទ្រព្យសម្បត្តិគ្រប់គ្រាន់សម្រាប់សងកាតព្វកិច្ច និងអច្ច័យទានទេនោះ ម្ចាស់បំណុល និង អច្ច័យលាភីមិនអាចទទួលបានការសងដ៏ពេញលេញបានឡើយ។ ប្រសិនបើម្ចាស់បំណុល(ដើមចោទ) បានដាក់ពាក្យបណ្តឹងចំពោះសន្តតិជន(ចុងចម្លើយ)ដែលបានយល់ព្រមដោយមានកម្រិត ហើយម្ចាស់បំណុលជាអ្នកឈ្នះ សាលក្រមត្រូវបញ្ជាក់ឲ្យច្បាស់ថាចុងចម្លើយត្រូវទទួលបន្ទុកកាតព្វកិច្ចត្រឹមត្រូវនៃមត៌កដែលខ្លួនទទួលបានតែប៉ុណ្ណោះ។

**៣.៥.២.២.ការទទួលខុសត្រូវរបស់សន្តតិជនដែលបានចំពានលើការយល់ព្រមដោយមានកម្រិត**

ក្រោយពីបានបង្កើតអានុភាពនៃការយល់ព្រមដោយមានកម្រិត ប្រសិនបើសន្តតិជនមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគទៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បានចាត់ចែងភាគណាមួយនៃទ្រព្យសម្បត្តិជាលក្ខណៈឯកជន នោះសន្តតិជនគ្រប់រូបនោះ នោះសន្តតិជនរូបនោះនិងចាត់ទុកថាបានយល់ព្រមទាំងស្រុង។ នៅក្នុងករណីនេះម្ចាស់បំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសន្តតិជននោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលអាចទទួលការសងដោយមត៌កបាន។[84]

[84] ដដែល, មាត្រា,១២៨០,១២៨៩ ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីយើងខ្ញុំទាំងពីរនាក់បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី សន្តតិកម្មតាមមតកសាសន៍ទាំងមូលរួចមក យើងខ្ញុំសូមធ្វើការសន្និដ្ឋានដូចតទៅ

មុនពេលម្ចាស់បណ្តាំទទួលមរណភាព ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍នៅពេលណាក៏បាន តែនៅពេលធ្វើមតកសាសន៍ គឺតម្រូវឲ្យម្ចាស់បណ្តាំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការពិចារណាឲ្យបានច្បាស់លាស់ដើម្បីបញ្ជាក់ថាមតកសាសន៍បានស្តែងចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ទម្រង់នៃមតកសាសន៍មានបីសំខាន់ៗ គឺមតកសាសន៍ដោយលិខិតយថាភូតមតកសាសន៍ដោយលិខិតឯកជន និងមតកសាសន៍ដោយលិខិតសម្ងាត់។ ហើយម្ចាស់បណ្តាំអាចជ្រើសយកទម្រង់មួយណាក៏បានដែរនៅក្នុងការធ្វើជាលិខិតមតកសាសន៍។ លើសពីនេះទៀតនោះក្នុងលិខិតមតកសាសន៍ មតកជនត្រូវសរសេរបញ្ជាក់ឲ្យច្បាស់នៅចំណុចមួយចំនួនដូចជា ការកំណត់ចំណែកមត៌ក ការកំណត់អ្នកប្រតិបត្តិមតកសាសន៍។ ម៉្យាងវិញទៀត បើមតកជនចង់ផ្តាច់មត៌កពីសន្តតិជនណាមួយ ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងលិខិតមតកសាសន៍។មិនតែប៉ុណ្ណោះការធ្វើមតកសាសន៍ គឺបានជួយឲ្យមានភាពច្បាស់លាស់នូវការបែងចែកទ្រព្យសម្បត្តិនៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព។ ជាពិសេសគឺបានជួយសម្របសម្រួលនូវការចែងចែកទ្រព្យចំពោះសហសន្តតិជនដើម្បីកុំឲ្យមានការឈ្លោះប្រកែកគ្នានៅពេលដែលមានសមាមាត្រមិនស្មើគ្នា ឬមានករណីណាមួយដែលបណ្តាលឲ្យសហសន្តតិជន ឬបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍មានការកើតទុកមិនសុខចិត្ត ព្រោះវាជាឆន្ទៈពិតរបស់មតកជន ដូច្នេះហើយសហសន្តតិជន និងបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ត្រូវតែទទួលយក ដោយការអនុវត្តតាមមតកសាសន៍នោះ។

ការរៀបចំលិខិតបណ្តាំមត៌ក ឬសន្តតិកម្មតាមមតកសាសន៍ជាមុនមានភាពប្រសើរចំពោះម្ចាស់ទ្រព្យចូលដល់ស្ថានភាពចាស់ជរា ឬគ្មានសហព័ទ្ធជាដៃគូអាចបន្តគ្រប់គ្រងបានពីព្រោះវាផ្តល់ឲ្យមតកជន មានលទ្ធភាពក្នុងការពិនិត្យពីគុណសម្បត្តិរបស់សន្តតិជនដែលត្រូវទទួល ពីរបៀបចាត់ចែងទ្រព្យរបស់ខ្លួន និងការស្វែងរកអ្នកប្រតិបត្តិមតកសាសន៍សំរាប់ជួយខ្លួនផងដែរ ។ លើសពីនេះការរៀបចំលិខិតបណ្តាំនឹងធ្វើឲ្យមតកជននៅតែជាម្ចាស់កម្មសិទ្ធិលើទ្រព្យរបស់ខ្លួន ដែលអាចចៀសវាងបាននូវហានិភ័យទាំងឡាយកើតឡើងពេលកំពុងមានជីវិតរស់នៅ ហើយវាក៏អាចជួយការពារវិវាទ ឬជំលោះពីក្នុងចំណោមសន្តតិជនដោយប្រការណាមួយពីបញ្ហាទទួលបានទ្រព្យសម្បត្តិតិចឬច្រើននោះដែរ ។ ដោយសារវិធីនេះមានគុណប្រយោជន៍ច្រើន និងជាពិសេស បានឆ្លើយតបទៅនឹងមតកជនជាចម្បង ម្ចាស់ទ្រព្យគួរយកចិត្តទុកដាក់ និងពិចារណាឲ្យបានល្អិតល្អន់លើការធ្វើមតកសាសន៍មុនឲ្យទ្រព្យសម្បត្តិទៅបុគ្គលណាម្នាក់។

ឆ្លងតាត់តាមរយៈការស្រាវជ្រាវខាងលើ យើងខ្ញុំសង្កេតឃើញថាការធ្វើសន្តតិកម្មតាមមតកសាន៍នេះពិតជាមានសារៈសំខាន់ណាស់ សម្រាប់បុគ្គលគ្រប់រូបដែលមានទ្រព្យសម្បត្តិហើយមិនមានវិធីក្នុងការបែងចែកទ្រព្យទៅបុគ្គលដែលមានលក្ខខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានដោយខ្លាចមានបញ្ហាជម្លោះរវាង កូនចៅសាច់ញ្ញាត្តិនៅអំឡុងពេលមតកជននៅរស់ ដូច្នេះមតកជនអាចការពារបញ្ហានេះបានដោយធ្វើសន្តតិកម្មតាមមតកសាសន៍បានតាមទម្រង់ផ្សេងៗដូចដែលបានកំណត់នៅក្នុងច្បាប់យើង។ ម្យ៉ាងវិញទៀតប្រសិនបើមតកជនមានជំពាក់បំណុលនៅពេលនៅរស់ មតកជនក៏អាចកំណត់អំពីការសងបំណុល ឬកាតព្វកិច្ចផ្សេងៗដែលសន្តតិជនទាំងអស់ត្រូវទទួលខុសត្រូវចំពោះការទទួលបានសន្តតិកម្មនៅក្នុងមតកសាសន៍នោះផងដែរ។

យើងខ្ញុំសង្ឃឹមថា ការស្រាវជ្រាវរបស់យើងខ្ញុំ អំពីសន្តតិកម្មតាមមតកសាសន៍នេះនឹងជួយពង្រឹងចំណេះដឹងនិងការចែករំលែកទៅគ្រប់បុគ្គលដែលចង់ចេះចង់ដឹងអំពីការធ្វើសន្តតិកម្មតាមមតកសាសន៍នេះ ព្រមទាំងទុកជាឯកសារសម្រាប់សិស្សានុសិស្សជំនាន់ក្រោយស្រាវជ្រាវ និងមានចាប់អារម្មណ៍ខ្លាំងចំពោះមហាជនទូទៅ ហើយប្រសិនបើដូច្នេះមែន វាជាការជោគជ័យបំផុតសម្រាប់ការស្រាវជ្រាវរបស់យើងខ្ញុំ។

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់ចំពោះប្រធានបទដូចដែលបានបកស្រាយខាងលើរួចមកក្រុមយើងខ្ញុំ សូមផ្តល់ជាអនុសាសន៍មួយចំនួន ដើម្បីជាពង្រឹងនូវការអនុវត្តនានាឱ្យមានប្រសិទ្ធភាពទៅលើបញ្ហាសន្តតិកម្មតាមមតកសាសន៍នេះ ដោយសារកន្លងមក មានបញ្ហាដែលកើតឡើងក្នុងរឿងសន្តតិកម្មនេះ។

សន្តតិកម្មតាមមតកសាសន៍ គឺជាគោលការនៃការគោរពសិទ្ធិ និង គោលការដើម្បីកំណត់អំពីសិទ្ធិ និងការបង្ហាញឆន្ទៈរបស់ម្ចាស់សិទ្ធិ ពោលគឺម្ចាស់បណ្តាំ ដែលនេះគឺជាស្មារតីនៃក្រមរដ្ឋប្បវេណី ដែលបានបង្កើតបែបនេះឡើង ដើម្បីជាផលប្រយោជន៍ចំពោះម្ចាស់សិទ្ធិ និងអ្នកទទួលស្នងនៃមត៌កនេះ។ ហើយរាល់បញ្ហាដែលកើតឡើងក្នុងរឿងសន្តតិកម្មនេះគឺ ភាគច្រើនបណ្តាលមកការច្រណែនដោយមានការចែកទ្រព្យមិនស្មើគ្នា ដែលធ្វើឱ្យមានការប្តឹងផ្តល់ឡើងទៅតុលាការជាដើម។

ដើម្បីឱ្យការធ្វើសន្តតិកម្មនេះអាចធ្វើទៅបានយ៉ាងមានប្រសិទ្ធភាព និងជៀសវាងនូវវិវាទទាំងឡាយណាដែលទាក់ទងទៅនឹងបញ្ហាសន្តតិកម្ម គឺ ប្រជាពលរដ្ឋគ្រប់រូបគួរយល់ដឹងឱ្យច្បាស់ពីសន្តតិកម្មហើយផ្សព្វផ្សាយឲ្យទូលំទូលាយអណពីការបែងចែងមត៌កនឹងយល់ដឹងពីប្បញ្ញត្តិច្បាប់។ នៅពេលដែលមានវិវាទកើតឡើងដោយបញ្ហាសន្តតិកម្មនេះ គួរព្យាយាមយ៉ាងណាឱ្យមានការសម្របសម្រួលគ្នានៅក្រៅប្រព័ន្ធតុលាការជាមុនសិន ទើបជាការល្អ ដោយវាមិនធ្វើឱ្យខាតពេលវេលា និងថវិកាច្រើននោះទេ។

ចំពោះបញ្ហាដែលកើតឡើងខាងលើនេះ ច្បាស់ណាស់ គឺពិតជាមិនអាចស្វែងរកចម្លើយនៅក្នុងការស្រាវជ្រាវលើប្រធានបទស្តីពី សន្តតិកម្មតាមមតកសាសន៍ ខាងលើនេះបានទេ។ ពីព្រោះបានបញ្ជាក់ឲ្យឃើញថាការសិក្សាស្រាវជ្រាវ គឺមិនទាន់មានភាពគ្រប់គ្រាន់សម្រាប់ការស្វែងយល់ឲ្យកាន់តែច្បាស់ និងទូលំទូលាយនោះទេ។ ដូនេះហើយជាការស្នើរសុំឲ្យមានការសិក្សា និងបកស្រាយបន្ថែម ដោយផ្តោតលើបញ្ហាដែលបានកំណត់ខាងលើដើម្បីឲ្យមានភាពគ្រប់ជ្រុងជ្រោយទៅលើប្រធានបទ សន្តតិកម្មតាមតកសាសន៍ នេះទើបអ្នកស្រាវជ្រាវជំនាន់ក្រោយៗ ងាយយល់និងអាចចាប់អត្ថន័យបានយ៉ាងល្អ។

## ឯកសារយោង

- ✓ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
- ✓ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, លេខ នស/រកម, ២១ វិច្ឆិកា ២០០៧
- ✓ សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៨,៩
- ✓ មេធាវី អ៊ីវ ប៉ូលី, សៀវភៅការបែងចែកមត៌ក,២០១១, នីតិរដ្ឋប្បវេណី,ភ្នំពេញ។
- ✓ លោកគ្រូ អៀង សំណាង សៀវភៅ នីតិរដ្ឋប្បវេណី ស្តីពីសន្តតិកម្ម កែសម្រួលបោះពុម្ពលើកទី១ ខែ មីនា ឆ្នាំ២០០៧។

# ឧបសម្ព័ន្ធ

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

**មាត្រា ១១៦៧.-** ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

## ជំពូកទី ៣
## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១
### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.-** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

ចោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

**មាត្រា ១១៦៩.–** សមត្ថភាពនាពេលធ្វើមតកសាសន៍

១-ម្ចាស់បណ្ដាំ ត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ។

២-បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្ដាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងមាត្រា ១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

## ផ្នែកទី ២
## ទម្រង់នៃមតកសាសន៍

**មាត្រា ១១៧០.–** ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្ដាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

**មាត្រា ១១៧១.–** សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

**មាត្រា ១១៧២.-** បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍

បុគ្គលដែលកំណត់ដូចខាងក្រោមនេះ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍បានឡើយ :

ក-អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។

ខ-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ ។

គ-បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិត របស់សារការីនោះ ។

**មាត្រា ១១៧៣.-** មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយ ត្រូវចុះហត្ថលេខា រៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។

ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

**មាត្រា ១១៧៤.-** មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតក-សាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

**មាត្រា ១១៧៥.-** មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

គ-ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថ-លេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្តាំ ។

**មាត្រា ១១៧៦.-** មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្ដាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

**មាត្រា ១១៧៧.-** មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

១-ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្ដាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវចុះហត្ថលេខាលើលិខិតនោះ ។

២-មតកសាសន៍ដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

៣-តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿ

ទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំ ។

**មាត្រា ១១៧៨.-** មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

១-បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់ ។

២-បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

៣-នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ម្ចាស់បណ្ដាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះបាន ។

៤-បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ១១៧៣ (មតក-សាសន៍ដោយលិខិតយថាភូត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ ពាក្យ សារការីត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ។

៥-មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្ដាំនោះ បែរជាអាចធ្វើមតកសាសន៍បាន តាមទម្រង់ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ដល់មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមនេះក្រោយពេលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

**មាត្រា ១១៧៩.-** ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

១-នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) មាត្រា ១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមនេះ ម្ចាស់បណ្ដាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្ដីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្ដីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី ។

២-ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវអានឱ្យម្ចាស់បណ្ដាំ ឬ សាក្សី ស្ដាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្ដាំ និង សាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្ដាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្ដាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្ដាំ ឬ សាក្សីនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះចូលទៅក្នុងលិខិតនោះ ។

**មាត្រា ១១៨០.-** ការសរសេរនាមត្រកូល និង នាមខ្លួន និង ការផ្ដិតម្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា

ក្នុងករណីដែលសារការី និង សាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សី គ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្ដិតម្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។

**មាត្រា ១១៨១.-** បទប្បញ្ញត្តិពិសេសចំពោះមតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែរមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិត

សម្ងាត់ នៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី ។

## ផ្នែកទី ៣
## ចំណុចនៃមតកសាសន៍

**មាត្រា ១១៨២.-** ការកំណត់ចំណែកមត៌ក

១-មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍ ឬ អាចបង្គាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្តីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

២-បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) ជំពូកទី ២ ។

**មាត្រា ១១៨៣.-** ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្មនោះ បាន ។

**មាត្រា ១១៨៤.-** អនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្តាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩ (និយមន័យនៃអច្ច័យទាន) នៃក្រមនេះបាន នៅក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

**មាត្រា ១១៨៥.–** អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

១-បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតក-សាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ ។

២-ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ ។

**មាត្រា ១១៨៦.–** ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន ។

**មាត្រា ១១៨៧.–** ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ដោយផ្តល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេងៗទៀតបាន ។ នៅក្នុងករណីនេះ សន្តតិជន ជាអាទិ៍ ត្រូវគោរពទៅតាមមតកសាសន៍នោះ ។

## ផ្នែកទី ៤
## ការលុបចោលនូវមតកសាសន៍

**មាត្រា ១១៨៨.-** ពេល និង ទម្រង់នៃការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៤ (ការលុបចោលនូវមតកសាសន៍) នេះ ។

**មាត្រា ១១៨៩.-** ការលុបចោលដោយទម្រង់នៃមតកសាសន៍

១-ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។

២-បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតកសាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។

**មាត្រា ១១៩០.-** ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ ។

**មាត្រា ១១៩១.-** ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថា បានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

**មាត្រា ១១៩២.-** ការបោះបង់សិទ្ធិលុបចោលមតកសាសន៍

ម្ចាស់បណ្តាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍ បានឡើយ ។

**មាត្រា ១១៩៣.-** ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឱ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះ មិនបានអនុវត្តករណីយកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះអាចទាមទារទៅតុលាការ ឱ្យលុបចោលអច្ច័យទាននោះបាន ។

## ផ្នែកទី ៥

## អានុភាពនៃមតកសាសន៍

**មាត្រា ១១៩៤.-** ពេលដែលមតកសាសន៍បង្កើតអានុភាព

១-មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

**មាត្រា ១១៩៥.-** អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍

១-បើមតកជនបានកំណត់ចំណែកមត៌ក ឬ វិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថា ត្រូវបានធ្លាក់ទៅ

សន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេលដែលមតកជននោះ បានទទួលមរណភាព ។

**មាត្រា ១១៩៦.-** មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ករបស់សន្តតិជន ឬ វិធីនៃការបែងចែកមត៌ក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១១៩៧.-** ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតក-សាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ១១៩៨.–** សិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ បើពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

## ផ្នែកទី ៦
## អច្ច័យទាន

**មាត្រា ១១៩៩.–** និយមន័យនៃអច្ច័យទាន

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ។

**មាត្រា ១២០០.–** មរណភាពរបស់អច្ច័យលាភី

១-អច្ច័យទាន ពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាព នៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

៣-ក្នុងករណីដែលសន្តតិជនដែលត្រូវបានសន្មត ជាអច្ច័យលាភី បញ្ញត្តិនៃកថា-ខណ្ឌទី ១ ខាងលើនេះ មិនរារាំងចំពោះការយកបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៩៦ (មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍) នៃក្រមនេះ មកអនុវត្តឡើយ ។

**មាត្រា ១២០១.–** ការបោះបង់អច្ច័យទាន

១-នៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីការបោះបង់សន្តតិកម្ម ។

២-ការបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

**មាត្រា ១២០២.–** ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ដោយកំណត់អំឡុងពេលសមរម្យ ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

**មាត្រា ១២០៣.–** ការបោះបង់ ឬ ការទទួលស្គាល់ ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៤.–** ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

១-ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាន ពុំអាចលុបចោលវិញបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទទួលស្គាល់ និង ការបោះបង់អច្ច័យទាននេះ ។

**មាត្រា ១២០៥.–** ការទទួលស្គាល់ ឬ បោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

១-ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ ។

២-ទោះបីបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបោះបង់អច្ច័យទានមានកំណត់ បានដែរ ។

**មាត្រា ១២០៦.–** សិទ្ធិទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់តាំងពីពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យ-ទានបាន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៧.–** អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតនៅក្នុងមត៌ក

អច្ច័យទាន ពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមត៌ក នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

**មាត្រា ១២០៨.–** អច្ច័យទាននៃវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

បើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទាន ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

**មាត្រា ១២០៩.–** ឧបាទេសកម្មលើវត្ថុ

១-បើម្ចាស់បណ្តាំមានសិទ្ធិទាមទារប្រាក់សំណង ចំពោះតតិយជន ដោយការបាត់បង់ ឬ កែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬ បាត់បង់ការកាន់កាប់វត្ថុនោះ ត្រូវសន្មតថាបានយកសិទ្ធិនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា ឬ

ច្របល់គ្នានឹងវត្ថុផ្សេងទៀត បើម្ចាស់បណ្តាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) នៃក្រមនេះ ត្រូវសន្មតថា ម្ចាស់បណ្តាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិអវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

**មាត្រា ១២១០.-** ឧបាទេសកម្មលើវត្ថុ នៃអច្ច័យទាននៃសិទ្ធិលើបំណុល

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន បើម្ចាស់បណ្តាំបានទទួលសំណង ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមតិក ត្រូវសន្មតថាបានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវសន្មតថាបានយកប្រាក់ និង ប្រាក់បញ្ញើ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមតិក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានសង ។

**មាត្រា ១២១១.-** ការទទួលខុសត្រូវរបស់អច្ច័យលាភី នៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

១-ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។

២-បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២១២.-** សិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល

១-អច្ច័យលាភីសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន ។

២-បើមត៌កទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឱ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។

## ផ្នែកទី ៧
## ការប្រតិបត្តិមតកសាសន៍

**មាត្រា ១២១៣.–** ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

១-អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះមតកសាសន៍ដែលបានធ្វើដោយលិខិតយថាភូត ។

៣-លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ ។

៤-បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

៥-ចំពោះលិខិតមតកសាសន៍ ទោះបីជាបានបើកនៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ក៏ដោយ មិនត្រូវបាត់បង់អានុភាព ដោយសារតែមូលហេតុនោះឡើយ ។

**មាត្រា ១២១៤.-** ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

១-បើម្ចាស់បណ្ដាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-បើជនដែលបានទទួលអាណត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២១៥.-** ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

បើអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតក-សាសន៍នោះ ត្រូវអនុវត្តភារកិច្ចនោះ ភ្លាមៗ ។

**មាត្រា ១២១៦.-** ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ

១-សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ ហើយដាស់តឿន ចំពោះជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតក-សាសន៍ ឱ្យឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន ។ បើអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់ ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីការងារនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតតិយជន ដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ឱ្យបានឆាប់រហ័ស ។ ក្នុងករណីនេះ បើតតិយជននោះមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ នៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីអាណត្តិនោះ ។

**មាត្រា ១២១៧.-** បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និង ជន

ធនក្ស័យ ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ។

**មាត្រា ១២១៨.-** ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ បើបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ១២១៩.-** ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

១-អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-សន្តតិជន អាចមានវត្តមាន នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។

**មាត្រា ១២២០.-** សិទ្ធិអំណាច មុខនាទី នៃអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។

**មាត្រា ១២២១.-** ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន

១-បើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមត៌ក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ។

២-ការចាត់ចែងដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ។

**មាត្រា ១២២២.-** ការប្រតិបត្តិមតកសាសន៍ ចំពោះទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់

ក្នុងករណីមតកសាសន៍ ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ បញ្ញត្តិចាប់ពីមាត្រា ១២១៩ (ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ) រហូតដល់មាត្រា ១២២១

(ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះតែទៅលើទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២២៣.-** ឋានៈនៃអ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតក-សាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ។

២-សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ ចំពោះសន្តតិជន ។

**មាត្រា ១២២៤.-** សិទ្ធិជ្រើសតាំងបន្ត របស់អ្នកប្រតិបត្តិមតកសាសន៍

១-បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង នៅក្នុងមតកសាសន៍ ។

២-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។ បើអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចនោះ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។

**មាត្រា ១២២៥.-** សហអ្នកប្រតិបត្តិមតកសាសន៍

១-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ អ្នកប្រតិបត្តិមតក-សាសន៍នីមួយៗ អាចធ្វើសកម្មភាពរក្សាទុកបាន ។

**មាត្រា ១២២៦.–** កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន ។

២-ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមតិក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២២៧.–** ការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

១-បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើអ្នកប្រតិបត្តិមតកសាសន៍ បានធ្វេសប្រហែសក្នុងភារកិច្ច ឬ បើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់ជននោះបាន ។

**មាត្រា ១២២៨.–** សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក ។ ប៉ុន្តែ មិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ ។

**មាត្រា ១២២៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាណត្តិ

បញ្ញត្តិស្តីពីអាណត្តិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ។

# ជំពូកទី ៤
# ភាគបម្រុង

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៣០.–** អ្នកមានសិទ្ធិលើភាគបម្រុង

១-បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្ដាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជន អាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិ ដូចខាងក្រោមនេះ :

ក-១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្ដាយ ឬ ជីដូន ជីតាប៉ុណ្ណោះ ។

ខ-១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង ។

២-ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗ អាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមត៌កបាន ។

៣-បញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង មាត្រា ១១៥៨ (ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះភាគបម្រុង ។

**មាត្រា ១២៣១.–** ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្ដើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) និង តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្មដែលបានកំណត់ក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) នៃក្រមនេះ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ ។

២-សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់ ត្រូវកំណត់តម្លៃនោះ ដោយផ្អែកតាមការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែល

ត្រូវបានជ្រើសតាំងដោយតុលាការ ។

៣-កាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលផងដែរ នូវសោហ៊ុយបុណ្យសពតាមឋានៈរបស់មតកជន ។

**មាត្រា ១២៣២.-** ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ប្រទានកម្មដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវក្លាយជាមូលដ្ឋានក្នុងការគណនាភាគបម្រុង លើកលែងតែផលប្រយោជន៍ពិសេសដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ :

ក- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ។

ខ- ក្រៅពីប្រទានកម្មដែលបានកំណត់ក្នុងចំណុច ក ខាងលើនេះ ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្ដាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ។

២-នៅក្នុងជំពូកទី ៤ (ភាគបម្រុង) នេះ ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ត្រូវចាត់ទុកថាជាប្រទានកម្ម ។

**មាត្រា ១២៣៣.-** ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និង ប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) ខាងលើនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ការកំណត់ចំណែកមត៌ក និង ការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនោះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ ។

**មាត្រា ១២៣៤.–** ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារបានដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និង ចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម ។

## ផ្នែកទី ២
## វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

**មាត្រា ១២៣៥.–** ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និង អ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ ។

**មាត្រា ១២៣៦.–** លំដាប់នៃការកាត់បន្ថយ

ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ជាមុនទេ ។

**មាត្រា ១២៣៧.–** ការកាត់បន្ថយអច្ច័យទាន ជាអាទិ៍

១-ដំបូង ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន នៅក្នុងពេលជាមួយគ្នា ហើយប្រសិនបើនៅតែខ្វះ ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ។

២-អច្ច័យទាន ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ ។

បញ្ញត្តិនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចំណែកមត៌កដែលបានកំណត់តាមវិធីធ្វើអនុប្បទានទ្រព្យសម្បត្តិដែលមានកំណត់ តែមួយចំណុច ឬ ច្រើនចំណុច ។ ប៉ុន្តែក្នុងករណីដែលអច្ច័យទានដែលធ្វើចំពោះសន្តតិជន និង ចំណែកមត៌កដែលបានកំណត់នោះ ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ផ្នែកដែលលើសពីចំនួនប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះ ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ ។

៣-ចំណែកមត៌កតាមមតកសាសន៍ ដែលបានកំណត់ជាភាគនៃមត៌ក ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយធ្វើការផ្លាស់ប្តូរភាគនោះ ។

៤-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈពិសេសផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមទៅតាមឆន្ទៈនោះ ។

**មាត្រា ១២៣៨.-** លំដាប់នៃការកាត់បន្ថយប្រទានកម្ម ជាអាទិ៍

១-ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មក ត្រូវធ្វើចំពោះប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនមកជាបន្តបន្ទាប់ ។

២-បើបានធ្វើប្រទានកម្ម ឬ ទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំនៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះអាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ។

**មាត្រា ១២៣៩.-** ការសងផលមកវិញ

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ក្រៅពីទ្រព្យសម្បត្តិ ឬ ប្រាក់សំណងដែលត្រូវសងមកវិញនោះ ត្រូវសងមកវិញផងដែរនូវផលដែលកើតឡើងក្រោយពីថ្ងៃដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ ។

**មាត្រា ១២៤០.-** បន្ទុកនៃការខាតបង់ ដោយអសាធនភាព

ការខាតបង់ដែលកើតឡើងដោយសារអសាធនភាព របស់សហសន្តតិជន អច្ច័យ-

លាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ ត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ។

**មាត្រា ១២៤១.–** ការកាត់បន្ថយប្រទានកម្មដែលមានភ្ជាប់បន្ទុក

ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក ដែលបានដកតម្លៃនៃបន្ទុកចេញពីក្នុងតម្លៃនៃកម្មវត្ថុនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយបាន ។

**មាត្រា ១២៤២.–** ការកាត់បន្ថយចំពោះកិច្ចសន្យា ជាអាទិ៍ ដែលត្រូវចាត់ទុកថាជាប្រទានកម្ម

១-កិច្ចសន្យាដែលបានធ្វើដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាប្រទាន-កម្ម តែក្នុងករណីដែលត្រូវបានធ្វើឡើង ដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងប៉ុណ្ណោះ ។ ក្នុងករណីនេះ បើអ្នកមានសិទ្ធិលើភាគបម្រុង ទាមទារឱ្យធ្វើការកាត់បន្ថយនោះ អ្នកនោះត្រូវសងតម្លៃថ្នូរនោះមកវិញ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលើកលែងកាតព្វកិច្ច ដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ។

**មាត្រា ១២៤៣.–** ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម

១-បើសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ បានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដទៃ ជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាត់ចែងនោះ ទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ។ ប៉ុន្តែ ប្រសិនបើអនុប្បទានិកនោះបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង នៅពេលធ្វើអនុប្បទាន អ្នកមានសិទ្ធិលើភាគបម្រុងក៏អាចទាមទារឱ្យកាត់បន្ថយចំពោះអនុប្បទានិកនោះ បានដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក បានបង្កើតសិទ្ធិលើកម្មវត្ថុនៃប្រទានកម្មនោះ ។

**មាត្រា ១២៤៤.-** សំណងដោយបង់តម្លៃ

១-សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសង បាន ដោយបង់តម្លៃនៃចំណែកមត៌កដែលបានកំណត់ តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬ តម្លៃ នៃកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវទទួល ការកាត់បន្ថយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះ ករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១២៤៣ (ការកាត់ បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម) ខាងលើនេះ ។

## ផ្នែកទី ៣
## ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

**មាត្រា ១២៤៥.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ ផ្ដើមសន្តតិកម្ម និង ការកំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬ ការទទួលផល ប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ ។ សិទ្ធិទាមទារឱ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយ អាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្ដើម សន្តតិកម្ម ។

**មាត្រា ១២៤៦.-** ការបោះបង់ភាគបម្រុង

ភាគបម្រុង អាចបោះបង់ចោលទាំងអស់ ឬ មួយផ្នែកបាន ។ ប៉ុន្តែ ការបោះបង់ ភាគបម្រុងនៅមុនពេលចាប់ផ្ដើមសន្តតិកម្ម មានអានុភាព លុះត្រាតែបានទទួលការអនុ- ញ្ញាតពីតុលាការ ។

**មាត្រា ១២៤៧.–** ករណីជាសហសន្តតិជន

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ ។

## ជំពូកទី ៥
## ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៤៨.–** អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយកម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិ-ជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមត៌កបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

**មាត្រា ១២៤៩.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនទទួលមរណភាព

បើសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះ បានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។

**មាត្រា ១២៥០.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនជាអនីតិជន ជាអាទិ៍

បើសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។

**មាត្រា ១២៥១.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

១-ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសន្តតិជនបានចាត់ចែងមត៌កដើម្បីសងកាតព្វកិច្ចផ្សេង ដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម នៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ បញ្ញត្តិនៃចំណុច ក មាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះមិនត្រូវយកមកអនុវត្តឡើយ ។

**មាត្រា ១២៥២.-** ការលុបចោលការយល់ព្រម ឬ ការបោះបង់

១-ការយល់ព្រម និង ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះជានៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ក៏ដោយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងចំពោះការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម ដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈឡើយ ។ ប៉ុន្តែ សិទ្ធិលុបចោលនេះ ត្រូវរលត់ បើពុំបានអនុវត្ត នៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ

គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផង ដែរ ចំពោះករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមធ្វើសន្តតិកម្ម ។

៣-បុគ្គលដែលមានបំណងចង់លុបចោល ការយល់ព្រមដោយកម្រិត ឬ ការបោះបង់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវដាក់ពាក្យសុំលុបចោលនោះ ទៅតុលាការ ។

**មាត្រា ១២៥៣.-** ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម

សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលយល់ព្រមលើសន្តតិកម្មបានឡើយ ។

## ផ្នែកទី ២
## ការយល់ព្រម

**មាត្រា ១២៥៤.-** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១២៥៥.-** ការយល់ព្រមទាំងស្រុងតាមច្បាប់

ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ :

ក-បើសន្តតិជនបានចាត់ចែងមត៌កនោះ ទាំងអស់ ឬ មួយភាគ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ-បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

គ-ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ។

**មាត្រា ១២៥៦.–** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៥៧.–** វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

**មាត្រា ១២៥៨.–** អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយល្បាកុល-

ភាពឡើយ ។

**មាត្រា ១២៥៩.-** ករណីដែលហេតុនៃការយល់ព្រមតាមច្បាប់ កើតឡើង ក្រោយការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ គ នៃមាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិ-ជននោះ ត្រូវចាត់ទុកថា សន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍នៃការយល់ព្រមដោយកម្រិត មិនបង្កើតអានុភាព តាំងពីដំបូងមក ។

២-បើមានមូលហេតុដូចកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសហ-សន្តតិជនម្នាក់ ឬ ច្រើននាក់ ដែលបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលពុំអាចទទួលការសងដោយមត៌ក តាមចំណែកមត៌កនីមួយៗនោះបាន ។

## ផ្នែកទី ៣
## ការបោះបង់

**មាត្រា ១២៦០.-** ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ ។

**មាត្រា ១២៦១.-** អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។

# ជំពូកទី ៦
# ការគ្រប់គ្រង និង ការបែងចែកមត៌ក

## ផ្នែកទី ១
## ការគ្រប់គ្រងមត៌ក

**មាត្រា ១២៦២.-** ការរក្សាទុក និង ការគ្រប់គ្រងមត៌ក

១-សន្តតិជនដែលកាន់កាប់មត៌ក នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក ។ ប៉ុន្តែ ការរក្សាទុក និង ការគ្រប់គ្រងនេះ ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៦៣ (ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍) ខាងក្រោមនេះ ។

២-ទោះបីជានៅមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ ។ ទោះបីជានៅក្រោយពេលបោះបង់សន្តតិកម្មក៏ដោយ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ រហូតដល់ពេលបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់នោះ អាចចាប់ផ្តើមធ្វើការគ្រប់គ្រងមត៌កនោះបាន ។

**មាត្រា ១២៦៣.-** ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍

បើបានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវធ្វើការគ្រប់គ្រងមត៌ក ។ ប៉ុន្តែ ប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២៦៤.-** អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន

១-បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ គ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក ។

២-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១២៥៣ (ការហាមឃាត់មិនឱ្យធ្វើបណ្ដឹងចំពោះសន្តតិជន នៅមុនការយល់ព្រម) នៃក្រមនេះ ក៏ដោយ អ្នកគ្រប់គ្រងជាបណ្ដោះអាសន្នដែលត្រូវបានជ្រើសតាំងដោយបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ គឺជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងនោះ ចំពោះសិទ្ធិទាមទារដែលទាក់ទងនឹងមត៌ក នៅក្នុងនាមជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងរបស់សន្តតិជននៃមតកជន ដោយបញ្ជាក់ឈ្មោះមតកជននោះផង រហូតដល់ពេលដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មនោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ។

**មាត្រា ១២៦៥.–** សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក

សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ សោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះ ។

## ផ្នែកទី ២
## ការបែងចែកមត៌ក

**មាត្រា ១២៦៦.–** ការពិភាក្សាបែងចែកមត៌ក

១-សហសន្តតិជនអាចចាប់ផ្ដើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្ដើមសន្តតិកម្ម ។ ប៉ុន្តែ ចំពោះការផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌ក ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៧៧ (ការហាមឃាត់មិនឱ្យផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិ) នៃក្រមនេះ ឬ ចំពោះករណីដែលមតកជនហាមឃាត់ការបែងចែកមត៌កតាមមតកសាសន៍ ការបែងចែកមត៌កពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ ។

២-ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ ។

**មាត្រា ១២៦៧.–** មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌កនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់ល័ក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

**មាត្រា ១២៦៨.–** សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ ។

**មាត្រា ១២៦៩.–** សំណាងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍

បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌ក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះ និង មិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ ។

**មាត្រា ១២៧០.–** ការបែងចែកដោយតុលាការ

១-បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការបែងចែកមត៌កនោះបាន ។

## គន្ថីទី ៩

## អវសានប្បញ្ញត្តិ

## ជំពូកទោល

## អវសានប្បញ្ញត្តិ

**មាត្រា ១៣០៥.– កាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍**

១-ក្រមនេះ ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់ ។

២-ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និងចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចរល.០៧១២.២២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ហត្ថលេខា**
**អង្គ វង្សវឌ្ឍានា**

លេខៈ៥៧៤ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**យុន ជិនកេន**

453/453